ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth, and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា

# ក្នុងខេត្តព្រៃវែង

# THE SITUATION OF TEACHER ALLOCATION AND UTILIZATION AT PRIMARY SCHOOLS IN PREY VENG PROVINCE

ដោយ / By

ប៊ិន សុផាន់ណាក់ / BIN SOPHANAK

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ ជំនាន់ទី៣

ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

ឆ្នាំសិក្សា២០១៩-២០២០

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth, and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា

# ក្នុងខេត្តព្រៃវែង

## THE SITUATION OF TEACHER ALLOCATION AND UTILIZATION AT PRIMARY SCHOOLS IN PREY VENG PROVINCE

ដោយ / By

ប៊ិន សុផាន់ណាក់ / BIN SOPHANAK

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ ជំនាន់ទី៣

ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

ឆ្នាំសិក្សា២០១៩-២០២០

សាស្ត្រាចារ្យដឹកនាំ ៖ លោក ចាប រតនា

# លិខិតបញ្ជាក់ និងទទួលស្គាល់ របស់នាយកវិទ្យាស្ថានជាតិអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ:.........៤......... វជអ.**

## លិខិតបញ្ជាក់ និងទទួលស្គាល់

**នាយកវិទ្យាស្ថានជាតិអប់រំ**

**សូមបញ្ជាក់ និងទទួលស្គាល់ថា៖**

លោក **ប៊ិន សុផាន់ណារ៉ា** និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០ ពិតជាបានការពារគម្រោងស្រាវជ្រាវ និងសរសេរនិក្ខេបបទ ដែលមានប្រធានបទ "**ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា" ករណីសិក្សា ៖ ខេត្តព្រៃវែង** ស្របតាមលក្ខខណ្ឌកម្មវិធីបណ្តុះបណ្តាល ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ពិតប្រាកដមែន។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សឿង សុវណ្ណារ៉ា

# លិខិតបញ្ជាក់

លោក **ចាប រតនា** ជាសាស្ត្រាចារ្យដឹកនាំ

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

ក្នុងនាមជាសាស្ត្រាចារ្យដឹកនាំការសរសេរនិក្ខេបបទស្រាវជ្រាវសូមបញ្ជាក់ថា បេក្ខជន **ម៉ិន សុផានណាក់** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវក្រោមប្រធានបទ “ **ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងខេត្តព្រៃវែង**” ប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០......

**សាស្ត្រាចារ្យដឹកនាំ**

**លោក ចាប រតនា**

អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ

នៃវិទ្យាស្ថានជាតិអប់រំ

# **សេចក្តីអះអាងរបស់បេក្ខជន**

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា “ **ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងខេត្តព្រៃវែង**” សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេស វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ នៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង ។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលបានសញ្ញាបត្រ នៅវិទ្យាស្ថានជាតិអប់រំ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយឡើយ ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន ។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃ ខែ ឆ្នាំ២០......

**ចិន សុផាន់ណាក់**

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :៣៣៤.....ខជអ. ឧក

**លិខិតឧទ្ទេសនាម**

យោង៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩។

បុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចូលរួមវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២០ ចាប់ពីម៉ោង៨៖០០នាទី ព្រឹកតទៅ នៅមជ្ឈមណ្ឌលវប្បធម៌ **សម្តេច ហ៊ុន សែន និងលោកជំទាវ៖**

I. **គណៈកម្មការវាយតម្លៃ**

**ក្រុមទី១**

| | | | |
|---|---|---|---|
| ១ | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | នាយកវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២ | លោកបណ្ឌិត នី វង្សា | ប្រធានការិយាល័យសិក្សា | អនុប្រធាន |
| ៣ | លោក ម៉ៅ សារឿន | ប្រធានដេប៉ាតឺម៉ង់អប់រំ | សមាជិក |
| ៤ | លោកបណ្ឌិត គួយ សុគាន | គ្រូឧទ្ទេស | សមាជិក |
| ៥ | ល.ស នូ ចន្ទី | គ្រូឧទ្ទេស | សមាជិក |
| ៦ | លោក សៀង វាសនា | គ្រូឧទ្ទេស | សមាជិក |

**ក្រុមទី២**

| | | | |
|---|---|---|---|
| ១ | លោកបណ្ឌិត នូវ វីរ៉ា | នាយករងវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២ | លោក ម៉ន មុនិន្ទ | ប្រធានដេប៉ាតឺម៉ង់ផែនការ | អនុប្រធាន |
| ៣ | លោក ប៉ូ ប៊ុន្នួន | អនុប្រធានការិយាល័យសិក្សា | សមាជិក |
| ៤ | លោកបណ្ឌិត ឈាង សង្វាត | គ្រូឧទ្ទេស | សមាជិក |
| ៥ | លោកបណ្ឌិត អាន វ៉ូប្រាវ | គ្រូឧទ្ទេស | សមាជិក |
| ៦ | ល.ស ខែក សំណាង | គ្រូឧទ្ទេស | សមាជិក |

II. **លេខាធិការ** (កត់ត្រាមតិយោបល់គណៈកម្មការវាយតម្លៃ បូកសរុបពិន្ទុ និងបញ្ចូលមធ្យមភាគក្នុងតារាងពិន្ទុ)

**ក្រុមទី១**

| | | | |
|---|---|---|---|
| ១ | លោក ចាប រតនា | អនុប្រធានដេប៉ាតឺម៉ង់ផែនការ | ប្រធាន |
| ២ | លោក លន លីណា | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |
| ៣ | ល.ស សុខ វណ្ណា | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |

**ក្រុមទី២**

| | | | |
|---|---|---|---|
| ១ | លោក ឡុច ចាន់ថន | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | ប្រធាន |
| ២ | លោក ចាន់ ធឿន | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |
| ៣ | លោក ម៉ែន សុខសុន្ទី | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |

III. **អ្នកសម្របសម្រួល** (រៀបចំលិខិតបទដ្ឋាន ដំណើរការកម្មវិធី និងបូកសរុបរបាយការណ៍)

| | | | |
|---|---|---|---|
| ១ | លោក លឹម វ៉ាន់ | អនុប្រធានដេប៉ាតឺម៉ង់ផែនការ | ប្រធាន |

ថ្ងៃពុធ ៤រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**កន្លែងទទួល៖**

-នាយក នាយករង នាយិការងវេជអ "ដើម្បីជ្រាបជាព័ត៌មាន និងអនុវត្ត"

-ប្រធានដេប៉ាតឺម៉ង់-ការិយាល័យក្រោមឱវាទវេជអ "ដើម្បីសហការ"

-សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារ៖ ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការវេជអ

# សេចក្តីថ្លែងអំណរគុណ

ដាបឋមខ្ញុំបាទពិតជាមានសេចក្តីសប្បាយរីករាយដោយបានបញ្ចប់ការសិក្សា និងការស្រាវជ្រាវ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិដោយជោគជ័យ ។ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

ក្រសួងអប់រំ យុវជន និងកីឡា ដែលបានរៀបចំបង្កើតឱ្យមានវគ្គវណ្ណុះបណ្តាលនេះឡើងតាមរយៈ វិទ្យាស្ថានជាតិអប់រំ ក្នុងការផ្តល់ឱកាសឱ្យខ្ញុំបាទ ក៏ដូចជាមន្ត្រីអប់រំដទៃបានអភិវឌ្ឍសមត្ថភាពបន្ថែម ។

ឯកឧត្តមនាយក នាយករង លោក លោកស្រី ជាសាស្ត្រាចារ្យ បុគ្គលិកនៃវិទ្យាស្ថានជាតិអប់រំ និង លោកគ្រូ អ្នកគ្រូឧទ្ទេសថ្នាក់ក្រសួងទាំងអស់ដែលបានលះបង់ពេលវេលាដ៏មានតម្លៃ និងចូលរួមចំណែកឱ្យ វគ្គបណ្តុះបណ្តាលនេះបញ្ចប់ជាស្ថាពរ ប្រកបដោយភាពជោគជ័យ។

លោកប្រធាន អនុប្រធាន មន្ត្រីបុគ្គលិកអប់រំ នៃមន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក ក្នុងខេត្តព្រៃវែង លោកនាយក លោកស្រីនាយិកាសាលាបឋមសិក្សាទាំងអស់ដែលចូលរួមផ្តល់ទិន្នន័យនៃ ការស្រាវជ្រាវ និងមិត្តរួមជំនាន់ទាំងអស់ដែលបានចូលរួមផ្តល់ជាគំនិតយោបល់ និងឯកសារពាក់ព័ន្ធ ផ្សេងៗ ទាំងក្នុងការសិក្សា និងការស្រាវជ្រាវរហូតដល់ទីបញ្ចប់ ។

លោក **ចាប រតនា** សាស្ត្រាចារ្យដឹកនាំដែលបានយកចិត្តទុកដាក់ក្នុងការណែនាំ ផ្តល់មតិ យោបល់ បំផុសគំនិតស្មារតី ផ្តល់ទាំងកម្លាំងចិត្តប្រាជ្ញាស្មារតី បច្ចេកទេសវិធីសាស្ត្រ និងជំរុញឱ្យខ្ញុំខិតខំ ប្រឹងប្រែងជម្នះឧបសគ្គ ដើម្បីសម្រេចនូវការសរសេរនិក្ខេបបទនេះឡើងប្រកបដោយគុណភាពខ្ពស់ ។

ខ្ញុំសូមគោរពដឹងគុណបំផុតចំពោះការស្រឡាញ់និងការអាណិតអាសូររបស់អ្នកម្តាយ **ម៉ាខ ឆាខ** និងលោកឪពុកដែលបានចែកឋានទៅហើយ **ចិន ស៊ីថា** ពន្លឺនៃក្តីស្រឡាញ់របស់អ្នកទាំងពីរ និងនាំផ្លូវ ជីវិតរបស់កូនៗជារៀងរហូតទៅ ។

ជាចុងបញ្ចប់ សូមគោរពជូនពរ ចំពោះក្រុមគ្រួសាររបស់ខ្ញុំ ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ សូមទទួលបានសេចក្តីសុខ មានសុភមង្គល មានសុខភាពល្អ និងទទួលបានជោគជ័យគ្រប់ភារ កិច្ច ព្រមទាំងទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

// មូលន័យសង្ខេប

# មូលន័យសង្ខេប

ខេត្តព្រៃវែងជាតំបន់ទំនាបកណ្តាលមានទីតាំងស្ថិតនៅខាងកើតប្រទេស មានព្រំប្រទល់ខាងជើងជាប់ខេត្តត្បូងឃ្មុំ ខាងកើតជាប់ខេត្តស្វាយរៀង ខាងត្បូងជាប់ប្រទេសវៀតណាម និងខាងលិចជាប់ខេត្តកណ្តាល មានផ្ទៃដីសរុប ចំនួន៤៨៨៣ គម² ត្រូវបានបែងចែកជាក្រុងចំនួន១ និង ស្រុកចំនួន១២ ក្នុងនោះរួមមាន ១១៦ ឃុំ និង១១៣៩ភូមិ ចំនួនប្រជាជនសរុបគឺ ១,០៥៧,៤២៨នាក់ ដែលក្នុងនោះ ៥៥៦,០៨២នាក់ ជាស្ត្រី និងមានដង់ស៊ីតេប្រជាជនជាមធ្យមគឺ ២១៧នាក់ ក្នុងផ្ទៃដីមួយគីឡូម៉ែតការ៉េ។ ចំពោះវិស័យអប់រំ នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែងមានការិយាល័យជំនាញចំនួន១២ មានបុគ្គលិកចំនួន១១០នាក់ ស្រី៤៣នាក់ មានការិយាល័យអប់រំ យុវជន និងកីឡាស្រុក/ក្រុងចំនួន១៣ មានបុគ្គលិកចំនួន១៥៦នាក់ ស្រី៤៧នាក់ មានសាលារៀនសរុបទូទាំងខេត្តចំនួន១០៥៧ មានគ្រូសរុបចំនួន ៧,៩០៧នាក់ ស្រី៣,៣០៩នាក់ មានសិស្សសរុបចំនួន២៣៦,៨០៩នាក់ ស្រី១១៥ ៧៥៦នាក់ ចែកចេញជា មត្តេយ្យសិក្សារដ្ឋចំនួន៣៨៦សាលា សាលាបឋមសិក្សាចំនួន៥៤៧សាលា អនុវិទ្យាល័យចំនួន៩២ វិទ្យាល័យចំនួន៣២ និងវិទ្យាល័យឯកជនចំនួន១។

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ ផ្តោតទៅលើការសិក្សាស្វែងយល់អំពីស្ថានភាព បញ្ហាប្រឈម និងដំណោះស្រាយក្នុងការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងខេត្តព្រៃវែងនាពេលបច្ចុប្បន្ន សំដៅលើកកម្ពស់ប្រសិទ្ធភាពក្នុងការប្រើប្រាស់គ្រូបង្រៀន។ ការស្រាវជ្រាវកំណត់យកសាលាបឋមសិក្សាទាំងអស់នៅទូទាំងខេត្តព្រៃវែងដែលមានចំនួន៥៤៧សាលា មានបុគ្គលិកអប់រំសរុបចំនួន៣,៩៥៣នាក់ ស្រី១,៦៦៧នាក់ ដែលក្នុងនោះបុគ្គលិកមិនបង្រៀនមានចំនួន១,២៦២នាក់ ស្រី៣២៧នាក់ និងបុគ្គលិកបង្រៀនមានចំនួន២,៦៩១នាក់ ស្រី១,៣៤០នាក់ និងមានសិស្សសរុបចំនួន១៤៨,២៣០នាក់ ស្រី ៦៩,៤៧០នាក់។ ការស្រាវជ្រាវនេះមានការចូលរួមផ្តល់មតិយោបល់ព្រមទាំងសំណូមពរពីគណៈគ្រប់គ្រងសាលាចំនួន១នាក់ក្នុង១សាលា។ វិធីសាស្ត្រប្រមូលទិន្នន័យត្រូវបានធ្វើឡើងតាមបែបគុណវិស័យ និងបរិមាណវិស័យ ដែលទិន្នន័យចម្បងបានមកពីការប្រើឧបករណ៍សម្រាប់ប្រមូលទិន្នន័យ តាមរយៈបញ្ជីកម្រងសំណួរដោយប្រើប្រព័ន្ធបច្ចេកវិទ្យា Google Forms និងទិន្នន័យបន្ទាប់បន្សំទទួលបានពីមន្ទីរអប់រំ

យុវជន និងកីឡាខេត្តព្រៃវែង។ ការវិភាគទិន្នន័យដោយប្រើប្រាស់កម្មវិធី Microsoft Excel 2016 ដែលបង្ហាញជាតារាង ជាចំនួន ជាភាគរយ ជាក្រាប និងធ្វើការបកស្រាយលើសំណួរបែបគុណវិស័យដោយការធ្វើចំណាត់ថ្នាក់ជាក្រុមដោយផ្អែកទៅលើទស្សនៈ និងចម្លើយដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា រួចធ្វើការបរិយាយ និងពន្យល់តាមចំណាត់ថ្នាក់នៃក្រុមនីមួយៗ ។

ការស្រាវជ្រាវនេះបានបង្ហាញនូវលទ្ធផលឱ្យឃើញថា៖ (១) ការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សានៅក្នុងខេត្តព្រៃវែងនាពេលបច្ចុប្បន្នពុំទាន់មានប្រសិទ្ធភាពនៅឡើយ។ តាមលទ្ធផលស្រាវជ្រាវបានបង្ហាញថា នៅបឋមសិក្សាក្នុងខេត្តព្រៃវែង នៅខ្វះគ្រូបង្រៀនចំនួន៤៤២នាក់ បើគិតតាមនិយាមអតិបរមា ហើយបើគិតតាមនិយាមអប្បបរមាវិញ នៅខ្វះគ្រូបង្រៀនចំនួន១២៨៦នាក់។ ចំពោះតម្រូវការជាក់ស្តែងដែលកំពុងអនុវត្តវិញនោះ នៅខ្វះគ្រូបង្រៀនរហូតដល់ទៅចំនួន១៨៤២នាក់ឯណោះ ហើយនៅក្នុងចំណោមស្រុក-ក្រុងទាំង១៣ មានតែនៅក្រុងព្រៃវែងមួយប៉ុណ្ណោះដែលលើសគ្រូបង្រៀនចំនួន១៥នាក់។ (២)ការប្រើប្រាស់និយាមសិស្សថ្នាក់ក្នុងខេត្តព្រៃវែងមិនត្រឹមត្រូវតាមនិយាមសិស្សថ្នាក់ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។ ពោលគឺក្នុងចំណោមថ្នាក់សរុបជាក់ស្តែងទាំងអស់ មានតែប្រមាណជា៤៦.៥%ប៉ុណ្ណោះដែលអាចអនុវត្តបានត្រឹមត្រូវតាមនិយាម ហើយចំនួនថ្នាក់រហូតដល់ទៅប្រមាណជា៥១.១%ដែលមានចំនួនសិស្សតិចជាងនិយាម និងក៏មានថ្នាក់ដែលមានចំនួនសិស្សច្រើនប្រមាណជា២.៤%ផងដែរ។ (៣)ការកង្វះគ្រូបង្រៀនជាបញ្ហាប្រឈមដ៏សំខាន់ដែលធ្វើឱ្យមានការពិបាកដល់គណៈគ្រប់គ្រងសាលាក្នុងការការរៀបចំដំណើរការបង្រៀននិងរៀន ការធ្វើបំណែងចែកនិងការស្វែងរកគ្រូមកបង្រៀន គ្រូបង្រៀនខ្វះវិធីសាស្ត្រក្នុងការគ្រប់គ្រងការបង្រៀននិងរៀនចំពោះថ្នាក់គួប ដោយសារតែពុំធ្លាប់បានបណ្តុះបណ្តាលការបង្រៀនថ្នាក់គួប គ្រូបង្រៀនថ្នាក់ពីរពេលគ្មានវេលាគ្រប់គ្រាន់ក្នុងការផលិតសម្ភារៈឧបទេស គ្រូចូលបង្រៀនយឺតពេល ដែលធ្វើឱ្យសិស្សានុសិស្សរៀនមិនបានពេញម៉ោង និងរៀនមិនចប់កម្មវិធីសិក្សា (៤) ការដោះស្រាយបញ្ហាចំពោះការលើសខ្វះគ្រូបង្រៀនមានលក្ខណៈល្អ មានការបត់បែនតាមស្ថានភាពជាក់ស្តែង និងបានអនុវត្តតាមគោការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីជំរុញឱ្យមានប្រសិទ្ធភាពនៃការប្រើប្រាស់គ្រូបង្រៀននៅតាមគ្រឹះស្ថានបឋមសិក្សាសាធារណៈ។

# មាតិកា

ទំព័រ


**លិខិតបញ្ជាក់ និងទទួលស្គាល់ របស់នាយកវិទ្យាស្ថានជាតិអប់រំ** ............ II

**លិខិតបញ្ជាក់របស់សាស្ត្រាចារ្យដឹកនាំ** ............ III

**សេចក្តីអះអាងរបស់បេក្ខជន** ............ IV

**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ** ............ V

**សេចក្តីថ្លែងអំណរគុណ** ............ VII

**មូលន័យសង្ខេប** ............ VIII

**មាតិកា** ............ X

**បញ្ជីតារាង** ............ XIII

**បញ្ជីក្រាប** ............ XIV

**ជំពូកទី១ សេចក្តីផ្តើម** ............ 1

១.១.សាវតារ ............ 1

១.២. បញ្ហានៃការស្រាវជ្រាវ ............ 3

១.៣.គោលបំណងនៃការស្រាវជ្រាវ ............ 4

១.៤.សំណួរស្រាវជ្រាវ ............ 4

១.៥.សារៈសំខាន់នៃការស្រាវជ្រាវ ............ 4

១.៦.វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ............ 5

១.៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............ 6

**ជំពូកទី២ រំលឹកទ្រឹស្តី** ............ 7

២.១.និយមន័យពាក្យគន្លឹះ ............ 7

២.២.និយមន័យពាក់ព័ន្ធ ............ 7

២.៣.លក្ខណៈទូទៅនៃប្រជាសាស្ត្ររបស់ខេត្តព្រៃវែង ............ 8

២.៤.ស្ថានភាពទូទៅបុគ្គលិកអប់រំនៅខេត្តព្រៃវែង ............ 10

២.៥.និយាមប្រើប្រាស់បុគ្គលិកអប់រំនៅបឋមសិក្សា ............ 11

២.៦.ប្រសិទ្ធភាពនៃការប្រើប្រាស់គ្រូបង្រៀន ............ 14
២.៦.១.ភារកិច្ចកំណត់របស់មន្ត្រីរាជការសម្រាប់ការងាររដ្ឋបាល និងការងារបង្រៀន ............ 14
២.៦.២.បែបបទ និងនីតិវិធីនៃការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា ............ 15
២.៦.៣.ភារកិច្ចបន្ថែម និងភារកិច្ចថ្នាក់គួបសម្រាប់មន្ត្រីរាជការ ............ 17
២.៦.៤.ប្រាក់កម្រៃសម្រាប់គ្រូបង្រៀនជាប់កិច្ចសន្យា និងមន្ត្រីរាជការដែលបានអនុវត្តភារកិច្ចបន្ថែមនិងភារកិច្ចថ្នាក់គួប ............ 18
២.៦.៥.ការគ្រប់គ្រង ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការងារបង្រៀន តាមកិច្ចសន្យា និងការអនុវត្តភារកិច្ចកំណត់ ភារកិច្ចបន្ថែម និងភារកិច្ចថ្នាក់គួប ............ 20
២.៧.បញ្ហាប្រឈមនៃការប្រើប្រាស់គ្រូបង្រៀន ............ 22
២.៨.ដំណោះស្រាយលើស្ថានភាពលើស ឬខ្វះគ្រូបង្រៀន ............ 24
២.៨.១ ការដោះស្រាយចំពោះសាលារៀនលើសគ្រូបង្រៀន ............ 24
២.៨.២ ការដោះស្រាយចំពោះសាលារៀនខ្វះគ្រូបង្រៀន ............ 25
**ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ** ............ 28
៣.១.ដំណើរការនៃការស្រាវជ្រាវ ............ 28
៣.២.វិធីសាស្ត្រនៃការស្រាវជ្រាវ ............ 29
៣.៣.ការជ្រើសរើសភាគសំណាក ............ 29
៣.៤.ឧបករណ៍ស្រាវជ្រាវ ............ 30
៣.៥.ការប្រមូលទិន្នន័យ ............ 31
៣.៦.ការវិភាគទិន្នន័យ ............ 31
៣.៧.ក្រមសីលធម៌ក្នុងពេលធ្វើការសិក្សាស្រាវជ្រាវ ............ 32
**ជំពូកទី៤ លទ្ធផល និងការពិភាក្សា** ............ 33
៤.១.ស្ថានភាពទីតាំងសាលារៀន ............ 33
៤.២.ការកំណត់ពីតម្រូវការ ............ 33
៤.២.១.ស្ថានភាពនៃការប្រើប្រាស់គ្រូនៅតាមសាលាបឋមសិក្សាក្នុងខេត្តព្រៃវែង ............ 33
៤.២.២.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកបាភ្នំ ............ 37
៤.២.៣.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកកំចាយមារ ............ 39

៤.២.៤.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកកំពង់ត្របែក............40
៤.២.៥.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកកញ្ច្រៀច.................42
៤.២.៦.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកមេសាង..................43
៤.២.៧.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកពាមជរ...................45
៤.២.៨.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកពាមរក៍...................46
៤.២.៩.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកពារាំង ....................48
៤.២.១០.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកពោធិ៍រៀង.............49
៤.២.១១.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកព្រះស្ដេច .............50
៤.២.១២.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងក្រុងព្រៃវែង .................52
៤.២.១៣.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនបឋមសិក្សាក្នុងស្រុកស៊ីធរកណ្ដាល ...........53
៤.២.១៤.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកស្វាយអន្ទរ............55
៤.៣.បញ្ហាប្រឈម និងដំណោះស្រាយ.........................................................................56
៤.៤.សំណូមពររបស់នាយកសាលាចំពោះបញ្ហាលើសខ្វះគ្រូបង្រៀន..................................59
**ជំពូកទី៥ សេចក្ដីសន្និដ្ឋាន និងសំណូមពរ**.............................................................62
៥.១.សេចក្ដីសន្និដ្ឋាន ..........................................................................................62
៥.២.សំណូមពរ ..................................................................................................63
៥.៣.អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត...........................................................64
**ឯកសារយោង** ..................................................................................................65
**ឧបសម្ព័ន្ធ**........................................................................................................67

# បញ្ជីតារាង

តារាងទី1៖ និយាមប្រើបុគ្គលិកទីចាត់ការនៅបឋមសិក្សា  សេចក្ដីណែនាំលេខ២៥៦អយក.សណន.... 11

តារាងទី2៖ និយាមប្រើបុគ្គលិកអប់រំទីចាត់ការនៅបឋមសិក្សា សេចក្ដីណែនាំលេខ២០អយក.សណន . 13

តារាងទី3៖ និយាមប្រើបុគ្គលិកបង្រៀននៅបឋមសិក្សាតាមសេចក្ដីណែនាំលេខ២០អយក.សណន..... 13

តារាងទី4៖ ចំនួនសំណាកសម្រាប់ការចុះប្រមូលទិន្នន័យ.......................................................... 29

តារាងទី5៖ ព័ត៌មានទីតាំងសាលាបឋមសិក្សាដែលនាយកសាលាបានបំពេញកម្រងសំណួរ ............... 33

តារាងទី6៖ តម្រូវការគ្រូបង្រៀននៅបឋមសិក្សាតាមក្រុង-ស្រុកនីមួយៗក្នុងខេត្តព្រៃវែង..................... 36

# បញ្ជីក្រាប

ក្រាបទី 1៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងនៅបឋមសិក្សាក្នុងខេត្តព្រៃវែង...34

ក្រាបទី 2៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកបាភ្នំ........................37

ក្រាបទី 3៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកកំចាយមារ................39

ក្រាបទី 4៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកកំពង់ត្របែក .............40

ក្រាបទី 5៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកកញ្ជៀច ....................42

ក្រាបទី 6៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកមេសាង ....................43

ក្រាបទី 7៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកពាមជរ .....................45

ក្រាបទី 8៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកពាមរក៍ .....................46

ក្រាបទី 9៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកពារាំង.......................48

ក្រាបទី 10៖តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកពោធិ៍រៀង ................49

ក្រាបទី 11៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកព្រះស្តេច ................ 51

ក្រាបទី 12៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងក្រុងព្រៃវែង.....................52

ក្រាបទី 13៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកស៊ីធរកណ្តាល ..........54

ក្រាបទី 14៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកស្វាយអន្ទរ ...............55

ក្រាបទី 15៖ ស្ថានភាពជាក់ស្តែងនៃការដោះស្រាយបញ្ហាលើសខ្វះគ្រូនៅបឋមសិក្សាក្នុងខេត្តព្រៃវែង ...57

ក្រាបទី 16៖ ការឆ្លើយតបរបស់នាយកចំពោះការស្នើសុំគ្រូបង្រៀននៅរយៈពេល៥ឆ្នាំចុងក្រោយ .........59

ក្រាបទី 17៖ សំណូមពររបស់នាយកសាលាចំពោះបញ្ហាលើសខ្វះគ្រូបង្រៀន .................................60

# ជំពូកទី១

# សេចក្ដីផ្ដើម

## ១.១.សាវតារ

ការអប់រំគឺជាគន្លឹះដែលឱ្យជីវិតល្អប្រសើរសម្រាប់កុមារគ្រប់រូប និងជាមូលដ្ឋានគ្រឹះរបស់សង្គម ដែលមានភាពរឹងមាំ (Bokova, ២០១៥)។ ក្នុងបរិបទសកល គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ បានផ្ដោតលើការធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ដើម្បីបញ្ជាក់ពីភាពឆ្លើយតបទៅនឹងគោលដៅនេះផែនទីបង្ហាញផ្លូវការអប់រំកម្ពុជា ឆ្នាំ២០៣០បានរំលេចនូវតួនាទីយ៉ាងសំខាន់របស់វិស័យអប់រំក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យមានចំណេះដឹង និងសមត្ថភាពខ្ពស់ ភាពច្នៃប្រឌិត ស្មារតីសហគ្រិនភាព នវានុវត្តន៍ និងក្រមសីលធម៌ខ្ពស់។ ការអប់រំសម្រាប់ឆ្នាំ២០៣០ ផ្ដោតជាសំខាន់លើការផ្ដល់សេវាប្រកបដោយគុណភាព សមធម៌ បរិយាបន្ន សម្រាប់អប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា រួមទាំងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ជាពិសេសការសិក្សាពេញមួយជីវិត ដើម្បីបង្កើនប្រសិទ្ធភាព គុណភាព ផលិតភាពការងារ ស្របតាមយុគសម័យបច្ចេកវិទ្យា ក្នុងការបង្កើនសេដ្ឋកិច្ច និងសុខដុមជីវិតបុគ្គលនិងសង្គម (ក្រសួងអប់រំ យុវជន និងកីឡា, ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០, ២០១៩)។

ក្នុងបរិបទកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា មានតួនាទីជានា និងគ្រប់គ្រងដំណើរការសាលាបឋមសិក្សាទូទាំងប្រទេសឱ្យមានប្រសិទ្ធភាពដើម្បីឆ្លើយតបនឹងតម្រូវការរៀនសូត្ររបស់កុមារប្រកបដោយគុណភាពសមស្របនឹងបរិបទក្នុងតំបន់ និងសកលលោក (នាយកដ្ឋានបឋមសិក្សា, ២០១៧)។

ដោយឈរលើមូលដ្ឋាននេះដែរ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ត្រូវបានរៀបចំឡើងក្នុងគោលដៅបន្តអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា និងបង្កើតមូលដ្ឋានរឹងមាំសម្រាប់ឆ្ពោះទៅឆ្នាំ២០៣០ ព្រមទាំងឆ្លើយតបនឹងចក្ខុវិស័យអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅក្នុងចំណោមអនុវិស័យសំខាន់ៗរបស់វិស័យអប់រំ ការអប់រំបឋមសិក្សា ក៏ត្រូវបានក្រសួងយកចិត្តទុកដាក់យ៉ាងខ្លាំងផងដែរ។ អាទិភាពរបស់អនុវិស័យនេះបានផ្ដោត

លើការកែលម្អការទទួលបានសេវាអប់រំ ការបញ្ចប់ការសិក្សារបស់សិស្សបឋមសិក្សា ជាពិសេសក្រុមកុមារជួបការលំបាក និងការពង្រឹងគុណភាពអប់រំ តាមរយៈកម្មវិធីពង្រឹងការរៀនថ្នាក់ដំបូងរួមមានភាសាខ្មែរ គណិតវិទ្យា និងការជួយគ្រូតាមមុខវិជ្ជា ព្រមទាំងគុណវឌ្ឍិគ្រូបង្រៀន តាមរយៈការអនុវត្តការគ្រប់គ្រងសាលារៀន។ នៅឆ្នាំសិក្សា២០១៧-២០១៨ សាលាបឋមសិក្សា៧៣ភាគរយបានអនុវត្តគោលនយោបាយសាលាកុមារមេត្រីកម្រិតមធ្យម និងកម្រិតអភិវឌ្ឍ ហើយក្រសួងក៏បានបំប៉នគ្រូបង្រៀន អំពីប្រសិទ្ធភាពនៃការរៀននិងបង្រៀន ដូចជា វិធីបង្រៀនតាមបែបការអប់រំវិន័យវិជ្ជមាន និងនាយកសាលាមួយចំនួនបានទទួលការបំប៉នស្តីពីការគ្រប់គ្រងសាលារៀន និងបានបំប៉នបន្ថែមអំពីជំនាញដឹកនាំគ្រប់គ្រងសាលារៀន ដើម្បីជានាបានគណនេយ្យភាព ក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្តការវាយតម្លៃលទ្ធផលសិក្សា និងស្វ័យភាពក្នុងការប្រើប្រាស់ធនធានសាលារៀន (ក្រសួងអប់រំ យុវជន និងកីឡា, ផែនការយុទ្ធសាស្ត្រវិស័យអប់រំ, ២០១៩)។

តាមចក្ខុវិស័យសម្រាប់គ្រូបង្រៀនកម្ពុជាឆ្នាំ២០៣០បានចែងថា គ្រូបង្រៀនកម្ពុជាមានសមត្ថភាពទទួលបានការលើកទឹកចិត្ត និងទទួលបានការគាំទ្រគ្រប់គ្រាន់ ដើម្បីជួយគាំទ្រដល់អ្នកសិក្សាឱ្យទទួលបានការអប់រំប្រកបដោយគុណភាពខ្ពស់។ ប្រព័ន្ធអប់រំកម្ពុជានឹងមានគ្រូបង្រៀនដែលមានសមត្ថភាពវិជ្ជាជីវៈទទួលបានការលើកទឹកចិត្តទទួលបានការគាំទ្រ និងការបំប៉នចំណេះដឹងមុខវិជ្ជាជំនាញគ្រប់គ្រាន់ ព្រមទាំងជំនាញគរុកោសល្យ ស្រលាញ់ការងារបង្រៀន និងសិស្សានុសិស្សរបស់ខ្លួន។ គ្រូបង្រៀននឹងទទួលបានការគាំទ្រជាប្រចាំ ដើម្បីឱ្យពួកគេអាចអភិវឌ្ឍចំណេះដឹងនិងសមត្ថភាពសម្រាប់លើកកម្ពស់ការសិក្សារៀនសូត្ររបស់សិស្ស។ ការបង្រៀនគឺជាវិជ្ជាជីវៈប្រកបដោយក្រមសីលធម៌ ក្នុងនោះគ្រូបង្រៀនត្រូវបំពេញការងារប្រកបដោយស្តង់ដាវិជ្ជាជីវៈ និងសីលធម៌ខ្ពស់បំផុត ដើម្បីជានាឱ្យសិស្សគ្រប់រូបរបស់ខ្លួនអាចទទួលបានជោគជ័យ (ក្រសួងអប់រំ យុវជន និងកីឡា, ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០, ២០១៩)។

## ១.២. បញ្ហានៃការស្រាវជ្រាវ

ផ្អែកទៅលើគោលនយោបាយអប់រំទី២ " ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីគ្រប់លំដាប់ថ្នាក់ " ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចុះនូវយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំលើយុទ្ធសាស្ត្រគោលទី៤ " កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស " ក្នុងយុទ្ធសាស្ត្ររងទី៤.៣ ត្រង់ចំណុច៣.៤ សាលារៀនត្រូវកែលម្អប្រព័ន្ធស្វ័យប្រកាសស្តីពីការប្រើប្រាស់បុគ្គលិកអប់រំ ដើម្បីពង្រឹងការគ្រប់គ្រប់បុគ្គលិកអប់រំឱ្យមានប្រសិទ្ធភាពដោយរកឱ្យឃើញការលើស និងខ្វះបុគ្គលិកអប់រំដែលបម្រើការងារនៅតាមសាលារៀន និងចំណុចទី៣.៦ នាយកសាលាផ្តល់ធាតុចូលទាំងអស់ដែលជាតម្រូវការរបស់សាលា (ក្រសួងអប់រំ យុវជន និងកីឡា, យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ឆ្នាំ ២០១៨-២០២៣, ២០១៨) ។

ដោយមើលឃើញថាបច្ចុប្បន្នក្រសួងអប់រំ យុវជន និងកីឡាមានការអភិវឌ្ឍ និងមានភាពរឹងមាំច្រើនក៏ដោយ ក៏នៅមានបញ្ហាមួយចំនួនដែលគួរយកចិត្តទុកដាក់ផងដែរដូចជា ប្រសិទ្ធភាពនៃការគ្រប់គ្រងបុគ្គលិកអប់រំ ការផ្លាស់ប្តូរទីកន្លែងធ្វើការ ការបាត់បង់ក្របខ័ណ្ឌបុគ្គលិកអប់រំ អវត្តមានបុគ្គលិក ការពង្រាយបុគ្គលិកអប់រំ អតុល្យភាពនៃការផ្គត់ផ្គង់និងតម្រូវការបុគ្គលិកអប់រំដែលមានសមត្ថភាព ប្រសិទ្ធភាពនៃ សនិទានកម្មបុគ្គលិកអប់រំ(របាយគ្រូបង្រៀន) ប្រសិទ្ធភាពនិងសុក្រឹតភាពនៃការអនុវត្តម៉ោងសិក្សានិងកម្មវិធីសិក្សា ប្រសិទ្ធភាពនៃអភិបាលកិច្ចអង្គភាព គុណវុឌ្ឍិនៃបុគ្គលិកអប់រំមួយចំនួននៅមានកម្រិតទាប ការងារគ្រប់គ្រងបុគ្គលិកអប់រំទាំងនៅថ្នាក់ជាតិ ក្រោមជាតិ និងគ្រឹះស្ថានសិក្សាមួយចំនួនពុំទាន់មានភាពសុក្រឹតដែលតែងតែលេចឮនូវបាតុភាពមិនប្រក្រតីជាបន្តបន្ទាប់ (ក្រសួងអប់រំ យុវជន និងកីឡា, ផែនការសកម្មភាព ស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ, ២០១៦)។ គ្រូបង្រៀនជាមូលដ្ឋានគ្រឹះក្នុងការលើកកម្ពស់គុណភាពអប់រំ។ ប៉ុន្តែជាទូទៅក្រសួងអប់រំ យុវជន និងកីឡា ខ្វះគ្រូបង្រៀនគ្រប់ខេត្តពិសេសនៅកម្រិតបឋមសិក្សា (ក្រសួងអប់រំ យុវជន និងកីឡា, ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន, ២០១៨)។

ហេតុយ៉ាងដូច្នេះទើបជំរុញទឹកចិត្តឱ្យអ្នកស្រាវជ្រាវមានចំណាប់អារម្មណ៍ ធ្វើការសិក្សាស្រាវជ្រាវដើម្បីស្វែងយល់អំពីស្ថានភាពជាក់ស្តែងដែលពាក់ព័ន្ធនឹងការប្រើប្រាស់គ្រូបង្រៀន បញ្ហាប្រឈម និងដំណោះស្រាយនានា របស់នាយក/នាយិកា នៅតាមសាលារៀន ។ អ្នកស្រាវជ្រាវបានសម្រេចធ្វើការជ្រើសរើសប្រធានបទមួយក្នុងការសរសេរនិក្ខេបបទស្រាវជ្រាវដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិស្តីពី " **ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា** " ករណីសិក្សានៅក្នុងខេត្តព្រៃវែង ។

## ១.៣.គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណងរួមពីរ ៖

១.សិក្សាពីស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងខេត្តព្រៃវែង។

២.ស្វែងយល់ពីបញ្ហាប្រឈម និងដំណោះស្រាយរបស់នាយក/នាយិកា នៅក្នុងការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងខេត្តព្រៃវែង។

## ១.៤.សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបគោលបំណងស្រាវជ្រាវខាងលើ ការស្រាវជ្រាវនឹងឆ្លើយសំណួរពីរខាងក្រោម ៖

១.តើការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងខេត្តព្រៃវែងមានស្ថានភាពយ៉ាងដូចម្តេច?

២.តើនាយក/នាយិកាជួបបញ្ហាប្រឈម និងមានដំណោះស្រាយអ្វីខ្លះ ក្នុងការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងខេត្តព្រៃវែង?

## ១.៥.សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ នឹងបង្ហាញអ្នកអានពីបច្ចុប្បន្នភាពការគ្រប់គ្រងសាលារៀនរបស់នាយកនាយិកាសាលាបឋមសិក្សា ចំពោះស្ថានភាពនៃការប្រើប្រាស់ និងចាត់ចែងគ្រូបង្រៀននៅតាមអង្គភាពនីមួយៗ ដើម្បីឆ្លើយតបតាមនិយាមប្រើប្រាស់បុគ្គលិកដែលក្រសួងដាក់ឱ្យអនុវត្ត ក្នុងបំណងពង្រឹងគុណភាពអប់រំនៅកម្ពុជា ដោយជម្រុញឱ្យគ្រឹះស្ថានសិក្សានីមួយៗ ប្រើប្រាស់គ្រូបង្រៀនអោយបានត្រឹមត្រូវ ដើម្បីជំរុញប្រសិទ្ធភាពនៃការគ្រប់គ្រងគ្រូបង្រៀននៅគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ ទាំងគ្រូបង្រៀន

ក្របខ័ណ្ឌ គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនពីរថ្នាក់ពីរពេល និងគ្រូបង្រៀនថ្នាក់គួប (សេចក្ដីណែនាំលេខ៥៣អយក.សណន, ២០១៩) និងដើម្បីធ្វើឱ្យការបង្រៀន និងរៀន ធានាបាននូវការអប់រំពលរដ្ឋឱ្យមានលក្ខណៈសម្បត្តិពេញលេញ ប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែក ដោយមានតុល្យភាពរវាង វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងមនសិការស្នេហាជាតិ និងមនុស្សជាតិ ដើម្បីអភិវឌ្ឍជាតិ និងការធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងពិភពលោក (នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា, ២០១៥)។ មិនត្រឹមប៉ុណ្ណោះ ការស្រាវជ្រាវនេះនឹងជួយដល់ ក្រសួងអប់រំ យុវជន និងកីឡាឱ្យបានមើលឃើញពីស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀន នៅតាមអង្គភាពនីមួយៗ ងាយស្រួលក្នុងការជួយដោះស្រាយ ស្ថានភាពទាំងនោះ ក៏ដូចជាជំនួយក្នុងការរៀបចំគោលនយោបាយ អភិវឌ្ឍវិស័យអប់រំផងដែរ ។

## ១.៦.វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ ផ្ដោតទៅលើតែស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅតាមសាលាបឋមសិក្សានៅក្នុងខេត្តព្រៃវែងតែប៉ុណ្ណោះ មិនផ្ដោតទៅលើអ្វីក្រៅពីនេះឡើយ។ ការសិក្សាស្រាវជ្រាវនេះ បានជ្រើសរើសសាលាបឋមសិក្សាទាំងអស់នៅទូទាំងខេត្តព្រៃវែងក្នុងនោះមានក្រុងចំនួន១ និងស្រុកចំនួន១២ ដែលមាន ៥៤៧សាលាបឋមសិក្សា ។

អ្នកស្រាវជ្រាវបានផ្ដល់ជាកម្រងសំណួរបែបគុណវិស័យ និងបរិមាណវិស័យ សម្រាប់សម្ភាសន៍នាយក/នាយិកាសាលាបឋមសិក្សាទាំងអស់ក្នុងខេត្តទាំងមូល។ កម្រងសំណួរខាងលើបានផ្ដោតទៅលើបីចំណុចៈ ផ្នែកទី១ ស្ដីពីការទីតាំងសាលារៀន ផ្នែកទី២ ស្ដីពីការកំណត់តម្រូវការ បញ្ហាប្រឈម និងដំណោះស្រាយ និងផ្នែកទី៣ ស្ដីអំពីសំណូមពររបស់នាយក/នាយិកាសាលាលើការលើសខ្វះគ្រូបង្រៀនដើម្បីប្រមូលទិន្នន័យសម្រាប់ធ្វើការសរសេរនិក្ខេបបទ គ្មានបំណងអ្វីផ្សេងក្រៅពីនេះឡើយ។

## ១.៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ បានរៀបចំបែងចែកជា៥ជំពូក មានដូចខាងក្រោម ៖

ជំពូកទី១ ៖ សេចក្ដីផ្ដើម នៅក្នុងនេះនិយាយអំពី សាវតា បញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ ។

ជំពូកទី២ ៖ ការរំលឹកទ្រឹស្ដី និយមន័យពាក្យគន្លឹះសំខាន់មួយចំនួនដែលត្រូវបានប្រើប្រាស់ក្នុងវិស័យអប់រំ និងពាក់ព័ន្ធទៅនឹងប្រធានបទ ព្រមទាំងទ្រឹស្ដី និងបទបញ្ញត្តិនានា ដើម្បីជាអំណះអំណាង និងជាគំនិតសម្រាប់ធ្វើការស្រាវជ្រាវ និងបង្កើតស្នាដៃថ្មីក្នុងនិក្ខេបបទនេះ។

ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ នៅក្នុងជំពូកនេះដែរ មានដំណើរការនៃការសិក្សាស្រាវជ្រាវ ការជ្រើសរើសគំរូសំណាក ឧបករណ៍ស្រាវជ្រាវ ការប្រមូលទិន្នន័យ និងវិធីសាស្ត្រក្នុងការវិភាគទិន្នន័យ ក្នុងនោះក៏រួមមានក្រមសីលធម៌ក្នុងពេលធ្វើការសិក្សាស្រាវជ្រាវផងដែរ ។

ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា អ្នកស្រាវជ្រាវមានលើកឡើងពីលក្ខណៈជាក់ស្ដែងដែលយើងបានធ្វើការស្រាវជ្រាវ ហើយចំណុចដែលត្រូវលើកឡើង គឺត្រូវឱ្យចូលទៅក្នុងចំណុចទាំងអស់ដែលត្រូវបានចោទសួរក្នុងចំណោទបញ្ហា។ ការពិភាក្សាលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ វិភាគទៅលើចំណុចខ្លាំងទាំងអស់ ដែលបានអនុវត្តជាក់ស្ដែង ថាតើវាដូចគ្នាទៅនឹងទ្រឹស្ដីដែរឬទេ គឺធ្វើឡើងក្នុងបំណងវិភាគរកឱ្យឃើញពីចំណុចខ្វះខាត ដើម្បីធ្វើការកែលម្អ(គឺវិភាគលើកម្រងសំណួរ) ដែលយើងអ្នកស្រាវជ្រាវចុះប្រមូលទិន្នន័យ។

ជំពូកទី៥ ៖ សេចក្ដីសន្និដ្ឋាន និងសំណូមពរ ការសន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់ដែលបានវិភាគ ផ្ដល់ជាសំណូមពរ ក្នុងគោលបំណងរួមចំណែក ធ្វើឱ្យការប្រើប្រាស់គ្រូបង្រៀននៅតាមសាលាបឋមសិក្សានានាកាន់តែប្រសើរឡើង។

# ជំពូកទី២

# រំលឹកទ្រឹស្តី

## ២.១.និយមន័យពាក្យគន្លឹះ

**ស្ថានភាព**គឺសំដៅដល់ទីតាំងស្ថិតនៅពិតប្រាកដ, អាកប្បកិរិយា, ហេតុភេទ, ដំណើរទំនង, បែបបទ, ដើងការ, ដំណើរការដែលប្រព្រឹត្តទៅ (ណាត, ២០០៨) ។ **ការប្រើប្រាស់**(Utilization) គឺជាការប្រើរបស់អ្វីមួយតាមរបៀបដែលមានប្រសិទ្ធភាព (CAMBRIDGE, 2020) ។ **គ្រូ** ជាអ្នកដែលមានចិត្តធ្ងន់, អ្នកដែលគួរគេគោរព គឺអ្នកបង្ហាត់បង្រៀនចំណេះវិជ្ជាសិល្បសាស្ត្រផ្សេងៗដល់សិស្ស គ្រូអក្សរ, គ្រូលេខ, គ្រូភ្លេង... (បណ្ឌិតជម្មណាត, ២០១៨)។ **គ្រូបង្រៀន**សំដៅដល់បុគ្គលិកបង្រៀននៃបុគ្គលិកអប់រំនៅគ្រឹះស្ថានសាធារណៈ និងគ្រឹះស្ថានឯកជនដែលមានអាជ្ញាប័ណ្ណអប់រំ នេះបើយោងតាមមាត្រាទី៤នៃអនុក្រឹត្យលេខ១២៦. អនក្រ.បក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន។ **ការប្រើប្រាស់គ្រូបង្រៀន**ជាការបញ្ចូលធាតុចូលដ៏សំខាន់សម្រាប់សកម្មភាពសាលាដែលមានភាពទន់ខ្សោយក៏ដូចជាមូលដ្ឋានគ្រឹះសម្រាប់សកម្មភាពរបស់សាលាទាំងអស់ (IJSRESSD, 2019)។

## ២.២.និយមន័យពាក់ព័ន្ធ

**ប្រសិទ្ធភាព**(Efficiency)គឺជាគុណភាពដែលអាចបំពេញភារកិច្ចបានជោគជ័យដោយមិនចាំបាច់ខ្ជះខ្ជាយពេលវេលាឬកម្លាំងឡើយ (Collins, 2020)។ រីឯក្នុងសៀវភៅគោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអបរំ ដែលបោះពុម្ពដោយក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១២ បានកំណត់និយមន័យ **ប្រសិទ្ធភាព** គឺសំដៅដល់សមត្ថភាពផលិតផលផ្អែកលើវត្ថុបំណង។

**ការអប់រំបឋមសិក្សា**ឬភូមិសិក្សាទី១ ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ នៃកម្មវិធីសិក្សាអប់រំក្នុងប្រព័ន្ធឬការអប់រំកម្រិតសមមូល ។ ការអប់រំបឋមសិក្សា ត្រូវបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញលើផ្នែករាងកាយ បញ្ញា សីលធម៌ តម្លៃ និងបំណិនមូលដ្ឋានដំបូងចាំបាច់ ដើម្បីឱ្យអ្នកសិក្សាអាចបន្តការសិក្សានៅមធ្យមសិក្សា។ **បុគ្គលិកអប់រំ** សំដៅដល់មន្ត្រីដែលកំពុងបម្រើការក្នុងវិស័យអប់រំ និងបានឆ្លងកាត់ការបណ្តុះបណ្តាលគរុកោសល្យទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យអប់រំ និងសាស្ត្រាចារ្យដែលបម្រើការនៅ

ឧត្តមសិក្សា។ បុគ្គលិកអប់រំរួមមានបុគ្គលិកបង្រៀន ឬមិនបង្រៀនក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ក្រៅក្របខ័ណ្ឌមន្ត្រី ឬបុគ្គលិកបម្រើការក្នុងវិស័យអប់រំឯកជនគ្រប់លំដាប់ថ្នាក់ លើកលែងតែមន្ត្រីនយោបាយដែលកំពុងដឹកនាំវិស័យអប់រំក្នុងក្រសួងស្ថាប័នរដ្ឋ (ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២, ២០០៧)។

យោងតាមអនុក្រឹត្យលេខ ៣០៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលបានកំណត់និយមន័យនៃពាក្យប្រើប្រាស់មួយចំនួនដូចជា **ភារកិច្ចកំណត់**សំដៅភារកិច្ចដែលត្រូវបានកំណត់ឱ្យមន្ត្រីរាជការជាគ្រូបង្រៀន ឬមន្ត្រីរាជការបំពេញការងាររដ្ឋបាល អនុវត្តផ្អែកលើមុខងារ និងថេរៈវេលាកំណត់ដោយច្បាប់។ **ភារកិច្ចបន្ថែម**សំដៅដល់ការងារដែលត្រូវប្រគល់បន្ថែមឱ្យមន្ត្រីរាជការដែលមានភារកិច្ចកំណត់ម្នាក់ទទួលខុសត្រូវគ្រប់យ៉ាងក្នុងការបង្រៀនសិស្សមួយថ្នាក់ ក្នុងពេលផ្សេងតាមកាលវិភាគប្រចាំថ្ងៃនៅគ្រឹះស្ថានបឋមសិក្សាសាធារណៈ។ **ភារកិច្ចថ្នាក់គួប**សំដៅដល់ការងារដែលប្រគល់ឱ្យគ្រូបង្រៀនម្នាក់ទទួលខុសត្រូវគ្រប់យ៉ាងក្នុងការបង្រៀនសិស្សពីរក្រុម ឬ បីក្រុម ដែលមានកម្រិតខុសគ្នានៅក្នុងបន្ទប់រៀនតែមួយ ក្នុងថេរៈវេលាតែមួយ តាមកាលវិភាគទន់ភ្លន់ដែលរៀបចំដោយគ្រូផ្ទាល់ និងបានការឯកភាពពីគណៈគ្រប់គ្រងសាលា។ **គណៈគ្រប់គ្រងសាលា**សំដៅដល់គណៈគ្រប់គ្រងគ្រឹះស្ថានបឋមសិក្សាសាធារណៈដែលដឹកនាំដោយនាយក ឬនាយិកាសាលា និងមាននាយករង ឬនាយិការងសាលាជាជំនួយ ។

## ២.៣.លក្ខណៈទូទៅនៃប្រជាសាស្ត្ររបស់ខេត្តព្រៃវែង

ខេត្តព្រៃវែងគឺជាខេត្តមួយក្នុងចំណោមរាជធានីខេត្តទាំង២៥ នៃព្រះរាជាណាចក្រកម្ពុជា ហើយជាតំបន់ទំនាបកណ្តាល មានទីតាំងស្ថិតនៅខាងកើតនៃផ្ទៃប្រទេស មានព្រំប្រទល់ខាងជើងជាប់ខេត្តត្បូងឃ្មុំ ខាងកើតជាប់ខេត្តស្វាយរៀង ខាងត្បូងជាប់ប្រទេសវៀតណាម និងខាងលិចជាប់ខេត្តកណ្តាល។ ខេត្តព្រៃវែងមានផ្ទៃដីសរុប ចំនួន ៤៨៨៣ គម$^{២}$ ដែលក្នុងនោះ ៩.១២% ជាផ្ទៃដីដែលប្រជាជនបានតាំងទីលំនៅ, ៦៣.៤៩% ជាដី សម្រាប់កសិកម្ម, ៣.៩៩% ជាផ្ទៃនៃតំបន់ព្រៃឈើ, ២២.១៨% ជាដីសាធារណៈ ហេដ្ឋារចនាសម្ព័ន និង ជារាសាស្ត្រ និងនៅសល់ ១.២៤% ជាដីមិនត្រូវបានប្រើប្រាស់។ ខេត្តព្រៃវែងត្រូវបានបែងចែកជា ក្រុងចំនួន ១ និង ស្រុកចំនួន ១២ ក្នុងនោះរួមមាន ១១៦ ឃុំ និង១១៣៩ភូមិ ៖ មានស្រុកបាភ្នំ ស្រុកកំចាយមារ ស្រុកកំពង់ត្របែក ស្រុកកញ្ជៀច ស្រុកមេសាង ស្រុកពាមជរ ស្រុកពាមរក៍ ស្រុកពារាំង

ស្រុកព្រះស្ដេច ក្រុងព្រៃវែង ស្រុកពោធិ៍រៀង ស្រុកស៊ីធរកណ្ដាល និងស្រុកស្វាយអន្ទរ (Wikipedia, 2020)។ ចំនួនប្រជាជនសរុបគឺ ១,០៥៧,៤២៨នាក់ ដែលក្នុងនោះ ៥០១,៣៤៦នាក់ ជាបុរស និង ៥៥៦,០៨២នាក់ ជាស្ត្រី និងមានដង់ស៊ីតេប្រជាជនជាមធ្យមគឺ ២១៧នាក់ ក្នុងផ្ទៃដីមួយគីឡូម៉ែតការ៉េ (វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ, ២០១៩)។

ផែនទីខេត្តព្រៃវែង (Phumsas, ២០១៦)




ខេត្តព្រៃវែងស្ថិតនៅខាងកើតប្រទេស មានព្រំប្រទល់ខាងជើងជាប់ខេត្តត្បូងឃ្មុំ ខាងកើត ជាប់ខេត្តស្វាយរៀង ខាងត្បូងជាប់ប្រទេសវៀតណាម និងខាងលិចជាប់ខេត្តកណ្ដាល។

## ២.៤.ស្ថានភាពទូទៅបុគ្គលិកអប់រំនៅខេត្តព្រៃវែង

ចំពោះវិស័យអប់រំនៅក្នុងខេត្តព្រៃវែង យោងតាមស្ថិតិអប់រំឆ្នាំសិក្សា២០១៩-២០២០ មន្ទីរអប់រំ យុវជន និងកីឡាមានការិយាល័យជំនាញចំនួន១២ មានបុគ្គលិកចំនួន១១០នាក់ ស្រី៤៣នាក់ មាន ការិយាល័យអប់រំ យុវជន និងកីឡាស្រុក/ក្រុងចំនួន១៣ មានបុគ្គលិកចំនួន១៥៦នាក់ ស្រី៤៧នាក់ មាន សាលារៀនសរុបទូទាំងខេត្តចំនួន១០៥៧ មានគ្រូសរុបចំនួន៧,៩០៧នាក់ ស្រី៣,៣០៩នាក់ មានសិស្ស សរុបចំនួន២៣៦,៨០៩នាក់ ស្រី១១៥ ៧៥៦នាក់ ដែលចែកចេញជា សាលាមត្តេយ្យរដ្ឋចំនួន៣៨៦ កន្លែង ក្នុងនោះសាលាមត្តេយ្យជាប់ដោយឡែកមានចំនួន១២សាលា មានសាលាបឋមសិក្សាចំនួន៥៤៧ សាលា ក្នុងនោះមានសាលាមិនគ្រប់កម្រិតថ្នាក់ចំនួន២៤សាលា មានអនុវិទ្យាល័យចំនួន៩២ មានវិទ្យាល័យចំនួន៣២ និងវិទ្យាល័យឯកជនចំនួន១ ។ សាលាគរុកោសល្យខេត្តមានបុគ្គលិកចំនួន៤៣នាក់ ស្រី២១ នាក់ មានគរុសិស្សចំនួន១៨៧នាក់ ស្រី១១៩នាក់។ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគមានបុគ្គលិកចំនួន ៥០នាក់ ស្រី២៧នាក់ មានគរុសិស្សចំនួន៨៩នាក់ ស្រី៤៦នាក់ ដែលក្នុងនោះគិតរួមទាំងគរុសិស្សខេត្ត ស្វាយរៀងផងដែរ។ ការអប់រំក្រៅប្រព័ន្ធ មានថ្នាក់អក្ខរកម្ម៧៥ថ្នាក់ មានសិស្សចំនួន១,៤៨៤នាក់ ស្រី ១,០៦៥នាក់ មានមជ្ឈមណ្ឌលសិក្សាសហគមន៍១៤កន្លែង មានគ្រូជំនាញ៣៤នាក់ ស្រី២៣ មានសិស្ស ចំនួន៦០២នាក់ ស្រី៤៥០នាក់ មានកម្មវិធីចូលរៀនឡើងវិញដែលមាន៤០ថ្នាក់ មានសិស្សចំនួន៧៨៤ នាក់ ស្រី៤០៧នាក់ មានកម្មវិធីថ្នាក់បំពេញវិជ្ជាមាន២កម្រិតថ្នាក់ទី៩ និងថ្នាក់ទី១២ សិស្សសរុបចំនួន ៣១៣នាក់ ស្រី១៦នាក់ និងមានកម្មវិធីសមមូលបឋមសិក្សាដែលមាន២៤ថ្នាក់ មានសិស្សចូលរៀនសរុប ៤៣៩នាក់ ស្រី២៣៦នាក់ (សុធីរ, ២០២០)។ នៅបឋមសិក្សាមានសាលាចំនួន៥៤៧ មានបុគ្គលិកអប់រំ សរុប៣,៩៥៣នាក់ ស្រី១,៦៦៧នាក់ ដែលក្នុងនោះមានបុគ្គលិកមិនបង្រៀនចំនួន១,២៦២នាក់ ស្រី ៣២៧នាក់ និងបុគ្គលិកបង្រៀនចំនួន២,៦៩១នាក់ ស្រី១,៣៤០នាក់ មានសិស្សសរុបចំនួន១៤៨,២៣០ នាក់ ស្រី៦៩,៤៧០នាក់ (នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ, ២០២០)។

## ២.៥.និយាមប្រើប្រាស់បុគ្គលិកអប់រំនៅបឋមសិក្សា

យោងតាមសេចក្តីណែនាំលេខ ២៥៦ អយក.សណន ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០២ ស្តីពីការកំណត់និយាមប្រើប្រាស់មន្ត្រីរាជការសម្រាប់សាលាមត្តេយ្យ បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា នៅសាលាបឋមសិក្សា ដើម្បីដំណើរការសិក្សា ( បង្រៀន និងរៀនមុខវិជ្ជាទូទៅ ការងារប្រតិបត្តិ ) ការងាររដ្ឋបាល រួមទាំងការងារកុមារ នៅក្នុងសាលារៀននីមួយៗ ការប្រើប្រាស់មន្ត្រីរាជការត្រូវបានកំណត់តាមនិយាមខាងក្រោម ៖

*តារាងទី1៖ និយាមប្រើបុគ្គលិកទីចាត់ការនៅបឋមសិក្សាតាមសេចក្តីណែនាំលេខ២៥៦អយក.សណន*

| សាលាបឋមសិក្សា | តួនាទី | ចំនួន | ភារកិច្ច |
|---|---|---|---|
| ៣ - ៦ ថ្នាក់ | នាយក | ១ | ការងាររដ្ឋបាល +បង្រៀន |
| | គ្រូកាន់ថ្នាក់ | ១ | ជាជំនួយការនាយក បន្ថែមលើការងារបង្រៀន និងការងារកុមារ |
| ៧ - ១០ ថ្នាក់ | នាយក | ១ | ការងាររដ្ឋបាល និងបច្ចេកទេស |
| | នាយករង | ១ | សកម្មភាពប្រតិបត្តិ បង្រៀន +ការងារកុមារ |
| | លេខាធិការ | ១ | (ក្នុងករណីសាលាមិនទាន់មានប្រើប្រព័ន្ធព័ត៌មានវិទ្យា ) |
| ១១ - ២០ ថ្នាក់ | នាយក | ១ | ទទួលបន្ទុករួម និងការងាររដ្ឋបាល |
| | នាយករង | ១ | ការងារបច្ចេកទេស +ការងារប្រតិបត្តិ +ការងារកុមារ |
| | លេខាធិការ | ១ | (ក្នុងករណីសាលាមិនទាន់មានប្រើប្រព័ន្ធព័ត៌មានវិទ្យា ) |
| | បណ្ណារក្ស | ១ | កាន់បណ្ណាល័យ +ជំនួយការនាយក |
| ២១ - ៣០ ថ្នាក់ | នាយក | ១ | ទទួលបន្ទុករួម +ការងាររដ្ឋបាល |
| | នាយករង | ១ | ការងារបច្ចេកទេស +ការងារប្រតិបត្តិ +ការងារកុមារ |
| | លេខាធិការ | ១ | (ក្នុងករណីសាលាមិនទាន់មានប្រើប្រព័ន្ធព័ត៌មានវិទ្យា ) |
| | បណ្ណារក្ស | ១ | កាន់បណ្ណាល័យ +ជំនួយការនាយក |
| ៣១ - ៤០ ថ្នាក់ | នាយក | ១ | ទទួលបន្ទុករួម +ការងាររដ្ឋបាល |
| | នាយករង | ២ | ទទួលបន្ទុកការងារបច្ចេកទេស ការងារប្រតិបត្តិ ការងារកុមារ និងការងារផ្សេងទៀតតាមការបែងចែកពីនាយក |

| | | | |
|---|---|---|---|
| | លេខាធិការ | ១ | (ក្នុងករណីសាលាមិនទាន់មានប្រើប្រព័ន្ធព័ត៌មានវិទ្យា ) |
| | បណ្ណារក្ស | ១ | កាន់បណ្ណាល័យ +ជំនួយការនាយក |
| ៤១ - ៦០ ថ្នាក់ | នាយក | ១ | ទទួលបន្ទុករួម +ការងាររដ្ឋបាល |
| | នាយករង | ៣ | ទទួលបន្ទុកការងារបច្ចេកទេស ការងារប្រតិបត្តិ ការងារកុមារ និងការងារផ្សេងទៀតតាមការបែងចែកពីនាយក |
| | លេខាធិការ | ១ | (ក្នុងករណីសាលាមិនទាន់មានប្រើប្រព័ន្ធព័ត៌មានវិទ្យា ) |
| | បណ្ណារក្ស | ១ | កាន់បណ្ណាល័យ +ជំនួយការនាយក |

បុគ្គលិកបង្រៀន : ១នាក់ /ថ្នាក់ និងផលធៀបសិស្ស/ថ្នាក់ : ៥០ ។ ចាប់ពី ១០ ថ្នាក់ : គ្រូរោងជាង ១ (សម្រាប់សាលារៀន ដែលមានសកម្មភាពរោងជាង ) ។ ចាប់ពី ២០ ថ្នាក់ : គ្រូសិល្បៈ-គេហកិច្ច ១ (សាលារៀនដែលមានតិចថ្នាក់ជាងនេះត្រូវបំប៉នគ្រូប្រចាំថ្នាក់ឱ្យទទួលបន្ទុក ) ។ ពេលចំនួនថ្នាក់លើសពី ១០ ឬ ២០ថ្នាក់ ដូចកំណត់ខាងលើ នាយកមានភារកិច្ចចាត់គ្រូរោងជាង គ្រូសិល្បៈ គេហកិច្ចបន្ថែមតាមការចាំបាច់ជាក់ស្តែង ។ ចំពោះសាលារៀនដែលមានហ្វឹកហាត់កីឡាករប្រមូលផ្តុំសម្រាប់ការប្រកួត នាយកត្រូវរៀបចំអនុវត្តក្រៅម៉ោងសិក្សា និងចាត់មន្ត្រីដែលមានជំនាញ ឬអ្នកស្ម័គ្រចិត្តឱ្យទទួលបន្ទុកសម្រាប់រយៈពេលហ្វឹកហាត់ និងប្រកួត ។

ដើម្បីឱ្យប្រសើរឡើងលើការងារគ្រប់គ្រង និងការបែងចែកភារកិច្ច ជូនបុគ្គលិកអប់រំដែលកំពុងបម្រើការងារនៅតាមអង្គភាពរដ្ឋបាល និងនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងដើម្បីផ្តល់សេវាអប់រំប្រកបដោយប្រកបដោយគុណភាពស្របទៅនឹងបរិបទនៃការអប់រំបច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា បានពិនិត្យកែសម្រួលឡើងវិញ យោងសេចក្តីណែនាំលេខ២០អយក.សណន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ ២០១៨ ស្តីពីនិយាមប្រើបុគ្គលិកអប់រំ និងដាក់ឱ្យអនុវត្តចាប់ពីឆ្នាំសិក្សា២០១៨-២០១៩តទៅ ៖

ការកំណត់ប្រភេទគ្រឹះស្ថានសិក្សាសាធារណៈនៅបឋមសិក្សាត្រូវបានចែកជា៣ប្រភេទរួមមាន៖ សាលាតូច សាលាមធ្យម និងសាលាធំ ។ សាលាតូចជាសាលាដែលមានតិចជាងឬស្មើ២០ថ្នាក់ សាលាមធ្យមជាសាលាដែលមានថ្នាក់ចាប់ពី២១ដល់៤០ថ្នាក់ និងសាលាធំជាសាលាដែលមានចាប់ពី៤១ថ្នាក់

ឡើងទៅ។ ចំពោះការកំណត់ម៉ោងបំពេញភារកិច្ចរបស់បុគ្គលិកអប់រំបឋមសិក្សា ចំនួនម៉ោងបង្រៀនក្នុងថ្នាក់ក្នុងមួយសប្តាហ៍មាន២៥ម៉ោង និងចំនួនម៉ោងដែលត្រូវបំពេញការងារគាំទ្រដល់ការបង្រៀនឱ្យគ្រប់៤០ម៉ោងក្នុងមួយសប្តាហ៍មានចំនួន១៥ម៉ោង។ ក្នុងនោះម៉ោងបង្រៀនសិស្សសុទ្ធសាធចំនួន២៥ម៉ោង ម៉ោងបំពេញការងារគាំទ្រការបង្រៀនចំនួន១២ម៉ោង ម៉ោងបំពេញការងាររបស់គ្រូទទួលបន្ទុកថ្នាក់ចំនួន២ម៉ោង និងម៉ោងបំពេញការងាររបស់ប្រធានក្រុមបច្ចេកទេសចំនួន១ម៉ោង ។

*តារាងទី2៖ និយាមប្រើបុគ្គលិកអប់រំទីចាត់ការនៅបឋមសិក្សាតាមសេចក្តីណែនាំលេខ២០អយក.សណន*

| តួនាទី និងភារកិច្ច | សាលាតូច តិចជាងឬស្មើ២០ថ្នាក់ | | | សាលាមធ្យម ពី២១ដល់៤០ថ្នាក់ | | សាលាធំ ចាប់ពី៤១ថ្នាក់ឡើង | |
|---|---|---|---|---|---|---|---|
| | ៦ | ៧-១០ | ១១-២០ | ២១-៣០ | ៣១-៤០ | ៤១-៦០ | ៦០-៨០+ |
| នាយក | ១ | ១ | ១ | ១ | ១ | ១ | ១ |
| នាយករង | | ១ | ១ | ១ | ១ | ២ | ៣ |
| លេខាធិការ | | ១ | ១ | ១ | ១ | ១ | ២ |
| បណ្ណារក្ស(មានបណ្ណាល័យ) | ១ | ១ | ១ | ២ | ២ | ៣ | ៣ |
| គ្រូរោងជាង(បើសាលាមានសកម្មភាពរោងជាង) | | | ១ | ១ | ១ | ១ | ១ |
| បុគ្គលិក ឬឆ្មាំ | | | | | | ១ | ១ |
| សរុប | ២ | ៤ | ៥ | ៦ | ៧ | ៩ | ១១ |

*តារាងទី3៖ និយាមប្រើបុគ្គលិកបង្រៀននៅបឋមសិក្សាតាមសេចក្តីណែនាំលេខ២០អយក.សណន*

| គ្រឹះស្ថានសិក្សាសាធារណៈ | និយាមប្រើចំនួនគ្រូ-សិស្ស | |
|---|---|---|
| | និយាមថ្នាក់-គ្រូបង្រៀន | ផលធៀប សិស្ស-ថ្នាក់ |
| បឋមសិក្សា | ១ / ១.១៥ | ទី១-៣ = ៣៥ - ៤៥<br>ទី៤-៦ = ៤០ - ៥០ |

**កំណត់សម្គាល់៖** ចំពោះរាជធានី/ខេត្តដែលអនុវត្តសេចក្តីណែនាំលេខ ២០ អយក.សណន នេះ ហើយធ្វើឱ្យប៉ះពាល់ដល់ការខ្វះគ្រូបង្រៀនត្រូវបន្តអនុវត្តតាមសេចក្តីណែនាំលេខ ២៥៦ អយក.សណន ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ២០០២ ស្តីពីការកំណត់និយាមប្រើប្រាស់ មន្ត្រីរាជការសម្រាប់មត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងសាលាគរុកោសល្យ។ សាលាមត្តេយ្យសិក្សា និងបឋមសិក្សា គ្រប់កម្រិតដែលមាន៦ថ្នាក់ និងមានសិស្សសរុបចាប់ពី ២១០នាក់ឡើង នាយកមិនបង្រៀន។ សាលាមត្តេយ្យសិក្សា និងបឋមសិក្សា គ្រប់កម្រិតដែលមាន៦ថ្នាក់ និងមានសិស្សសរុបចាប់ពី ២១០នាក់ឡើង នាយកមិនបង្រៀន។ នាយកសាលាមានសេវាបង្រៀន ចំពោះសាលាតូច តិចជាងឬស្មើ៣ថ្នាក់ (សេចក្តីណែនាំលេខ ៥៣អយក.សណន, ២០១៩)។

## ២.៦.ប្រសិទ្ធភាពនៃការប្រើប្រាស់គ្រូបង្រៀន

យោងតាមអនុក្រឹត្យលេខ៣០៩អនក្រ.បក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាលស្តីពីការរៀបចំការគ្រប់គ្រង និងការចាត់ចែងសេវាបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈក្នុងគោលបំណងធានាឱ្យមាននិរន្តរភាព មានប្រសិទ្ធភាព និងមានគោលដៅដើម្បី ៖ កំណត់នូវភារកិច្ចកំណត់របស់មន្ត្រីរាជការសម្រាប់ការងាររដ្ឋបាលនិងការងារបង្រៀននៅគ្រឹះស្ថានបឋមសិក្សាសាធារណៈ កំណត់នូវបែបបទ និងនីតិវិធីនៃការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា ដើម្បីបំពេញបន្ថែមលើសេវាបង្រៀននៅគ្រឹះស្ថានបឋមសិក្សាសាធារណៈដែលជួបការខ្វះគ្រូបង្រៀនជាមន្ត្រីរាជការ កំណត់នូវភារកិច្ចបន្ថែមនិងភារកិច្ចថ្នាក់គួបសម្រាប់មន្ត្រីរាជការ ដែលបានអនុវត្តដោយពេញលេញភារកិច្ចកំណត់របស់ខ្លួនរួចហើយ កំណត់នូវប្រាក់កម្រៃសម្រាប់គ្រូបង្រៀនជាប់កិច្ចសន្យា និងមន្ត្រីរាជការដែលបានអនុវត្តភារកិច្ចបន្ថែម និងភារកិច្ចថ្នាក់គួប កំណត់នូវការគ្រប់គ្រង ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការងារបង្រៀនតាមកិច្ចសន្យា និងការអនុវត្តភារកិច្ចកំណត់ ភារកិច្ចបន្ថែម និងភារកិច្ចថ្នាក់គួប។

### ២.៦.១.ភារកិច្ចកំណត់របស់មន្ត្រីរាជការសម្រាប់ការងាររដ្ឋបាល និងការងារបង្រៀន

មន្ត្រីរាជការដែលបម្រើការងារនៅតាមគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវអនុវត្តកាតព្វកិច្ចការងាររយៈពេល៨(ប្រាំបី)ម៉ោងក្នុងមួយថ្ងៃ និងប្រាំថ្ងៃក្នុងមួយសប្តាហ៍ ឬ រយៈពេល៤០(សែសិប) ម៉ោង

ក្នុងមួយសប្តាហ៍ ផ្អែកលើការចាត់ចែងរបស់គណៈគ្រប់គ្រងសាលា អនុលោមតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយត្រូវធានាឱ្យបាននូវនិរន្តរភាពនិងប្រសិទ្ធភាពទាំងការងាររដ្ឋបាល ទាំងការងារបង្រៀន។ មន្ត្រីរាជការជាគ្រូបង្រៀនដែលទទួលបន្ទុកការងារបង្រៀន មានភារកិច្ចកំណត់ដូចជា៖ ផ្តល់ការបង្រៀនជាក់ស្តែង និងពិតប្រាកដដល់សិស្សនៅតាមថ្នាក់ និងកម្រិតសិក្សា ព្រមទាំងបំពេញការងារពាក់ព័ន្ធគ្រប់យ៉ាងសម្រាប់ថ្នាក់រៀនដែលខ្លួនទទួលបន្ទុក។

ចំពោះរយៈពេលនៃការអនុវត្តភារកិច្ចកំណត់របស់មន្ត្រីរាជការជាគ្រូបង្រៀនដែលទទួលបន្ទុកការងារបង្រៀន ត្រូវបានកំណត់ដូចតទៅ៖ សម្រាប់ថ្នាក់ទី១ ទី២ និងទី៣ គ្រូបង្រៀនម្នាក់ទទួលខុសត្រូវគ្រប់ផ្នែកបង្រៀនសិស្សមួយថ្នាក់ក្នុងវេះវេលាមួយ ពេលនៃកាលវិភាគប្រចាំថ្ងៃនៅក្នុងគ្រឹះស្ថានសិក្សា គឺមួយថ្ងៃបង្រៀន៥(ប្រាំ) ម៉ោងសិក្សា និង ៥(ប្រាំ)ថ្ងៃក្នុងមួយសប្តាហ៍ ឬ បង្រៀន២៥(ម្ភៃប្រាំ)ម៉ោងសិក្សាក្នុងមួយសប្តាហ៍ នៅពេលព្រឹក ឬ នៅពេលរសៀល។ ក្រៅពីរយៈពេលដែលត្រូវបំពេញសម្រាប់ការបង្រៀន គ្រូបង្រៀន ត្រូវបំពេញការងារពាក់ព័ន្ធសម្រាប់ថ្នាក់រៀនដែលខ្លួនទទួលបន្ទុកក្នុងក្របខណ្ឌនៃរយៈពេលដែលបានកំណត់ខាងលើ។ សម្រាប់ថ្នាក់ទី៤ ទី៥ និងទី៦៖ គ្រូបង្រៀនម្នាក់ទទួលខុសត្រូវគ្រប់ផ្នែកបង្រៀនសិស្សមួយថ្នាក់ក្នុងវេះវេលាមួយពេលនៃកាលវិភាគប្រចាំថ្ងៃនៅក្នុងគ្រឹះស្ថានសិក្សា គឺមួយថ្ងៃបង្រៀន ៥(ប្រាំ)ម៉ោង កន្លះសិក្សានិង៥(ប្រាំ)ថ្ងៃក្នុងមួយសប្តាហ៍ ឬ បង្រៀន២៧(ម្ភៃប្រាំពីរ)ម៉ោងកន្លះសិក្សាក្នុងមួយសប្តាហ៍ នៅពេលព្រឹក ឬ នៅពេលរសៀល។ ក្រៅពីរយៈពេលដែលត្រូវបំពេញសម្រាប់ការបង្រៀន គ្រូបង្រៀន ត្រូវបំពេញការងារពាក់ព័ន្ធសម្រាប់ថ្នាក់រៀនដែលខ្លួនទទួលបន្ទុកក្នុងក្របខណ្ឌនៃរយៈពេលដែលបានកំណត់។

### ២.៦.២.បែបបទ និងនីតិវិធីនៃការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា

ការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា ត្រូវអនុវត្តក្នុងករណីគ្រឹះស្ថានបឋមសិក្សាសាធារណៈ ខ្វះមន្ត្រីរាជការជាគ្រូបង្រៀន ដើម្បីបំពេញការងារបង្រៀនស្របតាមនិយាមកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា។ ការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា ត្រូវបានផ្តល់ជាអាទិភាពសម្រាប់បំពេញការងារបង្រៀន ដើម្បីជំនួសការងារបង្រៀនតាមរយៈការអនុវត្តភារកិច្ចបន្ថែមនិងភារកិច្ចថ្នាក់គួប។ គ្រូបង្រៀន

ជាប់កិច្ចសន្យា ត្រូវបំពេញភារកិច្ចដូចគ្រូបង្រៀនកម្រិតបឋមដែលមានក្របខណ្ឌអនុលោម ភារកិច្ចកំណត់ និងទទួលប្រាក់កម្រៃដូចមានកំណត់ដោយច្បាប់ ប៉ុន្តែពុំមានបុព្វសិទ្ធិដូចមន្ត្រីរាជការជាគ្រូបង្រៀនទេ។

គណៈគ្រប់គ្រងសាលា ត្រូវរៀបចំផែនការប្រើប្រាស់មន្ត្រីរាជការ និងគ្រូបង្រៀនជាប់កិច្ចសន្យាប្រចាំឆ្នាំរបស់គ្រឹះស្ថានបឋមសិក្សាសាធារណៈ ដោយពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំសង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយដាក់សំណើផែនការនេះមកក្រសួងអប់រំ យុវជន និងកីឡា តាមរយៈការិយាល័យ អប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។ មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត ត្រូវពិគ្រោះយោបល់ជាមួយមន្ទីរមុខងារសាធារណៈរាជធានីខេត្ត មុននឹងដាក់សំណើផែនការនេះទៅក្រសួងអប់រំ យុវជន និងកីឡា។ ផែនការប្រើប្រាស់មន្ត្រីរាជការ និងគ្រូបង្រៀនជាប់កិច្ចសន្យាប្រចាំឆ្នាំ ត្រូវពិនិត្យ និងអនុម័តក្នុងថវិកាប្រចាំឆ្នាំនីមួយៗរបស់រាជរដ្ឋាភិបាល។ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំសេចក្តីណែនាំអំពីបែបបទនិងនីតិវិធីនៃការរៀបចំផែនការប្រើប្រាស់មន្ត្រីរាជការ និងគ្រូបង្រៀនជាប់កិច្ចសន្យានៅតាមគ្រឹះស្ថានបឋមសិក្សាសាធារណៈ។

ការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា ត្រូវជ្រើសរើសចេញពី៖ សិស្ស និស្សិតដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឡើងទៅ ឬ បានរៀនចប់ថ្នាក់ទី១២ និងដែលមានអាយុចន្លោះពី១៨(ដប់ប្រាំបី)ឆ្នាំ ដល់ ៣៥(សាមសិបប្រាំ)ឆ្នាំ ។ ជ្រើសរើសពីគ្រូបង្រៀនគ្រប់ប្រភេទក្របខ័ណ្ឌដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍។ ការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា ត្រូវបានផ្តល់អាទិភាពដល់បេក្ខជនដែលកំពុងរស់នៅក្នុងមូលដ្ឋានដែលខ្វះគ្រូបង្រៀន ជនពិការនិងស្រី។ គ្រូបង្រៀនជាប់កិច្ចសន្យាដែលត្រូវបានជ្រើសរើសថ្មី ត្រូវទទួលការបំប៉នរយៈពេលខ្លីដែលរៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡាលើផ្នែកគរុកោសល្យ និងការងាររដ្ឋបាល។ ក្នុងករណីក្រសួងអប់រំ យុវជន និងកីឡា មានសេចក្តីត្រូវការជ្រើសរើសមន្ត្រីរាជការក្របខ័ណ្ឌគ្រូបង្រៀនកម្រិតបឋម ក្រសួងត្រូវធ្វើការប្រឡងជ្រើសរើសដោយផ្តល់អាទិភាពជាចម្បងដល់គ្រូបង្រៀនជាប់កិច្ចសន្យាដែលបានបំពេញលក្ខខណ្ឌដូចជា៖ សិស្ស និស្សិត ដែលត្រូវបានជ្រើសរើស និងបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈណាមួយរយៈពេលយ៉ាងហោច៣(បី)ឆ្នាំជាប់ៗគ្នា បន្ទាប់ពីអនុក្រឹត្យលេខ៣០៩អនក្រ.បកចូលជាធរមាន និងកំពុងបង្រៀននៅទីតាំងគ្រឹះស្ថានបឋមសិក្សាសាធារ

ណៈដែលខ្វះគ្រូបង្រៀន។ ការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា ត្រូវអនុវត្តដោយគណៈកម្មការដែលដឹកនាំដោយមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត និងមានការចូលរួមពីតំណាងមន្ទីរមុខងារសាធារណៈរាជធានីខេត្ត។ គ្រូបង្រៀនជាប់កិច្ចសន្យា ត្រូវប្រកាសទទួលស្គាល់ដោយសេចក្តីសម្រេចរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត បន្ទាប់ពីទទួលបានទិដ្ឋាការពីមន្ទីរមុខងារសាធារណៈរាជធានីខេត្តពាក់ព័ន្ធ។ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំសេចក្តីណែនាំអំពីបែបបទ និងនីតិវិធីនៃការជ្រើសរើស និងការគ្រប់គ្រងគ្រូបង្រៀនជាប់កិច្ចសន្យា ។

### ២.៦.៣.ភារកិច្ចបន្ថែម និងភារកិច្ចថ្នាក់គួបសម្រាប់មន្ត្រីរាជការ

ភារកិច្ចបន្ថែម ត្រូវបានអនុញ្ញាត និងអនុវត្តចំពោះគ្រឹះស្ថានបឋមសិក្សាសាធារណៈដែលចំនួនមន្ត្រីរាជការជាគ្រូបង្រៀនមិនឆ្លើយតបនឹងនិយាមផលធៀបសិស្សថ្នាក់ក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។ ភារកិច្ចបន្ថែមត្រូវបានប្រគល់បន្ថែមឱ្យមន្ត្រីរាជការជាគ្រូបង្រៀនម្នាក់ក្នុងលក្ខខណ្ឌដូចជា៖ គ្រូបង្រៀននោះបានបំពេញភារកិច្ចកំណត់ពេញលេញ ផ្អែកលើចំនួនម៉ោងសម្រាប់ថ្នាក់ក្នុងកម្រិតនីមួយៗដូចមានចែងដោយច្បាប់ ក្នុងលក្ខខណ្ឌសេចក្តីត្រូវការនៃការ ផ្តល់សេវាបង្រៀនឱ្យមាននិរន្តរភាព និងការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាមិនអាចអនុវត្តបាន។ ភារកិច្ចបន្ថែម ត្រូវបានប្រគល់បន្ថែមឱ្យមន្ត្រីរាជការបំពេញការងាររដ្ឋបាលថ្នាក់ក្នុងលក្ខខណ្ឌដូចជា៖ មន្ត្រីរាជការបំពេញការងាររដ្ឋបាលនោះ បានបំពេញភារកិច្ចកំណត់ពេញលេញផ្អែកលើចំនួនម៉ោងកំណត់ដូចមានចែងដោយច្បាប់ ក្នុងលក្ខខណ្ឌសេចក្តីត្រូវការនៃការផ្តល់សេវាបង្រៀនឱ្យមាននិរន្តរភាព និងការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យានិងមន្ត្រីរាជការជាគ្រូបង្រៀនមិនអាចអនុវត្តបាន។ មន្ត្រីរាជការដែលទទួលភារកិច្ចបន្ថែមត្រូវបំពេញភារកិច្ចកំណត់របស់ខ្លួនឱ្យបានពេញលេញ បំពេញភារកិច្ចបន្ថែម និងធ្វើការរដ្ឋបាលគ្រប់យ៉ាងសម្រាប់ថ្នាក់រៀន ប្រើពេលបង្រៀនសិស្សតាមកាលវិភាគច្រើនជាងលើសមន្ត្រីរាជការបំពេញការងារបង្រៀនដែលបំពេញភារកិច្ចកំណត់ទូទៅដែលបង្រៀនតែមួយថ្នាក់ ឬ លើសមន្ត្រីរាជការបំពេញការងាររដ្ឋបាលដែលបំពេញភារកិច្ចកំណត់ទូទៅ ។

ភារកិច្ចថ្នាក់គួប ត្រូវបានអនុវត្តក្នុងលក្ខខណ្ឌដូចតទៅ៖ ការខ្វះបន្ទប់រៀនសម្រាប់ជានាសេវាបង្រៀនដល់សិស្សនៅកម្រិតថ្នាក់ណាមួយ ឬ ការខ្វះគ្រូបង្រៀនសម្រាប់សិស្សនៅកម្រិតថ្នាក់ណាមួយ ហើយការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាមិនអាចអនុវត្តបាន ឬ ការខ្វះបន្ទប់រៀន និងចំនួនសិស្សមិនគ្រប់តាមនិយាមកំណត់ដោយក្រសួងអប់រំ យុវជន និង កីឡាសម្រាប់បង្កើតថ្នាក់រៀនមួយថ្នាក់ដោយឡែក ឬ ការខ្វះគ្រូបង្រៀន និងចំនួនសិស្សមិនគ្រប់តាមនិយាមកំណត់ដោយក្រសួងអប់រំ យុវជន និង កីឡា ឬ គ្រឹះស្ថានបឋមសិក្សាសាធារណៈនោះមិនគ្រប់កម្រិត។ ភារកិច្ចថ្នាក់គួបត្រូវបានប្រគល់ឱ្យមន្ត្រីរាជការជាគ្រូបង្រៀនម្នាក់ក្នុងលក្ខខណ្ឌដូចជា៖ គ្រូបង្រៀននោះបានបំពេញកាតព្វកិច្ចបង្រៀនផ្អែកតាមចំនួនម៉ោងបង្រៀនកំណត់សម្រាប់ថ្នាក់ក្នុងកម្រិតនីមួយៗ ដូចមានចែងដោយច្បាប់ ក្នុងលក្ខខណ្ឌសេចក្តីត្រូវការនៃការផ្តល់សេវាបង្រៀនឱ្យមាននិរន្តរភាព និងការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាមិនអាចអនុវត្តបាន។ ភារកិច្ចថ្នាក់គួប ត្រូវបានប្រគល់ឱ្យមន្ត្រីរាជការបំពេញការងាររដ្ឋបាលថ្នាក់ក្នុងលក្ខខណ្ឌដូចជា៖ មន្ត្រីរាជការបានបំពេញភារកិច្ចកំណត់ពេញលេញ ផ្អែកលើចំនួនម៉ោងកំណត់ដូចមានចែងដោយច្បាប់ ក្នុងលក្ខខណ្ឌសេចក្តីត្រូវការនៃការផ្តល់សេវាបង្រៀនឱ្យមាននិរន្តរភាព និងការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា និងមន្ត្រីរាជការជាគ្រូបង្រៀនមិនអាចអនុវត្តបាន។ មន្ត្រីរាជការដែលទទួលភារកិច្ចថ្នាក់គួបត្រូវបំពេញភារកិច្ចកំណត់របស់ខ្លួនឱ្យបានពេញលេញ បំពេញភារកិច្ចថ្នាក់គួប និងធ្វើការរដ្ឋបាលគ្រប់យ៉ាងសម្រាប់ថ្នាក់រៀន ប្រើពេលបង្រៀនសិស្សតាមកាលវិភាគច្រើនជាង លើសមន្ត្រីរាជការបំពេញការងារបង្រៀនដែលបំពេញភារកិច្ចកំណត់ទូទៅដែលបង្រៀនតែមួយថ្នាក់ ឬ លើសមន្ត្រីរាជការបំពេញការងាររដ្ឋបាលដែលបំពេញភារកិច្ចកំណត់ទូទៅ។

### ២.៦.៤.ប្រាក់កម្រៃសម្រាប់គ្រូបង្រៀនជាប់កិច្ចសន្យា និងមន្ត្រីរាជការដែលបានអនុវត្តភារកិច្ចបន្ថែមនិងភារកិច្ចថ្នាក់គួប

គ្រូបង្រៀនជាប់កិច្ចសន្យា ដែលត្រូវបានជ្រើសរើសសម្រាប់ការបង្រៀននៅគ្រឹះស្ថានបឋមសិក្សាសាធារណៈ ផ្អែកលើបទបញ្ញត្តិនៃច្បាប់ត្រូវបានផ្តល់ប្រាក់កម្រៃប្រចាំខែចាប់ពីពេលដែលបានចាប់ផ្តើមរហូតដល់ពេលដែលសាមីខ្លួនបានបញ្ចប់ភារកិច្ច ដូចតទៅ៖ ស្មើនឹង ៨០%(ប៉ែតសិបភាគរយ) នៃបៀវត្ស

សរុបប្រចាំខែនៃបៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារអប់រំរបស់មន្ត្រីរាជការជាគ្រូបង្រៀនកម្រិតបឋមដែលទើបត្រូវបានជ្រើសរើសថ្មី ចំពោះគ្រូបង្រៀនជាប់កិច្ចសន្យាដែលបានជ្រើសរើសពីសិស្ស និស្សិត។ ទទួលបានស្មើនឹង ៩០%(កៅសិបភាគរយ) នៃបៀវត្សសរុបប្រចាំខែនៃបៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារអប់រំរបស់មន្ត្រីរាជការជាគ្រូបង្រៀនកម្រិតបឋមដែលទើបត្រូវបានជ្រើសរើសថ្មី ចំពោះគ្រូបង្រៀនជាប់កិច្ចសន្យាដែលបានជ្រើសរើសពីគ្រូបង្រៀនចូលនិវត្តន៍គ្រប់ប្រភេទក្របខណ្ឌ។

មន្ត្រីរាជការជាគ្រូបង្រៀន ឬ មន្ត្រីរាជការដែលបំពេញការងាររដ្ឋបាលនៅគ្រប់ប្រភេទក្របខណ្ឌដែលត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចបន្ថែមក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវបានផ្តល់ប្រាក់កម្រៃភារកិច្ចបន្ថែមប្រចាំខែ ស្មើនឹងបៀវត្សសរុបប្រចាំខែនៃបៀវត្សមូលដ្ឋាននិងប្រាក់បំណាច់មុខងារអប់រំរបស់មន្ត្រីរាជការជាគ្រូបង្រៀនកម្រិតបឋមដែលទើបត្រូវបានជ្រើសរើសថ្មី ចាប់ពីពេលដែលបានចាប់ផ្តើមរហូតដល់ពេលដែលសាមីខ្លួនបានបញ្ចប់ភារកិច្ច។ មន្ត្រីរាជការជាគ្រូបង្រៀន ឬ មន្ត្រីរាជការដែលបំពេញការងាររដ្ឋបាលនៅគ្រប់ប្រភេទក្របខ័ណ្ឌដែល ត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចថ្នាក់គួបក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈត្រូវបានផ្តល់ប្រាក់កម្រៃភារកិច្ចថ្នាក់គួបប្រចាំខែ ចាប់ពីពេលដែលបានចាប់ផ្តើមរហូតដល់ពេលដែលសាមីខ្លួនបានបញ្ចប់ភារកិច្ចដូចតទៅ៖ ស្មើនឹង ៦០%(ហុកសិបភាគរយ) នៃបៀវត្សសរុបប្រចាំខែនៃបៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារអប់រំរបស់មន្ត្រីរាជការជាគ្រូបង្រៀនកម្រិតបឋមដែលទើបត្រូវបានជ្រើសរើសថ្មីចំពោះថ្នាក់គួបដែលមានពីរកម្រិត។ ទទួលបានស្មើនឹង ៨០%(ប៉ែតសិបភាគរយ) នៃបៀវត្សសរុបប្រចាំខែនៃបៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារអប់រំរបស់មន្ត្រីរាជការជាគ្រូបង្រៀនកម្រិតបឋមដែលទើបត្រូវបានជ្រើសរើសថ្មីចំពោះថ្នាក់គួបដែលមានបីកម្រិត។

ប្រាក់កម្រៃដែលត្រូវផ្តល់ឱ្យគ្រូបង្រៀនជាប់កិច្ចសន្យា មន្ត្រីរាជការដែលអនុវត្តភារកិច្ចបន្ថែម និងមន្ត្រីរាជការដែលអនុវត្តភារកិច្ចថ្នាក់គួប ត្រូវអនុវត្តតាមតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងដោយក្រសួងមុខងារសាធារណៈ។

### ២.៦.៥.ការគ្រប់គ្រង ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការងារបង្រៀន តាមកិច្ចសន្យា និងការអនុវត្តភារកិច្ចកំណត់ ភារកិច្ចបន្ថែម និងភារកិច្ចថ្នាក់គួប

គណៈគ្រប់គ្រងសាលា ត្រូវពិនិត្យ គ្រប់គ្រង និងចាត់ចែងសេវាបង្រៀនឱ្យមានប្រសិទ្ធភាពក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈរបស់ខ្លួន ផ្អែកលើភារកិច្ចកំណត់ ភារកិច្ចបន្ថែម ភារកិច្ចថ្នាក់គួប និងការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា អនុលោមនិយាមកំណត់ដែលកំណត់ដោយច្បាប់ និងនិយាមស្ដីពីការប្រើប្រាស់បុគ្គលិកអប់រំកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។ ការស្នើជ្រើសរើស និងចាត់តាំងគ្រូបង្រៀនជាប់កិច្ចសន្យា និងមន្ត្រីរាជការឱ្យអនុវត្តភារកិច្ចបន្ថែម ឬ ភារកិច្ចថ្នាក់គួប ត្រូវពិនិត្យនិងរៀបចំដោយគណៈគ្រប់គ្រងសាលា។ នាយកឬនាយិកាសាលាក្នុងនាមគណៈគ្រប់គ្រងសាលាត្រូវលើកសំណើអំពីការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា ឬ មន្ត្រីរាជការឱ្យអនុវត្តភារកិច្ចបន្ថែមឬភារកិច្ចថ្នាក់គួបមកមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត ដើម្បីពិនិត្យ និងសម្រេចតាមរយៈការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុកខណ្ឌ ផ្អែកលើផែនការប្រចាំឆ្នាំដែលទទួលការអនុម័តក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរួចហើយ។ គណៈគ្រប់គ្រងសាលាត្រូវគ្រប់គ្រង និងចាត់ចែងការងារ ព្រមទាំងត្រូវមានគណនេយ្យភាព និងការទទួលខុសត្រូវដោយផ្ទាល់ក្នុងការធានានូវប្រសិទ្ធភាពនៃការអនុវត្តភារកិច្ចកំណត់ ភារកិច្ចបន្ថែម ភារកិច្ចថ្នាក់គួប ការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា និងការបើកផ្តល់ប្រាក់កម្រៃនៅក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន។

ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុកខណ្ឌ និងប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត ត្រូវមានគណនេយ្យភាព និងការទទួលខុសត្រូវក្នុងការត្រួតពិនិត្យនិងណែនាំការបំពេញការងាររបស់គណៈគ្រប់គ្រងសាលាក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើការត្រួតពិនិត្យ និងវាយតម្លៃអំពីស្ថានភាពនៃការគ្រប់គ្រង និងការចាត់ចែងការបង្រៀននៅគ្រឹះស្ថានបឋមសិក្សាសាធារណៈ នៅរៀងរាល់ដំណាច់ឆ្នាំសិក្សានីមួយៗ ឬផ្អែកលើភាពចាំបាច់នៃការងារក្នុងគោលដៅបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការប្រើប្រាស់ធនធានមនុស្សគាំទ្រដល់សេវាបង្រៀន។

ក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានមនុស្សឱ្យមានប្រសិទ្ធភាព ចំណាយតិច ចំណេញច្រើន គ្រប់អង្គភាពរដ្ឋបាលទាំងអស់ និងគ្រឹះស្ថានសិក្សាត្រូវកំណត់និយាមប្រើប្រាស់ឱ្យបានជាក់លាក់ ។ ការអនុវត្តតាមនិយាមផ្តល់នូវសារៈសំខាន់ដូចជា៖ មានភាពច្បាស់លាស់ក្នុងការគ្រប់គ្រងបុគ្គលិកអប់រំ ងាយស្រួលក្នុងការធ្វើផែនការតម្រូវការបុគ្គលិកអប់រំប្រចាំឆ្នាំ តាមមុខវិជ្ជាឯកទេស និងកម្រិតថ្នាក់ បុគ្គលិកអប់រំម្នាក់ៗបានបំពេញមុខងារតាមការកំណត់ មានមូលដ្ឋានជាក់លាក់ក្នុងការវាយតម្លៃគុណផល និងការទប់ស្កាត់លំហូរចូលបុគ្គលិកអប់រំថ្មី បង្ហាញពីភាពច្បាស់លាស់ និងហ្មត់ចត់របស់គណៈគ្រប់គ្រងសាលារៀន/អង្គភាព (សុផន, ២០២០)។ ធនធានមនុស្សជាកត្តាកំណត់សម្រាប់ធ្វើឱ្យសាលារៀនមានការអភិវឌ្ឍ ឬធ្វើឱ្យសាលាជួបបញ្ហាលំបាកមិនរីកចម្រើន។ ជារៀងរាល់ឆ្នាំនាយកសាលាត្រូវពិនិត្យពិចារណាលើចំនួនបុគ្គលិក ពិសេសគ្រូបង្រៀន ដោយប្រៀបធៀបនឹងតម្រូវការជាក់ស្តែង (គណៈកម្មការ"PAP", ២០០០)។ បើមិនគ្រប់គ្រាន់ត្រូវស្នើសុំបន្ថែម បើច្រើនពេក លើសតម្រូវការស្នើសុំដកចេញ ពោលគឺត្រូវធ្វើសនិទានកម្មបុគ្គលិកគ្រូបង្រៀនឱ្យបានសមស្រប និងប្រើប្រាស់ឱ្យអស់លទ្ធភាព។ នាយកសាលាត្រូវចាត់តាំង ប្រើប្រាស់បុគ្គលិកឱ្យបានសមស្របតាមចំណេះដឹង តាមសមត្ថភាព និងទៅតាមសំណូមពរសាមីខ្លួនផងដែរ។ ចំពោះគ្រូបង្រៀនត្រូវចាត់តាំងឱ្យបង្រៀនតាមថ្នាក់ តាមភូមិសិក្សាដោយពិនិត្យ ពិចារណាលើបទពិសោធន៍ លើចំណេះដឹង និងសំណូមពរសាមីខ្លួនផង។ ក្នុងការប្រើប្រាស់បុគ្គលិក គ្រូបង្រៀន នាយកសាលាត្រូវគិតគូរជានិច្ចលើការថែបំប៉នផ្នែកបច្ចេកទេស មុខជំនាញវិជ្ជាជីវៈជាប្រចាំតាមរយៈការបើកវគ្គបំប៉ន ឬសិក្ខាសាលាបំប៉នតាមក្រុមបច្ចេកទេសរៀងរាល់ថ្ងៃព្រហស្បតិ៍ និងប្រជុំផ្សព្វផ្សាយបច្ចេកទេសថ្មី ។ល។ការបំប៉នសុខភាព និងជីវភាព៖នាយកសាលាត្រូវគិតគូរជាប្រចាំដល់សុខទុក្ខរបស់អ្នកក្រោមឱវាទ។ ដោយប្រើប្រាស់គ្រប់រូបភាពតាមលទ្ធភាពដែលមាន ជំរុញរៀបចំបៀវត្សឱ្យបានទាន់ពេលវេលា បំផុសការកសាងសេដ្ឋកិច្ចគ្រួសារ...។ ធ្វើជាអាជ្ញាកណ្តាលផ្សះផ្សារទំនាស់ផ្សេងៗដែលកើតមានក្នុងសាលារៀន។ នាយកសាលាត្រូវតែជាមនុស្ស អព្យាក្រឹត មិននិយមបក្សពួក (មានក្រៅមានក្នុង ) ស្រឡាញ់មួយស្អប់មួយពោលគឺមនុស្សមានយុត្តិធម៌ ពុំមានអគតិក្នុងខ្លួន។ ពេលមានទំនាស់កើតឡើងទោះធំក្តី តូចក្តី នាយកត្រូវចេញមុខដោះស្រាយដោយឈរលើគោលការណ៍បង្រួបបង្រួមក្នុងឋានៈជាអ្នកគ្រប់គ្រងមានគុណធម៌

ល្អ ដើម្បីដោះស្រាយវិបត្តិកុំឱ្យរាលដាលវែងឆ្ងាយ។ នាយកសាលាត្រូវធ្វើអធិការកិច្ចតាមថ្នាក់ ដើម្បីជួយកែលម្អគ្រូបង្រៀនពិសេសគ្រូបង្រៀនដែលទើបចេញថ្មី ដើម្បីធ្វើការវាយតម្លៃតែងតាំងស៊ប់ក្នុងក្របខណ្ឌ ឬតំឡើងកាំប្រាក់តាមផែនការ និងតាមស្ថានភាពជាក់ស្តែង ។

## ២.៧.បញ្ហាប្រឈមនៃការប្រើប្រាស់គ្រូបង្រៀន

ដើម្បីទាក់ទាញ និងរក្សាគ្រូបង្រៀនល្អៗ អ្នកតាក់តែងគោលនយោបាយ ចាំបាច់ត្រូវតែកែលំអ ការអប់រំគ្រូ ពង្រាយគ្រូឱ្យបានកាន់តែយុត្តិធម៌ជាងមុន ផ្តល់ការលើកទឹកចិត្តក្នុងទម្រង់ជាបៀវត្សរ៍សមស្រប និងបង្កើតនូវគន្លងអាជីពដែលមានភាពទាក់ទាញ។ បើទោះបីជាមានវឌ្ឍនភាពក៏ដោយ កង្វះគ្រូបង្រៀននៅតែជាក្តីបារម្ភធ្ងន់ធ្ងរមួយ។ គម្លាតផលធៀបសិស្ស-គ្រូ រវាងតំបន់មួយ និងតំបន់មួយ នៅតែមានកម្រិតខ្ពស់។ គិតត្រឹមឆ្នាំ២០១២ ក្នុងចំណោម១៦១ប្រទេស ដែលមានទិន្នន័យប្រទេសចំនួន២៩ មានផលធៀបសិស្ស-គ្រូនៅបឋមសិក្សា លើសពី ៤០ ៖ ១។ ក្នុងចំណោមប្រទេសទាំងនេះ មានប្រទេសចំនួន ២៤ ស្ថិតនៅអាហ្វិចសាប់សាហារ៉ា។ ផលធៀបសិស្ស-គ្រូនៅ បឋមសិក្សា មានការថយចុះ នៅក្នុងប្រទេសចំនួន ១២១ ក្នុងចំណោម ១៤៦ ប្រទេស ដែលមានទិន្នន័យសម្រាប់ឆ្នាំ ១៩៩៩ និង២០១២។ ការបែកចែកគ្រូមិនបានស្មើគ្នានៅក្នុងប្រទេសនាំឱ្យបញ្ហាវិសមធម៌កាន់តែមានការកើនឡើង។ ចន្លោះពីឆ្នាំ ២០១២ ដល់ ២០១៥ ចាំបាច់ត្រូវមានគ្រូ៤លាននាក់ ដើម្បីសម្រេចឱ្យបាននូវសកលកម្មនៃការអប់រំ កម្រិតបឋមសិក្សា ៖ ២,៦ លាននាក់ ដើម្បីជំនួសគ្រូដែល ចូលនិវត្តន៍ ផ្លាស់ប្តូរការងារ ទទួលមរណភាព ឬឈប់ ដោយសារជំងឺ និង ១,៤ លាននាក់ ដើម្បីបំពេញចំនួន គ្រូដែលខ្វះ ដើម្បីបំពេញទៅតាមការកើនឡើងនូវការចុះឈ្មោះចូលរៀន និងរក្សាផលធៀបសិស្សគ្រូឱ្យនៅក្រោម ៤០៖១។ តំបន់ និងប្រទេសមួយចំនួនត្រូវការគ្រូបឋមសិក្សាបន្ថែមទៀតក្នុងចំនួនច្រើនជាងគ្រូនៅកម្រិតផ្សេងទៀត។ ក្នុងចំណោម៩៣ប្រទេស ដែលត្រូវការគ្រូបន្ថែមមានតែ២៩ប្រទេសប៉ុណ្ណោះដែលអាចរកបានគ្រូបន្ថែមគិតត្រឹមឆ្នាំ២០១៥ ហើយប្រទេស៦៤ទៀតនៅតែជួបប្រទះនឹងកង្វះគ្រូ។ ការបង្កើនចំនួនគ្រូ គឺមិនគ្រប់គ្រាន់នោះទេ គុណភាពក៏ចាំបាច់ត្រូវតែកែលំអផងដែរ តាមរយៈគ្រូដែលឆ្លងកាត់ការបណ្តុះបណ្តាលត្រឹមត្រូវ និងមានទឹកចិត្តបំពេញការងារ។ ប្រទេសជាច្រើនបានបង្កើនចំនួនគ្រូយ៉ាងឆាប់រហ័សតាមរយៈការជួលអ្នកដែលពុំមានសមត្ថភាពសមស្របឱ្យធ្វើជាគ្រូ

បង្រៀន។ ក្នុងចំណោម៩១ប្រទេសដែលមានទិន្នន័យឆ្នាំ២០១២ ភាគរយនៃគ្រូបឋមសិក្សាដែលបានទទួលការបណ្តុះបណ្តាលស្របតាមស្តង់ដាជាតិមានពី ៣៩% ដល់ជាង ៩៥% នៅក្នុង៣១ប្រទេស។ ការព្យាករដែលធ្វើឡើងសម្រាប់ប្រទេសចំនួន៤៦បង្ហាញថា មានប្រទេសចំនួន១២ មានគ្រូតិចជាង៧៥% បានទទួលការបណ្តុះបណ្តាលស្របតាមស្តង់ដាជាតិគិតត្រឹមឆ្នាំ២០១៥។ គម្លាតសមធម៌នៅក្នុងការពង្រាយគ្រូត្រូវការដំណោះស្រាយ។ ចំនួនគ្រូសរុប និងផលធៀបសិស្ស/គ្រូជាមធ្យមអាចលាក់កំបាំងមិនឱ្យគេឃើញពីរបាយមិនស្មើគ្នារបស់គ្រូបង្រៀនក្នុងប្រទេសនានាដែលនាំឱ្យមានការព្រួយបារម្ភខាងសមធម៌។ សិស្សនៅតាមសាលារៀនជួបការលំបាកជារឿយៗ រៀនជាមួយនឹងគ្រូដែលត្រៀមរៀបចំខ្លួនតិចតួចជាងគ្រូនៅតាមសាលារៀនដែលមានធនធានច្រើនជាង។ នៅក្នុងទសវត្សរ៍ចុងក្រោយនេះ រដ្ឋាភិបាលបានព្យាយាមដោះស្រាយបញ្ហាប្រឈមក្នុងការពង្រាយគ្រូតាមបែបផែនច្រើនយ៉ាងដូចជា ការពង្រាយគ្រូពី ថ្នាក់ជាតិទៅការផ្តល់ការលើកទឹកចិត្ត ដូចជា លំនៅដ្ឋាន អត្ថប្រយោជន៍ ផ្នែកហិរញ្ញវត្ថុ និងការពន្លឿនការឡើងឋានៈ និងការជ្រើសរើសគ្រូនៅនឹងមូលដ្ឋានផ្ទាល់។ (ក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា, ២០១៥)។

កម្ពុជានៅតែប្រឈមនឹងការពង្រឹងគុណភាព រក្សាគ្រូបង្រៀននៅបម្រើការងារក្នុងមុខងារអប់រំបានយូរ ឬរហូតដល់ចូលនិវត្តន៍ ទាក់ទាញអ្នកមានឧបនិស្ស័យជាពិសេស សិស្សដែលមាននិទ្ទេសល្អៗចូលបម្រើការងារជាគ្រូបង្រៀនក្នុងវិស័យអប់រំ (ក្រសួងអប់រំ យុវជន និងកីឡា, ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន, ២០១៨)។ យោងតាមរបាយការណ៍សន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០១៦-២០១៧ ក្នុងអនុវិស័យអប់រំបឋមសិក្សា បានលើកឡើងនូវបញ្ហាប្រឈមមួយចំនួនដែលចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយរួមមាន៖ ការអនុវត្តវិធីសាស្ត្របង្រៀនតាមបែបរិះរកនៅពុំទាន់បានទូលំទូលាយ ការគ្រប់គ្រងតាមសាលារៀននៅមិនទាន់បានអនុវត្តគ្រប់ផ្នែក ហេដ្ឋារចនាសម្ព័ន្ធរូបវន្តរួមមានប្រព័ន្ធទឹកស្អាតបង្គន់អនាម័យ...របស់គ្រឹះស្ថានបឋមសិក្សាសាធារណៈពុំទាន់ឆ្លើយតបទៅនឹងបរិបទបច្ចុប្បន្ន ការបណ្តុះបណ្តាលស្តីពីការអប់រំបរិយាបន្ន វិធីសាស្ត្របង្រៀនកុមារមានពិការភាពនៅមិនទាន់បានទូលំទូលាយ បច្ចុប្បន្នភាពតួនាទីភារកិច្ចរបស់ក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ខណ្ឌក្រុងស្រុក កង្វះ

គ្រូបង្រៀនភាសាបរទេសនៅបឋមសិក្សា កង្វះគ្រូនៅតាមសាលារៀនជនបទនិងតំបន់ជួបការលំបាក នាយកសាលាមិនបានអនុវត្តផែនការអធិការកិច្ចនិងស្វ័យវាយតម្លៃសាលាបានទៀងទាត់ (សន្និបាតបូកសរុបលទ្ធផលការងារ, ២០១៩)។ យោងតាមរបាយការណ៍របស់លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង ក្នុងអង្គសន្និបាតអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០១៨-២០១៩ និងលើកទិសដៅឆ្នាំសិក្សា២០១៩-២០២០ ដែលធ្វើឡើងនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ បានលើកឡើងថា នៅគ្រប់អនុវិស័យការកង្វះអាគារសិក្សា កង្វះគ្រូបង្រៀន និងអត្រានៃការបោះបង់ចោលការសិក្សារបស់សិស្សនៅតែចោទជាបញ្ហានៅឡើយ។

## ២.៨.ដំណោះស្រាយលើស្ថានភាពលើស ឬខ្វះគ្រូបង្រៀន

យោងតាមសេចក្តីណែនាំលេខ ៥៣ អយក.សណន ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងគ្រូបង្រៀនបានចែងពីរបៀបក្នុងការដោះស្រាយលើស្ថានភាពនៃការលើសឬខ្វះគ្រូបង្រៀនមានដូចតទៅ៖ ពង្រឹងការអនុវត្តសេចក្តីណែនាំលេខ២៣ អយក.សណន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការបែងចែកប៉ុស្តិ៍បម្រើការងាររបស់គ្រូបង្រៀនចេញថ្មី ប៉ុន្តែគួរមានការកែសម្រួលចំណុចមួយចំនួនដូចជា៖ ពង្រឹងដំណើរការរបស់គណៈកម្មការគ្រប់គ្រងបុគ្គលិករាជធានីខេត្ត គណៈកម្មការជ្រើសរើសប៉ុស្តិ៍។ គ្រូបង្រៀនចេញថ្មីដែលមានកិច្ចសន្យាទៅបម្រើការនៅសាលារៀនដែលបានជ្រើសរើសត្រូវទៅបម្រើការនៅទីនោះ។ បញ្ឈប់ការប្តូរប៉ុស្តិ៍គ្នា បន្ទាប់ពីការជ្រើសរើសប៉ុស្តិ៍រួច។ គ្រូបង្រៀនចេញថ្មីដែលមិនគោរពតាមលិខិតបង្គាប់ការ ឬលិខិតឧទ្ទេសនាម នឹងត្រូវស្នើផ្អាកបៀវត្សឬស្នើលុបឈ្មោះចេញពីក្របខ័ណ្ឌភ្លាម។

### ២.៨.១ ការដោះស្រាយចំពោះសាលារៀនលើសគ្រូបង្រៀន

ករណីនៅរាជធានីភ្នំពេញការអនុវត្តសាកល្បងដោយមានការពិនិត្យឱ្យបានហ្មត់ចត់តួលេខគ្រូបង្រៀន ដែលមានសេវាបង្រៀនមិនគ្រប់តាមនិយាមកំណត់ និងអាសយដ្ឋានបច្ចុប្បន្នរបស់គ្រូបង្រៀនទាំងអស់នោះ ដើម្បីស្នើពង្រាយទៅសាលារៀនដែលកំពុងខ្វះគ្រូបង្រៀន នៅជិតលំនៅដ្ឋានរបស់ពួកគាត់។ ករណីនៅខេត្តផ្សេងទៀតបន្តទប់ស្កាត់ការផ្លាស់គ្រូបង្រៀនចូលសាលារៀនដែលលើសគ្រូ។ ស្នើសុំគោល

ការណ៍បង្កើនប្រាក់ឧបត្ថម្ភម្តងគត់ដល់គ្រូបង្រៀនដែលស្ម័គ្រចិត្តពង្រាយទៅសាលារៀនដែលកំពុងខ្វះគ្រូ។ សុំគោលការណ៍ផ្តល់ប្រាក់បំណាច់មុខងារពិសេសដល់គ្រូដែលកំពុងបង្រៀននៅតំបន់ជួបការបាកខ្លាំង។

### ២.៨.២ ការដោះស្រាយចំពោះសាលារៀនខ្វះគ្រូបង្រៀន

ធ្វើវិក្រឹតការគ្រូបង្រៀនកម្រិតបឋមសិក្សា ដើម្បីតាំងស៊ប់ក្នុងក្របខ័ណ្ឌ ជាគ្រូបង្រៀនកម្រិតមូលដ្ឋាន និងត្រូវផ្តល់អាទិភាពឱ្យគ្រូបង្រៀនដែលស្ម័គ្រចិត្តពង្រាយទៅសាលារៀនដែលខ្វះគ្រូ ដោយតម្រូវឱ្យសាមីខ្លួនជ្រើសរើសសាលារៀន និងមុខវិជ្ជាមុននឹងដាក់ពាក្យសុំចុះឈ្មោះ។ ពិភាក្សាជាមួយក្រសួងពាក់ព័ន្ធដើម្បីរកលទ្ធភាពបង្កើនប្រាក់ឧបត្ថម្ភម្តងគត់ សម្រាប់ការពង្រាយគ្រូបង្រៀនឆ្លងរាជធានីខេត្ត ក្រុងស្រុកខណ្ឌ និងឃុំសង្កាត់។ ការស្នើបញ្ចូលក្របខ័ណ្ឌ (ទាំងគ្រូក្របខ័ណ្ឌ និងគ្រូបង្រៀនជាប់កិច្ចសន្យា) ត្រូវធ្វើឡើងដោយផ្អែកលើផែនការគ្រប់ជ្រុងជ្រោយ ច្បាស់លាស់ និងស្របតាមគោលការណ៍កំណត់ ដោយចៀសវាងនូវការស្នើសុំបន្ថែមក្នុងឆ្នាំ ដែលធ្វើឱ្យកិច្ចការនេះប្រព្រឹត្តទៅដោយមិនមានតម្លាភាព និងប្រសិទ្ធភាព។

**ក. គ្រូបង្រៀនជាប់កិច្ចសន្យា**

គ្រឹះស្ថានសិក្សាសាធារណៈ (បឋមសិក្សា) ត្រូវធ្វើស្វ័យប្រកាសអំពី ការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា ស្របតាមសេចក្តីណែនាំលេខ៤៩៨ មស.សណន របស់ក្រសួងមុខងារសាធារណៈ។ ការប្រឡងជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា ត្រូវរៀបចំដោយមានលក្ខណៈទន់ភ្លន់ និងដោយផ្តល់អាទិភាព ពិន្ទុចំពោះបេក្ខជនដែលស្ម័គ្រចិត្ត ទៅបម្រើការនៅតាមតំបន់ដាច់ស្រយាល និងជួបការលំបាក។ ពង្រឹងការអនុវត្តគោលការណ៍ណែនាំ ស្តីពីការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា ដោយត្រូវជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា តាមការចាំបាច់ជាក់ស្តែងក្នុងឆ្នាំនីមួយៗសម្រាប់សាលារៀនដែលខ្វះគ្រូ។ គ្រូបង្រៀនជាប់កិច្ចសន្យាអាចប្រឡងចូលក្របខ័ណ្ឌរដ្ឋដែលបានកំណត់នៅក្នុងលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀន។ ការស្នើសុំចូលក្របខ័ណ្ឌជាស្វ័យប្រវត្តិរបស់គ្រូបង្រៀនជាប់កិច្ចសន្យាមិនត្រូវបានអនុញ្ញាតឡើយ។ ផ្តល់សិទ្ធិឱ្យនាយកសាលាដែលមានតម្រូវការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។ សាលាគរុកោសល្យខេត្តនីមួយៗត្រូវមានផែនការបំប៉នគ្រូបង្រៀនជាប់កិច្ចសន្យាដែលជ្រើសរើសថ្មី។ ពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយក្នុងការធ្វើផែនការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា

ដើម្បីជៀសវាងការស្នើសុំបន្ថែម។ ពិនិត្យឡើងវិញគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ សុំគោលការណ៍ជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា១ឆ្នាំមុនដោយមិនមានការដោះដូរ និងបន្តដោយស្វ័យប្រវត្តិតាមរយៈ ការសិក្សានិងវាយតម្លៃសេវាបង្រៀនរបស់គ្រូបង្រៀនជាប់កិច្ចសន្យា ការធ្វើតេស្ត / ប្រឡង ការបណ្តុះបណ្តាល និងចាត់ឱ្យបង្រៀននៅចំទីតាំង។ សាលារៀនដែលត្រូវជ្រើសរើសគ្រូកិច្ចសន្យានឹងត្រូវសុំទិដ្ឋាការពីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងមុខងារ សាធារណៈ ដើម្បីជានាគុណភាព។ ស្នើសុំក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីផ្ទេរប្រាក់ឧបត្ថម្ភទៅកាន់គណនីសាលាផ្ទាល់ ប្រការនេះនឹងជានាការបើកទៀងទាត់ទាន់ពេល។ កំណត់ចំនួនជ្រើសរើសគ្រូបង្រៀនកិច្ចសន្យាមិនឱ្យលើសពី១០,០០០នាក់ក្នុង១ឆ្នាំ។ ចំពោះគ្រូបង្រៀនជាប់កិច្ចសន្យា បើមិនអាចកាត់បន្ថយបាន ក៏មិនគួរឱ្យកើនថែមទៀតទេ។ បើចាំបាច់ខ្លាំង ការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា គួរផ្តល់អាទិភាពដល់គ្រូចូលនិវត្តន៍ដែលមានសមត្ថភាព និងស្ម័គ្រចិត្តបន្តបង្រៀន ( ក្រៅពីជ្រើសរើសសិស្ស និស្សិត ដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឡើងទៅ )។ ស្នើសុំគោលការណ៍អនុញ្ញាតឱ្យមន្ទីរអប់រំ យុវជន និងកីឡា និងមន្ទីរមុខងារសាធារណៈ រាជធានី ខេត្ត មានសិទ្ធិសម្រេចលើករណីជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យាដើម្បីជំនួស គ្រូបង្រៀនជាប់កិច្ចសន្យាមរណភាព និង លំហែមាតុភាព។ ស្នើសុំគោលការណ៍បន្តផ្តល់ប្រាក់ឧបត្ថម្ភក្នុងពេលវិស្សមកាលដល់គ្រូបង្រៀនជាក់កិច្ចសន្យាដែលជ្រើសរើសចេញ ពីគ្រូបង្រៀនចូលនិវត្តន៍ និងនិស្សិតដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើង។

### ខ. គ្រូបង្រៀនថ្នាក់គួប

គ្រឹះស្ថានសិក្សាសាធារណៈ (បឋមសិក្សា) ត្រូវធ្វើស្វ័យប្រកាសអំពីការប្រើប្រាស់គ្រូបង្រៀនថ្នាក់គួបស្របតាមសេចក្តីណែនាំលេខ៤៩៨ មស.សណន របស់ក្រសួងមុខងារសាធារណៈ។ ពង្រឹងការអនុវត្តភារកិច្ចថ្នាក់គួប តាមមាត្រា ១៨ នៃអនុក្រឹត្យលេខ ៣០៩ អនក្រ.បក ស្តីពី ការគ្រប់គ្រង និងចាត់ចែងសេវាបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ចុះថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០១៤។ កង្វះបន្ទប់រៀនសម្រាប់សេវាបង្រៀនដល់សិស្សនៅកម្រិតថ្នាក់ណាមួយ ក្នុងករណីគ្រូបង្រៀនជាប់កិច្ចសន្យាមិនអាចអនុវត្តបានកង្វះបន្ទប់រៀននិងចំនួនសិស្សមិនគ្រប់តាមនិយាម គ្រឹះស្ថានបឋមសិក្សាសាធារណៈនោះមិនគ្រប់កម្រិត។

កាត់បន្ថយការប្រើគ្រូបង្រៀនថ្នាក់គួប លុបបំបាត់ការបង្រៀនថ្នាក់គួបបីកម្រិតថ្នាក់ អធិការកិច្ចលទ្ធផលនៃការបង្រៀនថ្នាក់គួប។

**គ. គ្រូបង្រៀនពីរវេន**

គ្រឹះស្ថានសិក្សាសាធារណៈ(បឋមសិក្សា) ត្រូវធ្វើស្វ័យប្រកាសអំពីការប្រើប្រាស់គ្រូបង្រៀនថ្នាក់ពីរវេនស្របតាមសេចក្តីណែនាំលេខ៤៩៤មស.សណនរបស់ក្រសួងមុខងារសាធាណៈ កាត់បន្ថយការប្រើគ្រូបង្រៀនពីរវេន អធិការកិច្ចលទ្ធផលការបង្រៀនថ្នាក់គួប។

**ឃ. ការផ្លាស់ប្តូរទីកន្លែងធ្វើការរបស់គ្រូបង្រៀន**

ទប់ស្កាត់ការផ្លាស់ប្តូរគ្រូបង្រៀនចូលសាលារៀនលើសគ្រូទោះបីតាមសហព័ទ្ធក៏ដោយ អនុញ្ញាតឱ្យផ្លាស់ប្តូរទីកន្លែងធ្វើការឆ្លងរាជធានី ខេត្ត ប៉ុន្តែសាមីខ្លួនត្រូវជ្រើសរើសសាលារៀនជាមុនសិន ហើយត្រូវមានយោបល់យល់ព្រមទទួលពីនាយកសាលារៀន និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ដែលត្រូវផ្លាស់ចូលទើបអាចដាក់ពាក្យសុំផ្លាស់ប្តូរបាន។ អនុញ្ញាតឱ្យផ្ទេរក្របខ័ណ្ឌចេញក្រៅក្រសួងចំនួន៥០នាក់ក្នុង១ឆ្នាំដោយមិនគិតការផ្ទេរជាករណីដោយឡែក។ មិនអនុញ្ញាតឱ្យគ្រូបង្រៀនចេញថ្មីគ្រប់ប្រភេទក្របខ័ណ្ឌប្តូរគ្រឹះស្ថានសិក្សាដែលសាមីខ្លួនបានជ្រើសរើស។ ការផ្លាស់ប្តូរពីរាជធានីខេត្ត ចូលអង្គភាពនានាក្រោមឱវាទទីស្តីការក្រសួងត្រូវឆ្លងកាត់ការប្រឡង វាស់ស្ទង់សមត្ថភាពនិងឆ្លងកាត់ការធ្វើសម្ភាសន៍ដោយផ្ទាល់ពីប្រធានអង្គភាពដែលត្រូវផ្លាស់ចូល។

**ង. ការផ្លាស់ប្តូរតាមសហព័ទ្ធ**

ត្រូវត្រួតពិនិត្យឯកសារឱ្យបានច្បាស់លាស់(ចៀសវាងការរៀបការក្លែងក្លាយ) អនុញ្ញាតឱ្យផ្លាស់ប្តូរតាមសហព័ទ្ធ ចូលក្រោមឱវាទទីស្តីការក្រសួង ប៉ុន្តែមិនអនុញ្ញាតផ្លាស់ចូលក្នុងអង្គភាពតែមួយ គ្រូបង្រៀនចេញថ្មីដែលសុំប្តូររាជធានី ខេត្ត តាមសហព័ទ្ធជាមន្ត្រីរាជការ អនុញ្ញាតឱ្យប្តូរ បន្ទាប់ពីសាមីខ្លួនបានបញ្ចប់កម្មសិក្សាដោយជោគជ័យ។

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១.ដំណើរការនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះនឹងធ្វើឡើងបន្ទាប់ពីឧបករណ៍ស្រាវជ្រាវរៀបចំបានចប់គ្រប់ជ្រុងជ្រោយ។ បន្ទាប់ពីទទួលបានការអនុញ្ញាតតាមលិខិតឧទ្ទេសនាមរបស់នាយកវិទ្យាស្ថានជាតិអប់រំក្នុងការចុះធ្វើការសិក្សាស្រាវជ្រាវ ដើម្បីដំណើរការរៀបចំ និងចុះប្រមូលទិន្នន័យនៅតាមមន្ទីរ អប់រំ យុវជន និងកីឡារាជធានី ខេត្ត និងបន្ទាប់ពី មានការយល់ព្រម និងអនុញ្ញាតពីប្រធានមន្ទីរ អប់រំ យុវជន និងកីឡាខេត្តព្រៃវែង អ្នកសិក្សាស្រាវជ្រាវបានធ្វើការប្រមូលព័ត៌មានពីការិយាល័យដែលពាក់ព័ន្ធមួយចំនួន ដូចជា ការិយាល័យគ្រប់គ្រងបុគ្គលិក ការិយាល័យអនុវត្ត និងផែនការ និងការិយាល័យបឋមសិក្សា ។

បន្ទាប់មកមានការបញ្ជូនទៅឱ្យការិយាល័យអប់រំ យុវជន និងកីឡាស្រុកនានាក្រោមឱវាទរបស់មន្ទីរ អប់រំ យុវជន និងកីឡាខេត្តព្រៃវែង នូវលិខិតឧទ្ទេសនាមក្នុងការចុះសិក្សាស្រាវជ្រាវ , លិខិតអនុញ្ញាតពីវិទ្យាស្ថានជាតិអប់រំ និងព័ត៌មានលម្អិតនានា និងធ្វើការទំនាក់ទំនងទៅប្រធានការិយាល័យនានា ដើម្បីរៀបចំកិច្ចដំណើរការប្រមូលទិន្នន័យ ដោយពន្យល់ពីគោលបំណង និងជូនដំណឹងដល់នាយកសាលា និងកំណត់កាលបរិច្ឆេទដំណើរការប្រមូលទិន្នន័យ។

បន្ទាប់ពីជូនដំណឹង និងទាក់ទងរួចហើយ ដំណើរការសម្ភាសនឹងចាប់ផ្តើម ដោយប្រើប្រាស់កម្រងសំណួរ ដែលបង្កើតឡើងដោយប្រព័ន្ធបច្ចេកវិទ្យា Google Forms ដែលមានលក្ខណៈជាទម្រង់បិទ និងបើក (បំពេញឈ្មោះ និង គ្រីស √ ) សម្រាប់នាយក/នាយិកា ធ្វើការបំពេញ និងឆ្លើយសំណួរទៅតាមការយល់ឃើញរបស់ពួកគាត់។ ដើម្បីធានានូវសុក្រឹតភាព ភាពជឿជាក់ និងផ្ទៀងផ្ទាត់ចម្លើយ ឱ្យបានច្បាស់លាស់ មុននឹងបញ្ចប់ការឆ្លើយកម្រងសំណួរសម្ភាសន៍នីមួយៗ អ្នកស្រាវជ្រាវបានកំណត់លើប្រព័ន្ធ Google Forms តម្រូវឱ្យមានការឆ្លើយតបគ្រប់សំណួរទើប ប្រព័ន្ធអនុញ្ញាតឱ្យបញ្ចប់ការឆ្លើយដោយជោគជ័យ ។

## ៣.២.វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវខាងលើ និងសម្រេចទៅតាមគោលបំណងនៃការសិក្សាស្រាវជ្រាវ ការសិក្សានេះនឹងជ្រើសរើសយកវិធីសាស្រ្តបញ្ចូលគ្នារវាង បរិមាណវិស័យ និងគុណវិស័យ។ ក្នុងនោះចំពោះការប្រមូលទិន្នន័យតាមបែបបរិមាណវិស័យនឹងប្រើប្រាស់នូវកម្រងសំណួរជាទម្រង់បិទជាក់លាក់ និងតាមលំដាប់លំដោយ។ ចំណែកឯការប្រមូលទិន្នន័យតាមបែបគុណវិស័យនឹងប្រើប្រាស់សំណួរគោលៗ ជាលក្ខណៈទម្រង់បើក និងមានភាពបត់បែន។ ទាំងកម្រងសំណួរបិទ និងសំណួរគោលៗ បានតាក់តែងឡើងសម្រាប់ការឆ្លើយតបកម្រងសំណួរដែលមានលក្ខណៈជាបុគ្គល ។

## ៣.៣.ការជ្រើសរើសគំរូសំណាក

អ្នកស្រាវជ្រាវបានធ្វើការជ្រើសរើសយកចំនួនសំណាកសាលាបឋមសិក្សាទាំងអស់ក្នុងខេត្តព្រៃវែងចំនួន៥៤៧សាលា ដើម្បីចុះទៅប្រមូលទិន្នន័យសម្រាប់ការស្រាវជ្រាវដោយផ្អែកទៅលើប្រភេទទីតាំងសាលាចំនួន៣ប្រភេទ គឺ សាលារៀននៅទីប្រជុំជនចំនួន១២សាលា សាលារៀននៅតំបន់ជនបទចំនួនសាលា៣៩៤សាលា និងសាលារៀននៅតំបន់ជនបទដែលជួបការលំបាកចំនួន១៤១សាលា។ ប្រភេទសំណាក ជាគណៈគ្រប់គ្រងសាលារៀន០១រូប ក្នុង០១សាលា ដែលកំពុងទទួលខុសត្រូវលើការងារប្រើប្រាស់គ្រូបង្រៀននៅតាមអង្គភាពនីមួយៗ។

*តារាងទី4៖ ចំនួនសំណាកសម្រាប់ការចុះប្រមូលទិន្នន័យ*

| ល.រ | ស្រុក | សរុបសាលា | គណៈគ្រប់គ្រងសាលា |
|---|---|---|---|
| ១ | បាភ្នំ | ៤៧ | ៤៧ |
| ២ | កំចាយមារ | ៤០ | ៤០ |
| ៣ | កំពង់ត្របែក | ៥៧ | ៥៧ |
| ៤ | កញ្ជ្រៀច | ៣៥ | ៣៥ |
| ៥ | មេសាង | ៥៥ | ៥៥ |
| ៦ | ពាមជរ | ៣៦ | ៣៦ |
| ៧ | ពាមរក៍ | ៣១ | ៣១ |

| | | | |
|---|---|---|---|
| ៨ | ពារាំង | ៥៤ | ៥៤ |
| ៩ | ពោធិ៍រៀង | ២២ | ២២ |
| ១០ | ព្រះស្តេច | ៦០ | ៦០ |
| ១១ | ក្រុងព្រៃវែង | ១២ | ១២ |
| ១២ | ស៊ីធរកណ្តាល | ៤៧ | ៤៧ |
| ១៣ | ស្វាយអន្ទរ | ៥១ | ៥១ |
| សរុប | | ៥៤៧ | ៥៤៧ |

## ៣.៤.ឧបករណ៍ស្រាវជ្រាវ

ឧបករណ៍ស្រាវជ្រាវដែលត្រូវយកមកប្រើនៅក្នុងការប្រមូលទិន្នន័យមានជាកម្រងសំណួរដែលមានកម្រិតចម្លើយ ជាទម្រង់បិទ និងកម្រងសំណួរទម្រង់បើក។ ដើម្បីប្រមូលទិន្នន័យនេះបាន ត្រូវមានកម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលាបឋមសិក្សា។កម្រងសំណួរសម្រាប់សម្ភាសន៍គណៈគ្រប់គ្រងសាលាមានគោលបំណងស្វែងយល់ពីដំណើរការងារគ្រប់គ្រងរបស់នាយក/នាយិកាលើការបែងចែក និងប្រើប្រាស់បុគ្គលិករបស់ខ្លួន។ កម្រងសំណួរត្រូវបានចែកចេញជា ០៣ ផ្នែក គឺ ផ្នែកទី១ ស្តីពីស្ថានភាពទីតាំងសាលារៀន ផ្នែកទី២ ស្តីពីការកំណត់តម្រូវការ បញ្ហាប្រឈម និងដំណោះស្រាយ និងផ្នែកទី៣ ស្តីអំពីសំណូមពររបស់នាយក/នាយិកាសាលាលើបញ្ហាលើសខ្វះគ្រូបង្រៀន ។

យោងតាមពេលវេលាមានកំណត់ និងស្ថានភាពបច្ចុប្បន្នមានការរាតត្បាតពីជម្ងឺសកលCOVID-19 ដែលតម្រូវឱ្យសាលារៀនមានការផ្អាកជាបណ្តោះអាសន្នផងនោះ ដូច្នេះឧបករណ៍ស្រាវជ្រាវត្រូវបានបញ្ជូនទៅគណៈគ្រប់គ្រងសាលាបឋមសិក្សាទាំង៥៤៧ក្នុងខេត្តព្រៃវែងតាមរយៈការបញ្ជូនតំណភ្ជាប់ចូលទៅក្នុងប្រព័ន្ធ Telegram ដោយការបំពេញកម្រងសំណួរ តាមបច្ចេកវិទ្យា Google Forms ។

## ៣.៥.ការប្រមូលទិន្នន័យ

បន្ទាប់ពីបានទទួលការណែនាំ និងឯកភាពពីសាស្ត្រាចារ្យដឹកនាំ ព្រមទាំងទទួលការអនុញ្ញាតពីលោក នាយកវិទ្យាស្ថានជាតិអប់រំ តាមរយៈលិខិតឧទ្ទេសនាម លេខ៖១៣៥ វជអ.ជក ចុះថ្ងៃ ពុធ ៩កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ២០២០។ កម្មវត្ថុ៖ ការចុះប្រមូលទិន្នន័យរបស់និសិត្សឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ដើម្បីសរសេរនិក្ខេបបទបំពេញលក្ខខណ្ឌសិក្សា តាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០តទៅ។

ទិន្នន័យដែលអ្នកស្រាវជ្រាវបានធ្វើការប្រមូលដើម្បីសរសេរនិក្ខេបបទនេះមាន២ប្រភេទ៖ ទិន្នន័យប្រភេទទី១៖ ទិន្នន័យពីការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកទាំង១៣ និងការិយាល័យបុគ្គលិក ការិយាល័យអនុវត្តនិងផែនការ និងការិយាល័យបឋមសិក្សានៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង។ ទិន្នន័យប្រភេទទី២៖ ទិន្នន័យដែលប្រមូលបានពីការបំពេញកម្រងសំណួរផ្ទាល់ពីនាយកសាលាបឋមសិក្សាទូទាំងខេត្តព្រៃវែង តាមរយៈកម្រងសំណួរបំពេញដែលរៀបចំតាមបច្ចេកវិទ្យា Google Forms។

## ៣.៦.ការវិភាគទិន្នន័យ

ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវខាងលើ ចំពោះទិន្នន័យបែបបរិមាណវិស័យអ្នកស្រាវជ្រាវបានវាយបញ្ចូលនូវទិន្នន័យដែលប្រមូលបានពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង និងទាញយកទិន្នន័យដែលបានមកពីការបំពេញកម្រងសំណួររបស់នាយកសាលាតាមរយៈបច្ចេកវិទ្យា Google Forms មករៀបចំប្រើប្រាស់ក្នុងកម្មវិធី Microsoft Excel 2016 ដោយវិភាគតាមក្រាប តាមតារាង ជាតួលេខ និងជាតួភាគរយ។ លទ្ធផលដែលទទួលបានត្រូវបានរៀបចំធ្វើការវិភាគទៅលើតារាង និងក្រាបនីមួយៗបង្ហាញទិន្នន័យជាចម្បងនឹងធ្វើការប្រៀបធៀបរវាងការអនុវត្តតាមគោលដៅនានា និងតាមនិយាមកំណត់ដោយច្បាប់ ដើម្បីទទួលបានចម្លើយ ដែលអាចឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវខាងលើ ព្រមទាំងស្របទៅតាមគោលបំណងនៃការស្រាវជ្រាវនេះផងដែរ។ រីឯការវិភាគទិន្នន័យបែបគុណវិស័យគឺវិភាគតាម រយៈការចាត់

ថ្នាក់ជាក្រុម និងដាក់ចំណាងជើងដោយផ្អែកទៅលើទស្សនៈនិងអត្ថន័យនៃប្រយោគដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា រួចធ្វើការបរិយាយ និងពន្យល់តាមចំណាត់ថ្នាក់នៃក្រុមនីមួយៗ។

## ៣.៧.ក្រមសីលធម៌ក្នុងពេលធ្វើការសិក្សាស្រាវជ្រាវ

អ្នកស្រាវជ្រាវបានធ្វើការស្នើសុំលិខិតអនុញ្ញាតពីថ្នាក់ដឹកនាំវិទ្យាស្ថានជាតិអប់រំ និងប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង ជាក្រមសីលធម៌មួយសម្រាប់ការស្រាវជ្រាវនៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង ក៏ដូចជាសាលាបឋមសិក្សា ដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា និងការបង្ហាញពីការគោរពតាមឋានានុក្រមថ្នាក់ដឹកនាំផងដែរ ។

អ្នកស្រាវជ្រាវមិនត្រូវបានបង្ហាញពីឈ្មោះអ្នកដែលខ្លួនបានប្រមូលព័ត៌មាននោះទេ ជាពិសេសរាល់ចំណុចអវិជ្ជមានចំពោះអ្នកដែលបានផ្តល់ទិន្នន័យ និងឆ្លើយសំណួរស្រាវជ្រាវ ព្រោះជាកត្តាមួយដែលធ្វើឱ្យមានការបាក់ទឹកចិត្ត អាចបង្កឱ្យមានជម្លោះដោយថាហេតុកើតឡើង ហើយក៏អាចធ្វើឱ្យប៉ះពាល់ដល់អង្គភាពបំពេញការងារ ពោលគឺព័ត៌មានដែលទទួលបាននឹងត្រូវរក្សាការសម្ងាត់។ អ្នកស្រាវជ្រាវត្រូវធ្វើការលើកទឹកចិត្តដល់អ្នកឆ្លើយសំណួរ និងអំណរគុណដល់ពួកគាត់ដែលបានចូលរួមផ្តល់ព័ត៌មានដល់អ្នកស្រាវជ្រាវ ព្រមទាំងអាចជះឥទ្ធិពលល្អសម្រាប់អ្នកស្រាវជ្រាវក្រោយៗទៀតឱ្យមានការផ្តល់នូវតម្លៃ ភាពជឿជាក់រវាងគ្នាទៅវិញទៅមក ទាំងអ្នកស្រាវជ្រាវទាំងអ្នកផ្តល់ព័ត៌មាន ។

# ជំពូកទី៤

# លទ្ធផល និងការពិភាក្សា

## ៤.១.ស្ថានភាពទីតាំងសាលារៀន

*តារាងទី5៖ ព័ត៌មានទីតាំងសាលាបឋមសិក្សាដែលនាយកសាលាបានបំពេញកម្រងសំណួរ*

| ល.រ | បរិយាយ | | ចំនួន | ភាគរយ |
|---|---|---|---|---|
| 1 | ទីតាំងសាលារៀន | តំបន់ទីប្រជុំជន | 12 | 2.2% |
| | | តំបន់ជនបទ | 343 | 62.7% |
| | | តំបន់ជួបការលំបាក | 121 | 22.1% |
| | | សរុប | 476 | 87% |

តារាងទិន្នន័យទី៥បង្ហាញថា នាយកនៃសាលាបឋមសិក្សាដែលបានបំពេញកម្រងសំណួរមានចំនួន៤៧៦សាលា ស្មើនឹង៨៧% នៃសាលាបឋមសិក្សាសរុប៥៤៧សាលាក្នុងខេត្តព្រៃវែង ។ នៅក្នុងនោះសាលារៀនដែលស្ថិតនៅទីប្រជុំជនមានចំនួន១២សាលា ស្មើនឹង២.២% នៅតំបន់ជនបទមានចំនួន៣៤៣សាលា ស្មើនឹង៦២.៧% និងនៅតំបន់ជួបការលំបាកមានចំនួន១២១ ស្មើនឹង២២.១% ។ ការប្រមូលទិន្នន័យពីនាយកសាលាមិនបានគ្រប់ចំនួន១០០%នោះទេ នេះដោយសារស្ថានភាពសាលារៀនត្រូវបានផ្អាកជាបណ្ដោះអាសន្នដោយសារជម្ងឺសកលCOVID-19 ហើយការស្រាវជ្រាវប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា Google Forms ក្នុងការប្រមូលទិន្នន័យពីចម្ងាយ ដែលពាក់ព័ន្ធយ៉ាងសំខាន់ផងដែរទៅនឹងសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យានេះរបស់នាយកសាលានៅបឋមសិក្សា ។

## ៤.២.ការកំណត់ពីតម្រូវការ

### ៤.២.១.ស្ថានភាពនៃការប្រើប្រាស់គ្រូនៅតាមសាលាបឋមសិក្សាក្នុងខេត្តព្រៃវែង

នៅក្នុងទូទាំងខេត្តព្រៃវែងមានសាលាបឋមសិក្សាសរុបចំនួន៥៤៧សាលា ដែលជាក់ស្ដែងមានសិស្សសរុបចំនួន១៤៨២៣០នាក់ មានថ្នាក់សរុបចំនួន៤៥៣៣ថ្នាក់ និងប្រើប្រាស់គ្រូបង្រៀនចំនួន២៦៩១នាក់ (នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ, ២០២០)។

*ក្រាបទី 1៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងនៅបឋមសិក្សាក្នុងខេត្តព្រៃវែង*




តាមសេចក្តីណែនាំលេខ២០ អយក.សណន ចុះថ្ងៃទី៩ខែសីហាឆ្នាំ២០១៨ ស្តីពីនិយាមប្រើបុគ្គលិកអប់រំ បានបង្ហាញពីផលធៀបសិស្សថ្នាក់នៅសាលារៀនចំណេះទូទៅនៅបឋមសិក្សាជា២ផ្នែកគឺផ្នែកទី១៖ ថ្នាក់ទី១ដល់ទី៣សិស្សក្នុងមួយថ្នាក់មានចំនួនពី៣៥នាក់ទៅ៤៥នាក់ និងផ្នែកទី២៖ថ្នាក់ទី៤ដល់ទី៦សិស្សក្នុងមួយថ្នាក់មានចំនួនពី៤០នាក់ទៅ៥០នាក់ ។ ដើម្បីធ្វើការវិភាគ អ្នកស្រាវជ្រាវបានកំណត់និយាមសិស្ស-ថ្នាក់ជា២ប្រភេទគឺ ប្រភេទទី១៖ ថ្នាក់ទី១ដល់ថ្នាក់ទី៣ ក្នុងមួយថ្នាក់ដាក់សិស្សចំនួន៣៥នាក់ និងថ្នាក់ទី៤ដល់ថ្នាក់ទី៦ ក្នុងមួយថ្នាក់ដាក់សិស្សចំនួន៤០នាក់ នេះឱ្យឈ្មោះថានិយាមអប្បបរមា និងប្រភេទទី២៖ ថ្នាក់ទី១ដល់ថ្នាក់ទី៣ ក្នុងមួយថ្នាក់ដាក់សិស្សចំនួន៤៥នាក់ និងថ្នាក់ទី៤ដល់ថ្នាក់ទី៦ ក្នុងមួយថ្នាក់ដាក់សិស្សចំនួន៥០នាក់ នេះឱ្យឈ្មោះថានិយាមអតិបរមា ។

តាមនិយាមអប្បបរមា សិស្សជាក់ស្តែងសរុបមានចំនួន១៤៨២៣០នាក់ នោះត្រូវមានថ្នាក់ចំនួន៣៩៧៧ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ដល់ទី៣ចំនួន៧៥៨៤២ចែក៣៥ស្មើនឹង២១៦៧ថ្នាក់ បូក ១៨១០ថ្នាក់ដែលបានមកពីចំនួនសិស្សថ្នាក់ទី៤ដល់ទី៦ចំនួន៧២៣៨៨ចែក៤០) ដែលត្រូវការប្រើប្រាស់គ្រូបង្រៀនចំនួន៣៩៧៧នាក់ (តាមច្បាប់កំណត់ក្នុង១ថ្នាក់ត្រូវការគ្រូ១នាក់) ។ ប៉ុន្តែតាមទិន្នន័យដែលទទួលបាន ចំនួនថ្នាក់សរុបជាក់ស្តែង ច្រើនជាង ថ្នាក់តាមនិយាមចំនួន៥៥៦ថ្នាក់

(៤៥៣៣ថ្នាក់ ដក ៣៩៧៧ថ្នាក់)។ រីឯគ្រូដែលជាបុគ្គលិកបង្រៀនជាក់ស្តែងមានចំនួន២៦៩១នាក់ តិចជាង គ្រូបង្រៀនតាមនិយាមចំនួន១២៨៦នាក់(៣៩៧៧នាក់ ដក ២៦៩១នាក់)។

តាមនិយាមអតិបរមាត្រូវមានថ្នាក់ចំនួន៣១៣៣ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ ដល់ទី៣ចំនួន៧៥៨៤២ចែក៤៥ស្មើនឹង១៦៨៥ថ្នាក់ បូក ១៤៤៨ថ្នាក់ដែលបានមកពីចំនួនសិស្សថ្នាក់ទី៤ដល់ទី៦ចំនួន៧២៣៨៨ចែក៥០) ដែលត្រូវការប្រើប្រាស់គ្រូបង្រៀនចំនួន៣១៣៣នាក់។ ប៉ុន្តែតាមទិន្នន័យថ្នាក់ជាក់ស្តែងច្រើនជាងថ្នាក់តាមនិយាមចំនួន១៤០០ថ្នាក់(៤៥៣៣ថ្នាក់ ដក ៣១៣៣ថ្នាក់)។ រីឯគ្រូបង្រៀនជាក់ស្តែងមានចំនួន តិចជាង គ្រូបង្រៀនគិតតាមនិយាមចំនួន៤៤២នាក់(៣១៣៣នាក់ ដក ២៦៩១នាក់)។

តាមទិន្នន័យជាក់ស្តែងមានថ្នាក់ចំនួន៤៥៣៣ថ្នាក់ បើតាមច្បាប់កំណត់១ថ្នាក់ត្រូវការគ្រូបង្រៀន១ម្នាក់ នោះត្រូវប្រើប្រាស់គ្រូបង្រៀនចំនួន៤៥៣៣នាក់។ តាមទិន្នន័យដែលទទួលបាន គ្រូបង្រៀនជាក់ស្តែង តិចជាងតម្រូវការជាក់ស្តែងចំនួន១៨៤២នាក់ (៤៥៣៣នាក់ ដក ២៦៩១នាក់)។

សរុបមកជារួមនៅបឋមសិក្សាក្នុងទូទាំងខេត្តព្រៃវែងចំនួនថ្នាក់ជាក់ស្តែងច្រើនជាងចំនួនថ្នាក់គិតតាមនិយាម បើទោះបីជាគិតតាមនិយាមអប្បបរមា ឬនិយាមអតិបរមាក៏ដោយ។ មូលហេតុចម្បងមួយដែលរួមចំណែកបណ្តាលឱ្យចំនួនថ្នាក់ជាក់ស្តែងមានច្រើនជាងចំនួនថ្នាក់តាមនិយាម គឺដោយសារសាលាបឋមសិក្សាដែលស្ថិតនៅតំបន់ជនបទភាគច្រើន នៅក្នុងមួយថ្នាក់ៗមានចំនួនសិស្សតិច ជាពិសេសនៅតំបន់ជួបការលំបាក ពោលគឺនៅក្នុងចំណោមថ្នាក់សរុបជាក់ស្តែងទាំងអស់មានតែប្រមាណជា៤៦.៥% ប៉ុណ្ណោះដែលអាចអនុវត្តតាមនិយាម ចំពោះថ្នាក់ដែលមានចំនួនសិស្សតិចជាងនិយាមមានប្រមាណជា៥១.១% ហើយក៏មានថ្នាក់ដែលមានចំនួនសិស្សច្រើនប្រមាណជា២.៤%ផងដែរ។ នេះបញ្ជាក់ថា ការប្រើប្រាស់និយាមសិស្ស-ថ្នាក់ក្នុងខេត្តព្រៃវែងតិចជាងនិយាម សិស្ស-ថ្នាក់ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡាមានចំនួនច្រើន។ រីឯគ្រូបង្រៀនជាក់ស្តែងមានចំនួន តិចជាងតម្រូវការគ្រូតាមនិយាម។ នេះមានន័យថាខ្វះគ្រូបង្រៀននៅបឋមសិក្សា បើអនុវត្តតាមនិយាមដែលកំណត់ដោយច្បាប់ ហើយកាន់តែ

ខ្វះគ្រូបង្រៀនសម្រាប់តម្រូវការដែលកំពុងអនុវត្តជាក់ស្តែង។ ស្ថានភាពនេះបញ្ជាក់ឱ្យឃើញថា ការបែងចែក និងប្រើប្រាស់គ្រូបង្រៀននៅក្នុងខេត្តព្រៃវែងពុំទាន់មានប្រសិទ្ធភាពនៅឡើយទេ។

*តារាងទី៦៖ តម្រូវការគ្រូបង្រៀននៅបឋមសិក្សាតាមក្រុង-ស្រុកនីមួយៗក្នុងខេត្តព្រៃវែង*

| ល.រ | ស្រុក | គ្រូបង្រៀនជាក់ស្តែង | តម្រូវការគ្រូ | | | |
|---|---|---|---|---|---|---|
| | | | តាមនិយាមអប្បបរមា | | និយាមអតិបរមា | |
| | | | លើស | ខ្វះ | លើស | ខ្វះ |
| 1 | បាភ្នំ | 311 | 12 | - | 76 | - |
| 2 | កំចាយមារ | 185 | - | 175 | - | 75 |
| 3 | កំពង់ត្របែក | 295 | - | 173 | - | 74 |
| 4 | កញ្ជៀច | 101 | - | 142 | - | 90 |
| 5 | មេសាង | 290 | - | 133 | - | 43 |
| 6 | ពាមជរ | 133 | - | 142 | - | 84 |
| 7 | ពាមរក៍ | 182 | - | 18 | 25 | - |
| 8 | ពារាំង | 249 | - | 169 | - | 80 |
| 9 | ពោធិ៍រៀង | 112 | - | 23 | 6 | - |
| 10 | ព្រះស្ដេច | 257 | - | 224 | - | 122 |
| 11 | ក្រុងព្រៃវែង | 137 | 41 | - | 62 | - |
| 12 | ស៊ីធរកណ្ដាល | 191 | - | 44 | 6 | - |
| 13 | ស្វាយអន្ទរ | 248 | - | 127 | - | 48 |
| សរុប | | 2691 | 53 | 1370 | 175 | 616 |

តារាងទិន្នន័យទី៦បង្ហាញថា តាមនិយាមអប្បបរមាគ្រូបង្រៀននៅបឋមសិក្សាក្នុងក្រុង-ស្រុកទាំង ១៣ក្នុងខេត្តព្រៃវែង លើសគ្រូបង្រៀនចំនួន៥៣នាក់ ក្នុងនោះមានស្រុកបាភ្នំ និងក្រុងព្រៃវែង ហើយខ្វះគ្រូបង្រៀនចំនួន១៣៧០នាក់នៅតាមស្រុក១១ផ្សេងទៀត ក្នុងនោះស្រុកចំនួន៨ដែលខ្វះគ្រូបង្រៀនច្រើនរួមមាន៖ ស្រុកកំចាយមារ ស្រុកកំពង់ត្របែក ស្រុកកញ្ជៀច ស្រុកមេសាង ស្រុកពាមជរ ស្រុកពារាំង ស្រុក

ព្រះស្តេច និងស្រុកស្វាយអន្ទរ។ បើតាមនិយាមអតិបរមាវិញ នៅបឋមសិក្សាក្នុងក្រុង-ស្រុកទាំង១៣ក្នុងខេត្តព្រៃវែង លើសគ្រូបង្រៀនចំនួន១៧៥នាក់ នៅតាមស្រុកចំនួន៦គឺ ស្រុកបាភ្នំ ស្រុកកំចាយមារ ស្រុកពាមរក៍ ស្រុកពោធិ៍រៀង ក្រុងព្រៃវែង និងស្រុកស៊ីធរកណ្តាល ហើយខ្វះគ្រូបង្រៀនចំនួន៦១៦នាក់នៅតាមស្រុក៨ផ្សេងទៀត ក្នុងនោះស្រុកចំនួន៥ដែលខ្វះគ្រូបង្រៀនច្រើនរួមមាន ស្រុកកំពង់ត្របែក ស្រុកកញ្ជៀច ស្រុកពាមជរ ស្រុកពារាំង និងស្រុកព្រះស្តេច ។

សរុបជារួមនៅក្នុងខេត្តព្រៃវែងមានស្រុកចំនួនពីរដែលលើសគ្រូបង្រៀននៅបឋមសិក្សាគឺស្រុកបាភ្នំ និងក្រុងព្រៃវែង ហើយស្រុកចំនួនបីគឺស្រុកពាមរក៍ ស្រុកពោធិ៍រៀង និងស្រុកស៊ីធរកណ្តាល អាចនិយាយបានថាគ្រូបង្រៀនមានចំនួនគ្រប់គ្រាន់ បើអនុវត្តតាមនិយាមដែលកំណត់ដោយច្បាប់ ប៉ុន្តែនៅតែខ្វះគ្រូបង្រៀនសម្រាប់តម្រូវការដែលកំពុងអនុវត្ត។ រីឯស្រុកដទៃក្រៅពីនេះសុទ្ធតែមានបញ្ហាខ្វះគ្រូបង្រៀនយ៉ាងច្រើននៅបឋមសិក្សា។

### ៤.២.២.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកបាភ្នំ

នៅក្នុងស្រុកបាភ្នំមានសាលាបឋមសិក្សាសរុបចំនួន៤៧សាលា ដែលជាក់ស្តែងមានសិស្សសរុបចំនួន ១១១០៦នាក់ មានថ្នាក់សរុបចំនួន៣៨១ថ្នាក់ និងប្រើប្រាស់គ្រូបង្រៀនចំនួន៣១១នាក់។

*ក្រាបទី 2៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកបាភ្នំ*



តាមនិយាមអប្បបរមាត្រូវមានថ្នាក់ចំនួន២៩៩ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ ដល់ទី៣ចំនួន៥៩៣៧នាក់ចែក៣៥ស្មើនឹង១៧០ថ្នាក់ បូក ១២៩ថ្នាក់ដែលបានមកពីចំនួនសិស្សថ្នាក់ទី ៤ដល់ទី៦ចំនួន៥១៦៩ចែក៤០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន២៩៩នាក់ ( តាមច្បាប់កំណត់ក្នុង១ថ្នាក់ត្រូវការគ្រូ១នាក់)។ តាមទិន្នន័យជាក់ស្តែង ចំនួនថ្នាក់លើសពីតម្រូវការថ្នាក់តាមនិយាមចំនួន៨២ថ្នាក់ (៣៨១ថ្នាក់ ដក ២៩៩ថ្នាក់)។ រីឯចំនួនគ្រូបង្រៀនជាក់ស្តែង ច្រើនជាង តម្រូវការគ្រូតាមនិយាមចំនួន១២នាក់ (៣១១នាក់ ដក ២៩៩នាក់)។

តាមនិយាមអតិបរមាត្រូវមានថ្នាក់ចំនួន២៣៥ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ ដល់ទី៣ចំនួន៥៩៣៧នាក់ចែក៤៥ស្មើនឹង១៣២ថ្នាក់ បូក ១០៣ថ្នាក់ដែលបានមកពីចំនួនសិស្សថ្នាក់ទី ៤ដល់ទី៦ចំនួន៥១៦៩ចែក៥០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន២៣៥នាក់។ តាមទិន្នន័យជាក់ស្តែងចំនួនថ្នាក់លើសតម្រូវការថ្នាក់តាមនិយាមចំនួន១៤៦ថ្នាក់(៣៨១ថ្នាក់ ដក ២៣៥ថ្នាក់)។ រីឯចំនួនគ្រូបង្រៀនជាក់ស្តែងច្រើនជាងតម្រូវការគ្រូតាមនិយាមចំនួន៧៦នាក់(៣១១នាក់ដក២៣៥នាក់)។

តាមទិន្នន័យជាក់ស្តែងមានថ្នាក់ចំនួន៣៨១ថ្នាក់ បើតាមច្បាប់កំណត់១ថ្នាក់ត្រូវការគ្រូបង្រៀន១ម្នាក់ នោះត្រូវប្រើប្រាស់គ្រូបង្រៀនចំនួន៣៨១នាក់។ តាមទិន្នន័យដែលទទួលបាន គ្រូបង្រៀនជាក់ស្តែងតិចជាងតម្រូវការជាក់ស្តែងចំនួន៧០នាក់ (៣៨១នាក់ ដក ៣១១នាក់) ។

សរុបមកនៅបឋមសិក្សាក្នុងស្រុកបាភ្នំចំនួនគ្រូបង្រៀនជាក់ស្តែងច្រើនជាងតម្រូវការគ្រូបង្រៀនគិតតាមនិយាម ទោះបីជាគិតតាមនិយាមអប្បបរមា ឬគិតតាមនិយាមអតិបរមា។ នេះមានន័យថាគ្រូបង្រៀននៅបឋមសិក្សាមានចំនួនគ្រប់គ្រាន់ ហើយលើសចំនួនទៀតផង បើអនុវត្តតាមនិយាមដែលកំណត់ដោយច្បាប់។ បើទោះបីគិតតាមនិយាមមានការលើសគ្រូបង្រៀនក៏ដោយ ប៉ុន្តែនៅតែខ្វះគ្រូបង្រៀនសម្រាប់តម្រូវការដែលកំពុងអនុវត្តជាក់ស្តែង ។ ចំនួនថ្នាក់ជាក់ស្តែងមានចំនួនលើសច្រើនជាងថ្នាក់តាមនិយាម។ កត្តានេះបណ្តាលមកពីសាលារៀនភាគច្រើន នៅតំបន់ជនបទជាពិសេសនៅតំបន់ដាច់ស្រយាលក្នុងមួយថ្នាក់ៗមានចំនួនសិស្សតិច។ ស្ថានភាពនេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់

តិចជាងចំនួនកំណត់ ដែលកំពុងតែអនុវត្ត ហើយការប្រើប្រាស់គ្រូបង្រៀននៅក្នុងស្រុកបាភ្នំនៅពុំទាន់មានប្រសិទ្ធភាពនៅឡើយ ។

### ៤.២.៣.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកកំចាយមារ

នៅក្នុងស្រុកកំចាយមារមានសាលាបឋមសិក្សាសរុបចំនួន៤០សាលា ដែលមានសិស្សសរុបចំនួន ១២៣២៧នាក់ មានថ្នាក់សរុបចំនួន៣៤៩ថ្នាក់ និងប្រើប្រាស់គ្រូបង្រៀនចំនួន១៨៥នាក់ ។

*ក្រាបទី 3៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកកំចាយមារ*




តាមនិយាមអប្បបរមាត្រូវមានថ្នាក់ចំនួន៣៣០ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ដល់ទី៣ចំនួន៥៩៧១នាក់ចែក៣៥ស្មើនឹង១៧១ថ្នាក់ បូក ១៥៩ថ្នាក់ដែលបានមកពីចំនួនសិស្សថ្នាក់ទី៤ដល់ទី៦ចំនួន៦៣៥៦ចែក៤០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន៣៣០នាក់ ( តាមច្បាប់កំណត់ក្នុង១ថ្នាក់ត្រូវការគ្រូ១នាក់)។ តាមទិន្នន័យជាក់ស្តែងចំនួនថ្នាក់លើសតម្រូវការថ្នាក់គិតតាមនិយាមចំនួន១៩ថ្នាក់ (៣៤៩ថ្នាក់ ដក ៣៣០ថ្នាក់) ។ រីឯចំនួនគ្រូបង្រៀនក្នុងស្រុកនេះ តិចជាង តម្រូវការគ្រូតាមនិយាមចំនួន១៤៥នាក់ (៣៣០នាក់ ដក ១៨៥នាក់)។

តាមនិយាមអតិបរមាត្រូវមានថ្នាក់ចំនួន២៦០ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ដល់ទី៣ចំនួន៥៩៧១នាក់ចែក៤៥ស្មើនឹង១៣៣ថ្នាក់ បូក ១២៧ថ្នាក់ដែលបានមកពីចំនួនសិស្សថ្នាក់ទី៤ដល់ទី៦ចំនួន៦៣៥៦ចែក៥០)ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន២៦០នាក់។ តាមទិន្នន័យជាក់

ស្តែងចំនួនថ្នាក់លើសតម្រូវការថ្នាក់គិតតាមនិយាមចំនួន៨៩ថ្នាក់(៣៤៩ថ្នាក់ដក ២៦០ថ្នាក់)។ រីឯចំនួនគ្រូបង្រៀនក្នុងស្រុកនេះតិចជាងតម្រូវការគ្រូតាមនិយាមចំនួន៧៥នាក់(២៦០នាក់ដក១៨៥នាក់)។

តាមទិន្នន័យជាក់ស្តែងមានថ្នាក់ចំនួន៣៤៩ថ្នាក់ បើតាមច្បាប់កំណត់១ថ្នាក់ត្រូវការគ្រូបង្រៀន១ម្នាក់ នោះត្រូវប្រើប្រាស់គ្រូបង្រៀនចំនួន៣៤៩នាក់។ តាមទិន្នន័យដែលទទួលបាន គ្រូបង្រៀនជាក់ស្តែងតិចជាងតម្រូវការជាក់ស្តែងចំនួន១៦៤នាក់ (៣៤៩នាក់ ដក ១៨៥នាក់)។

សរុបមកបើទោះជាគិតតាមនិយាមអប្បបរមា ឬនិយាមអតិបរមាក៏ដោយ នៅបឋមសិក្សាក្នុងស្រុកកំចាយមារចំនួនគ្រូបង្រៀនជាក់ស្តែងតិចជាងតម្រូវការគ្រូបង្រៀនគិតតាមនិយាម។ នេះមានន័យថាខ្វះគ្រូបង្រៀននៅបឋមសិក្សាយ៉ាងច្រើន បើអនុវត្តតាមនិយាមដែលកំណត់ដោយច្បាប់ ហើយកាន់តែខ្វះគ្រូបង្រៀនសម្រាប់តម្រូវការដែលកំពុងអនុវត្តជាក់ស្តែង ដោយសារតែចំនួនថ្នាក់ជាក់ស្តែងមានចំនួនច្រើនលើសតម្រូវការថ្នាក់គិតតាមនិយាម។ នេះបញ្ជាក់ថា ការប្រើប្រាស់និយាមសិស្សថ្នាក់តិចជាងចំនួនកំណត់ដែលកំពុងតែអនុវត្ត ហើយការប្រើប្រាស់គ្រូបង្រៀនក្នុងស្រុកកំចាយមារពុំទាន់មានប្រសិទ្ធភាពនៅឡើយ។

### ៤.២.៤.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកកំពង់ត្របែក

នៅក្នុងស្រុកកំពង់ត្របែកមានសាលាបឋមសិក្សាសរុបចំនួន៥៧សាលា ដែលជាក់ស្តែងមានសិស្សសរុបចំនួន១៧៤៤៧នាក់ មានថ្នាក់ចំនួន៤៩៦ថ្នាក់ និងប្រើប្រាស់គ្រូបង្រៀនចំនួន២៩៥នាក់ ។

*ក្រាបទី 4៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកកំពង់ត្របែក*



តាមនិយាមអប្បបរមាត្រូវមានថ្នាក់ចំនួន៤៦៨ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ ដល់ទី៣ចំនួន៨៩៦២នាក់ចែក៣៥ស្មើនឹង២៥៦ថ្នាក់ បូក ចំនួនសិស្សថ្នាក់ទី៤ដល់ទី៦ចំនួន៨៤៨៥ ចែក៤០ស្មើនឹង២១២ថ្នាក់) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន៤៦៨នាក់ ( តាមច្បាប់កំណត់ក្នុង១ ថ្នាក់ត្រូវការគ្រូ១នាក់) ។ តាមទិន្នន័យដែលទទួលបានចំនួនថ្នាក់ជាក់ស្តែងច្រើនជាងតម្រូវការថ្នាក់គិត តាមនិយាមចំនួន២៨ថ្នាក់ (៤៩៦ថ្នាក់ ដក ៤៦៨ថ្នាក់) ។រីឯចំនួនគ្រូបង្រៀនជាក់ស្តែងក្នុងស្រុកនេះ តិច ជាង តម្រូវការគ្រូតាមនិយាមចំនួន១៧៣នាក់ (៤៦៨នាក់ ដក ២៩៥នាក់)។

តាមនិយាមអតិបរមាត្រូវមានថ្នាក់ចំនួន៣៦៩ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ ដល់ទី៣ចំនួន៨៩៦២នាក់ចែក៤៥ស្មើនឹង១៩៩ថ្នាក់ បូក ចំនួនសិស្សថ្នាក់ទី៤ដល់ទី៦ចំនួន៨៤៨៥ ចែក៥០ស្មើនឹង១៧០ថ្នាក់) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន៣៦៩នាក់ ។ តាមទិន្នន័យជាក់ស្តែង ចំនួនថ្នាក់ច្រើនជាងតម្រូវការថ្នាក់គិតតាមនិយាមចំនួន១២៧ថ្នាក់ (៤៩៦ថ្នាក់ ដក ៣៦៩ថ្នាក់)។ រីឯ ចំនួនគ្រូជាក់ស្តែង តិចជាង តម្រូវការគ្រូតាមនិយាមចំនួន៧៤នាក់ (៣៦៩នាក់ ដក ២៩៥នាក់)។

តាមទិន្នន័យជាក់ស្តែងមានថ្នាក់ចំនួន៤៩៦ថ្នាក់ បើតាមច្បាប់កំណត់១ថ្នាក់ត្រូវការគ្រូបង្រៀន១ ម្នាក់ នោះត្រូវប្រើប្រាស់គ្រូបង្រៀនចំនួន៤៩៦នាក់។ តាមទិន្នន័យដែលទទួលបាន គ្រូបង្រៀនជាក់ស្តែង តិចជាងតម្រូវការជាក់ស្តែងចំនួន២០១នាក់ (៤៩៦នាក់ ដក ២៩៥នាក់)។

សរុបមកនៅបឋមសិក្សាក្នុងស្រុកកំពង់ត្របែកចំនួនគ្រូបង្រៀនជាក់ស្តែងតិចជាងតម្រូវការគ្រូ បង្រៀនគិតតាមនិយាម បើទោះជាគិតតាមនិយាមអប្បបរមា ឬនិយាមអតិបរមាក៏ដោយ ។ នេះមានន័យ ថាខ្វះគ្រូបង្រៀននៅបឋមសិក្សាយ៉ាងច្រើន បើអនុវត្តតាមនិយាមដែលកំណត់ដោយច្បាប់ ហើយកាន់តែ ខ្វះគ្រូបង្រៀនសម្រាប់តម្រូវការដែលកំពុងអនុវត្តជាក់ស្តែង ដោយសារតែចំនួនថ្នាក់ជាក់ស្តែងមានចំនួន ច្រើនលើសពីតម្រូវការថ្នាក់តាមនិយាម។ ស្ថានភាពនេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្ស-ថ្នាក់តិចជាងចំនួនកំណត់ ដែលកំពុងតែអនុវត្ត ហើយការប្រើប្រាស់គ្រូបង្រៀននៅក្នុងស្រុកកំពង់ត្របែក នៅពុំទាន់មានប្រសិទ្ធភាពនោះទេ ។

### ៤.២.៥.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកកញ្ជៀច

នៅក្នុងស្រុកកញ្ជៀចមានសាលាបឋមសិក្សាសរុបចំនួន៣៥សាលាដែលជាក់ស្តែងមានសិស្សសរុប ចំនួន ៩០៦៣នាក់ មានថ្នាក់ចំនួន២៨៤ថ្នាក់ និងប្រើប្រាស់គ្រូបង្រៀនចំនួន១០១នាក់ ។

*ក្រាបទី 5៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកកញ្ជៀច*




តាមនិយាមអប្បបរមាត្រូវមានថ្នាក់ចំនួន២៤៣ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ ដល់ទី៣ចំនួន៤៥៤៧នាក់ចែក៣៥ស្មើនឹង១៣០ថ្នាក់ បូក ១១៣ថ្នាក់ដែលបានពីចំនួនសិស្សថ្នាក់ទី៤ ដល់ទី៦ចំនួន៤៥១៦ចែក៤០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន២៤៣នាក់ ( តាមច្បាប់កំណត់ ក្នុង១ថ្នាក់ត្រូវការគ្រូ១នាក់) ។ តាមទិន្នន័យដែលទទួលបានចំនួនថ្នាក់ជាក់ស្តែងច្រើនជាងតម្រូវការថ្នាក់ គិតតាមនិយាមចំនួន៤១ថ្នាក់ (២៨៤ថ្នាក់ ដក ២៤៣ថ្នាក់) ។រីឯចំនួនគ្រូបង្រៀនជាក់ស្តែងក្នុងស្រុកនេះ វិញ តិចជាង តម្រូវការគ្រូតាមនិយាមចំនួន១៤២នាក់ (២៤៣នាក់ ដក ១០១នាក់)។

តាមនិយាមអតិបរមាត្រូវមានថ្នាក់ចំនួន១៩១ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ ដល់ទី៣ចំនួន៤៥៤៧នាក់ចែក៤៥ស្មើនឹង១០១ថ្នាក់ បូក ៩០ថ្នាក់ដែលបានពីចំនួនសិស្សថ្នាក់ទី៤ដល់ ទី៦ចំនួន៤៥១៦ចែក៥០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន១៩១នាក់។ តាមទិន្នន័យជាក់ស្តែង ចំនួនថ្នាក់លើសពីតម្រូវការថ្នាក់គិតតាមនិយាមចំនួន៩៣ថ្នាក់ (២៨៤ថ្នាក់ ដក ១៩១ថ្នាក់) ។ រីឯចំនួន គ្រូបង្រៀនជាក់ស្តែងវិញ តិចជាង តម្រូវការគ្រូតាមនិយាមចំនួន៩០នាក់ (១៩១នាក់ ដក ១០១នាក់)។

តាមទិន្នន័យជាក់ស្តែងមានថ្នាក់ចំនួន២៨៤ថ្នាក់ បើតាមច្បាប់កំណត់១ថ្នាក់ត្រូវការគ្រូបង្រៀន១ម្នាក់ នោះត្រូវប្រើប្រាស់គ្រូបង្រៀនចំនួន២៨៤នាក់។ តាមទិន្នន័យដែលទទួលបាន គ្រូបង្រៀនជាក់ស្តែងតិចជាងតម្រូវការជាក់ស្តែងចំនួន១៨៣នាក់ (២៩៤នាក់ ដក ១០១នាក់)។

សរុបមកនៅបឋមសិក្សាក្នុងស្រុកកញ្ជៀចចំនួនគ្រូបង្រៀនជាក់ស្តែងតិចជាងតម្រូវការគ្រូបង្រៀនគិតតាមនិយាម បើទោះជាគិតតាមនិយាមអប្បបរមា ឬនិយាមអតិបរមាក៏ដោយ ។ នេះមានន័យថាខ្វះគ្រូបង្រៀននៅបឋមសិក្សាយ៉ាងច្រើន បើអនុវត្តតាមនិយាមដែលកំណត់ដោយច្បាប់ ហើយកាន់តែខ្វះគ្រូបង្រៀនសម្រាប់តម្រូវការដែលកំពុងអនុវត្តជាក់ស្តែង ។ ចំនួនថ្នាក់ជាក់ស្តែងមានចំនួនច្រើនលើសពីតម្រូវការថ្នាក់តាមនិយាម ។ ស្ថានភាពនេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់តិចជាងចំនួនកំណត់ដែលកំពុងតែអនុវត្ត ហើយការប្រើប្រាស់គ្រូបង្រៀននៅក្នុងស្រុកកញ្ជៀចពុំទាន់មានប្រសិទ្ធភាពនោះទេ។

### ៤.២.៦.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកមេសាង

នៅក្នុងស្រុកមេសាងមានសាលាបឋមសិក្សាសរុបចំនួន៥៥សាលា ដែលជាក់ស្តែងមានសិស្សសរុបចំនួន ១៥៧៩៥នាក់ មានថ្នាក់សរុបចំនួន៤៦៨ថ្នាក់ និងប្រើប្រាស់គ្រូបង្រៀនចំនួន២៩០នាក់ ។

*ក្រាបទី ៦៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកមេសាង*



តាមនិយាមអប្បបរមាត្រូវមានថ្នាក់ចំនួន៤២៣ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ ដល់ទី៣ចំនួន៧៧៧៤នាក់ចែក៣៥ស្មើនឹង២២២ថ្នាក់ បូក ២០១ថ្នាក់ដែលបានពីចំនួនសិស្សថ្នាក់ទី៤ ដល់ទី៦ចំនួន៨០២១ចែក៤០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន៤២៣នាក់ ( តាមច្បាប់កំណត់ ក្នុង១ថ្នាក់ត្រូវការគ្រូ១នាក់)។ តាមទិន្នន័យដែលទទួលបានចំនួនថ្នាក់ជាក់ស្តែងច្រើនជាងតម្រូវការថ្នាក់ គិតតាមនិយាមចំនួន៤៥ថ្នាក់ (៤៦៨ថ្នាក់ ដក ៤២៣ថ្នាក់)។ រីឯចំនួនគ្រូបង្រៀនជាក់ស្តែងក្នុងស្រុកនេះ តិចជាង តម្រូវការគ្រូតាមនិយាមចំនួន១៣៣នាក់ (៤២៣នាក់ ដក ២៩០នាក់)។

តាមនិយាមអតិបរមាត្រូវមានថ្នាក់ចំនួន៣៣៣ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ ដល់ទី៣ចំនួន៧៧៧៤នាក់ចែក៤៥ស្មើនឹង១៧៣ថ្នាក់ បូក ១៦០ថ្នាក់ដែលបានពីចំនួនសិស្សថ្នាក់ទី៤ ដល់ទី៦ចំនួន៨០២១ចែក៥០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន៣៣៣នាក់។ តាមទិន្នន័យជាក់ស្តែងចំនួនថ្នាក់ច្រើនជាងតម្រូវការថ្នាក់គិតតាមនិយាមចំនួន១៣៥ថ្នាក់ (៤៦៨ថ្នាក់ ដក ៣៣៣ថ្នាក់)។ រីឯចំនួនគ្រូជាក់ស្តែង តិចជាង តម្រូវការគ្រូតាមនិយាមចំនួន៤៣នាក់ (៣៣៣នាក់ ដក ២៩០នាក់)។

តាមទិន្នន័យជាក់ស្តែងមានថ្នាក់ចំនួន៤៦៨ថ្នាក់ បើតាមច្បាប់កំណត់១ថ្នាក់ត្រូវការគ្រូបង្រៀន១ ម្នាក់ នោះត្រូវប្រើប្រាស់គ្រូបង្រៀនចំនួន៤៦៨នាក់។ តាមទិន្នន័យដែលទទួលបាន គ្រូបង្រៀនជាក់ស្តែង តិចជាងតម្រូវការជាក់ស្តែងចំនួន១៧៨នាក់ (៤៦៨នាក់ ដក ២៩០នាក់)។

សរុបមកនៅបឋមសិក្សាក្នុងស្រុកមេសាងចំនួនគ្រូបង្រៀនជាក់ស្តែងតិចជាងតម្រូវការគ្រូបង្រៀន គិតតាមនិយាម ទោះបីជាគិតតាមនិយាមអប្បបរមា ឬនិយាមអតិបរមាក៏ដោយ។ នេះមានន័យថាខ្វះគ្រូបង្រៀននៅបឋមសិក្សា បើអនុវត្តតាមនិយាមដែលកំណត់ដោយច្បាប់ ហើយរឹតតែខ្វះគ្រូបង្រៀនសម្រាប់ តម្រូវការដែលកំពុងអនុវត្តជាក់ស្តែង។ ចំនួនថ្នាក់ជាក់ស្តែងមានចំនួនច្រើនលើសពីតម្រូវការថ្នាក់តាម និយាម។ ស្ថានភាពនេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្ស-ថ្នាក់តិចជាងចំនួនកំណត់ ដែល កំពុងតែអនុវត្ត ហើយការប្រើប្រាស់គ្រូបង្រៀននៅក្នុងស្រុកមេសាងនៅពុំទាន់មានប្រសិទ្ធភាពនោះទេ។

### ៤.២.៧.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកពាមជរ

នៅក្នុងស្រុកពាមជរ មានសាលាបឋមសិក្សាសរុបចំនួន៣៦សាលា ដែលជាក់ស្តែងមានសិស្សសរុបចំនួន១០២៤១នាក់ មានថ្នាក់ចំនួន៣០២ថ្នាក់ និងប្រើប្រាស់គ្រូបង្រៀនចំនួន១៣៣នាក់ ។

*ក្រាបទី 7៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកពាមជរ*




តាមនិយាមអប្បបរមាត្រូវមានថ្នាក់ចំនួន២៧៥ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ដល់ទី៣ចំនួន៥៣២៤នាក់ចែក៣៥ស្មើនឹង១៥២ថ្នាក់ បូក ១២៣ថ្នាក់ដែលបានពីចំនួនសិស្សថ្នាក់ទី៤ដល់ទី៦ចំនួន៤៩១៧ចែក៤០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន២៧៥នាក់ ( តាមច្បាប់កំណត់ក្នុង១ថ្នាក់ត្រូវការគ្រូ១នាក់)។ តាមទិន្នន័យដែលទទួលបានចំនួនថ្នាក់ជាក់ស្តែងច្រើនជាងតម្រូវការថ្នាក់គិតតាមនិយាមចំនួន២៧ថ្នាក់ (៣០២ថ្នាក់ ដក ២៧៥ថ្នាក់)។ រីឯចំនួនគ្រូបង្រៀនជាក់ស្តែងក្នុងស្រុកនេះ តិចជាង តម្រូវការគ្រូតាមនិយាមចំនួន១៤២នាក់ (២៧៥នាក់ ដក ១៣៣នាក់)។

តាមនិយាមអតិបរមាត្រូវមានថ្នាក់ចំនួន២១៧ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ដល់ទី៣ចំនួន៥៣២៤នាក់ចែក៤៥ស្មើនឹង១១៨ថ្នាក់ បូក ៩៩ថ្នាក់ដែលបានពីចំនួនសិស្សថ្នាក់ទី៤ដល់ទី៦ចំនួន៤៩១៧ចែក៥០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន២១៧នាក់ ។ តាមទិន្នន័យចំនួនថ្នាក់ជាក់ស្តែង ច្រើនជាងតម្រូវការថ្នាក់គិតតាមនិយាមចំនួន៨៥ថ្នាក់ (៣០២ថ្នាក់ ដក ២១៧ថ្នាក់)។ រីឯចំនួនគ្រូជាក់ស្តែង តិចជាង តម្រូវការគ្រូតាមនិយាមចំនួន៨៤នាក់ (២១៧នាក់ ដក ១៣៣នាក់)។

តាមទិន្នន័យជាក់ស្ដែងមានថ្នាក់ចំនួន៣០២ថ្នាក់ បើតាមច្បាប់កំណត់១ថ្នាក់ត្រូវការគ្រូបង្រៀន១ម្នាក់ នោះត្រូវប្រើប្រាស់គ្រូបង្រៀនចំនួន៣០២នាក់។ តាមទិន្នន័យដែលទទួលបាន គ្រូបង្រៀនជាក់ស្ដែងតិចជាងតម្រូវការជាក់ស្ដែងចំនួន១៦៩នាក់ (៣០២នាក់ ដក១៣៣នាក់)។

សរុបមកនៅបឋមសិក្សាក្នុងស្រុកពាមជរចំនួនគ្រូបង្រៀនជាក់ស្ដែងតិចជាងតម្រូវការគ្រូបង្រៀនគិតតាមនិយាម បើទោះជាគិតតាមនិយាមអប្បបរមា ឬនិយាមអតិបរមាក៏ដោយ ។ នេះមានន័យថាខ្វះគ្រូបង្រៀននៅបឋមសិក្សាយ៉ាងច្រើន បើអនុវត្តតាមនិយាមដែលកំណត់ដោយច្បាប់ ហើយកាន់តែខ្វះគ្រូបង្រៀនសម្រាប់តម្រូវការដែលកំពុងអនុវត្តជាក់ស្ដែង ដោយសារតែចំនួនថ្នាក់ជាក់ស្ដែងមានចំនួនច្រើនលើសពីតម្រូវការថ្នាក់តាមនិយាម។ ស្ថានភាពនេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្ស-ថ្នាក់តិចជាងចំនួនកំណត់ ដែលកំពុងតែអនុវត្ត ហើយការប្រើប្រាស់គ្រូបង្រៀននៅក្នុងស្រុកពាមជរនៅពុំទាន់មានប្រសិទ្ធភាពនោះទេ។

### ៤.២.៨.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកពាមរក៍

នៅក្នុងស្រុកពាមរក៍មានសាលាបឋមសិក្សាសរុបចំនួន៣១សាលា ដែលជាក់ស្ដែងមានសិស្សសរុបចំនួន៧៤២៤នាក់ មានថ្នាក់ចំនួន២៤៣ថ្នាក់ និងប្រើប្រាស់គ្រូបង្រៀនចំនួន១៨២នាក់ ។

*ក្រាបទី ៩៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្ដែងក្នុងស្រុកពាមរក៍*



តាមនិយាមអប្បបរមាត្រូវមានថ្នាក់ចំនួន២០០ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ ដល់ទី៣ចំនួន៤០២៦នាក់ចែក៣៥ស្មើនឹង១១៥ថ្នាក់ បូក ៨៥ថ្នាក់ដែលបានពីចំនួនសិស្សថ្នាក់ទី៤ដល់ទី៦ចំនួន៣៣៩៨ចែក៤០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន២០០នាក់ ( តាមច្បាប់កំណត់ក្នុង១ថ្នាក់ត្រូវការគ្រូ១នាក់)។ តាមទិន្នន័យដែលទទួលបានចំនួនថ្នាក់ជាក់ស្តែងច្រើនជាងតម្រូវការថ្នាក់គិតតាមនិយាមចំនួន៤៣ថ្នាក់ (២៤៣ថ្នាក់ ដក ២០០ថ្នាក់)។ រីឯចំនួនគ្រូបង្រៀនជាក់ស្តែងក្នុងស្រុកនេះតិចជាង តម្រូវការគ្រូតាមនិយាមចំនួន១៨នាក់ (២០០នាក់ ដក ១៨២នាក់)។

តាមនិយាមអតិបរមាត្រូវមានថ្នាក់ចំនួន១៥៧ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ ដល់ទី៣ចំនួន៤០២៦នាក់ចែក៤៥ស្មើនឹង៨៩ថ្នាក់ បូក ៦៨ថ្នាក់ដែលបានពីចំនួនសិស្សថ្នាក់ទី៤ដល់ទី៦ចំនួន៣៣៩៨ចែក៥០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន១៥៧នាក់។ តាមទិន្នន័យដែលទទួលបានចំនួនថ្នាក់ជាក់ស្តែងច្រើនជាងតម្រូវការថ្នាក់តាមនិយាមចំនួន៨៦ថ្នាក់(២៤៣ថ្នាក់ដក១៥៧ថ្នាក់)។ រីឯចំនួនគ្រូជាក់ស្តែង ច្រើនជាង តម្រូវការគ្រូតាមនិយាមចំនួន២៥នាក់ (១៨២នាក់ ដក ១៥៧នាក់)។

តាមទិន្នន័យជាក់ស្តែងមានថ្នាក់ចំនួន២៤៣ថ្នាក់ បើតាមច្បាប់កំណត់១ថ្នាក់ត្រូវការគ្រូបង្រៀន១ម្នាក់ នោះត្រូវប្រើប្រាស់គ្រូបង្រៀនចំនួន២៤៣នាក់។ តាមទិន្នន័យដែលទទួលបាន គ្រូបង្រៀនជាក់ស្តែងតិចជាងតម្រូវការជាក់ស្តែងចំនួន៦១នាក់ (២៤៣នាក់ ដក ១៨២នាក់)។

សរុបមកនៅបឋមសិក្សាក្នុងស្រុកពាមរក៍ចំនួនគ្រូបង្រៀនជាក់ស្តែងតិចជាងចំនួនគ្រូតាមនិយាមអប្បបរមា ប៉ុន្តែបើគិតតាមនិយាមអតិបរមាវិញនោះ គ្រូបង្រៀនជាក់ស្តែងមានចំនួនលើសទៅវិញ។ នេះមានន័យថា មានចំនួនគ្រូបងៀនគ្រប់គ្រាន់នៅតាមបឋមសិក្សាក្នុងស្រុកនេះ បើអនុវត្តតាមនិយាមដែលកំណត់ដោយច្បាប់។ ប៉ុន្តែនៅតែខ្វះគ្រូបង្រៀនសម្រាប់តម្រូវការដែលកំពុងអនុវត្តជាក់ស្តែង ដោយសារតែចំនួនថ្នាក់ជាក់ស្តែងមានចំនួនច្រើនជាងថ្នាក់គិតតាមនិយាម។ ស្ថានភាពនេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្ស-ថ្នាក់តិចជាងចំនួនកំណត់ ដែលកំពុងតែអនុវត្ត ហើយការប្រើប្រាស់គ្រូបង្រៀននៅក្នុងស្រុកពាមរក៍ពុំទាន់មានប្រសិទ្ធភាពនៅឡើយ។

### ៤.២.៩.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកពារាំង

នៅក្នុងស្រុកពារាំងមានសាលាបឋមសិក្សាសរុបចំនួន៥៤សាលា ដែលជាក់ស្តែងមានសិស្សសរុបចំនួន ១៥៥៥៦នាក់ មានថ្នាក់ចំនួន៤៧៤ថ្នាក់ និងប្រើប្រាស់គ្រូបង្រៀនចំនួន២៤៩នាក់។

*ក្រាបទី ៩៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកពារាំង*




តាមនិយាមអប្បបរមាត្រូវមានថ្នាក់ចំនួន៤១៨ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ដល់ទី៣ចំនួន៨១៥៧នាក់ចែក៣៥ស្មើនឹង២៣៣ថ្នាក់ បូក ១៨៥ថ្នាក់ដែលបានពីចំនួនសិស្សថ្នាក់ទី៤ដល់ទី៦ចំនួន៧៣៩៩ចែក៤០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន៤១៨នាក់ ( តាមច្បាប់កំណត់ក្នុង១ថ្នាក់ត្រូវការគ្រូ១នាក់) ។ តាមទិន្នន័យដែលទទួលបានចំនួនថ្នាក់ជាក់ស្តែងច្រើនជាងតម្រូវការថ្នាក់គិតតាមនិយាមចំនួន៥៦ថ្នាក់ (៤៧៤ថ្នាក់ ដក ៤១៨ថ្នាក់) ។រីឯចំនួនគ្រូបង្រៀនជាក់ស្តែងក្នុងស្រុកនេះតិចជាង តម្រូវការគ្រូតាមនិយាមចំនួន១៦៩នាក់ (៤១៨នាក់ ដក ២៤៩នាក់)។

តាមនិយាមអតិបរមាត្រូវមានថ្នាក់ចំនួន៣២៩ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ដល់ទី៣ចំនួន៨១៥៧នាក់ចែក៤៥ស្មើនឹង១៨១ថ្នាក់ បូក ១៤៨ថ្នាក់ដែលបានពីចំនួនសិស្សថ្នាក់ទី៤ដល់ទី៦ចំនួន៧៣៩៩ចែក៥០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន៣២៩នាក់។ តាមទិន្នន័យជាក់ស្តែងចំនួនថ្នាក់ច្រើនជាងតម្រូវការថ្នាក់គិតតាមនិយាមចំនួន១៤៥ថ្នាក់ (៤៧៤ថ្នាក់ ដក ៣២៩ថ្នាក់)។ រីឯចំនួនគ្រូជាក់ស្តែង តិចជាង តម្រូវការគ្រូតាមនិយាមចំនួន៨០នាក់ (៣២៩នាក់ ដក ២៤៩នាក់)។

តាមទិន្នន័យជាក់ស្តែងមានថ្នាក់ចំនួន៤៧៤ថ្នាក់ បើតាមច្បាប់កំណត់១ថ្នាក់ត្រូវការគ្រូបង្រៀន១ម្នាក់ នោះត្រូវប្រើប្រាស់គ្រូបង្រៀនចំនួន៤៧៤នាក់។ តាមទិន្នន័យដែលទទួលបាន គ្រូបង្រៀនជាក់ស្តែងតិចជាងតម្រូវការជាក់ស្តែងចំនួន២២៥នាក់ (៤៧៤នាក់ ដក ២៤៩នាក់)។

សរុបមកនៅបឋមសិក្សាក្នុងស្រុកពារាំងចំនួនគ្រូបង្រៀនជាក់ស្តែងតិចជាងតម្រូវការគ្រូបង្រៀនគិតតាមនិយាម បើទោះជាគិតតាមនិយាមអប្បបរមា ឬនិយាមអតិបរមាក៏ដោយ ។ នេះមានន័យថាខ្វះគ្រូបង្រៀននៅបឋមសិក្សាយ៉ាងច្រើន បើអនុវត្តតាមនិយាមដែលកំណត់ដោយច្បាប់ ហើយកាន់តែខ្វះគ្រូបង្រៀនសម្រាប់តម្រូវការដែលកំពុងអនុវត្តជាក់ស្តែង ដោយសារចំនួនថ្នាក់ជាក់ស្តែងមានចំនួនច្រើនលើសពីតម្រូវការថ្នាក់តាមនិយាម។ ស្ថានភាពនេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្ស-ថ្នាក់តិចជាងចំនួនកំណត់ដែលកំពុងតែអនុវត្ត ហើយការប្រើប្រាស់គ្រូបងៀននៅបឋមសិក្សាក្នុងស្រុកពារាំងពុំទាន់មានប្រសិទ្ធភាពនៅឡើយ។

### ៤.២.១០.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកពោធិ៍រៀង

នៅក្នុងស្រុកពោធិ៍រៀងមានសាលាបឋមសិក្សាសរុបចំនួន២២សាលា ដែលជាក់ស្តែងមានសិស្សសរុបចំនួន៥០៤០នាក់ មានថ្នាក់សរុបចំនួន១៦៨ថ្នាក់ និងប្រើប្រាស់គ្រូបង្រៀនចំនួន១១២នាក់ ។

*ក្រាបទី 10៖តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកពោធិ៍រៀង*




តាមនិយាមអប្បបរមាត្រូវមានថ្នាក់ចំនួន១៣៥ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ដល់ទី៣ចំនួន២៥៤១នាក់ចែក៣៥ស្មើនឹង៧៣ថ្នាក់ បូក ៦២ថ្នាក់ដែលបានពីចំនួនសិស្សថ្នាក់ទី៤ដល់ទី

៦ចំនួន២៤៩៩ចែក៥០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន១៣៥នាក់ (តាមច្បាប់កំណត់ក្នុង១ថ្នាក់ត្រូវការគ្រូ១នាក់)។ តាមទិន្នន័យដែលទទួលបានចំនួនថ្នាក់ជាក់ស្តែងច្រើនជាងតម្រូវការថ្នាក់គិតតាមនិយាមចំនួន៣៣ថ្នាក់ (១៦៨ថ្នាក់ ដក ១៣៥ថ្នាក់)។ រីឯចំនួនគ្រូបង្រៀនជាក់ស្តែងក្នុងស្រុកនេះតិចជាង តម្រូវការគ្រូតាមនិយាមចំនួន២៣នាក់ (១៣៥នាក់ ដក ១១២នាក់)។

តាមនិយាមអតិបរមាត្រូវមានថ្នាក់ចំនួន១០៦ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ដល់ទី៣ចំនួន២៥៤១នាក់ចែក៤៥ស្មើនឹង៥៦ថ្នាក់ បូក ៥០ថ្នាក់ដែលបានពីចំនួនសិស្សថ្នាក់ទី៤ដល់ទី៦ចំនួន២៤៩៩ចែក៥០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន១០៦នាក់។ តាមទិន្នន័យជាក់ស្តែងចំនួនថ្នាក់ច្រើនជាងតម្រូវការថ្នាក់គិតតាមនិយាមចំនួន៦២ថ្នាក់ (១៦៨ថ្នាក់ ដក ១០៦ថ្នាក់)។ រីឯចំនួនគ្រូជាក់ស្តែង ច្រើនជាង តម្រូវការគ្រូតាមនិយាមចំនួន៦នាក់ (១១២នាក់ ដក ១០៦នាក់)។

តាមទិន្នន័យជាក់ស្តែងមានថ្នាក់ចំនួន១៦៨ថ្នាក់ បើតាមច្បាប់កំណត់១ថ្នាក់ត្រូវការគ្រូបង្រៀន១ម្នាក់ នោះត្រូវប្រើប្រាស់គ្រូបង្រៀនចំនួន១៦៨នាក់។ តាមទិន្នន័យដែលទទួលបាន គ្រូបង្រៀនជាក់ស្តែងតិចជាងតម្រូវការជាក់ស្តែងចំនួន៥៦នាក់ (១៦៨នាក់ ដក ១១២នាក់)។

សរុបមកនៅបឋមសិក្សាក្នុងស្រុកពោធិ៍រៀងចំនួនគ្រូបង្រៀនជាក់ស្តែងតិចជាងចំនួនគ្រូបង្រៀនតាមនិយាមអប្បបរមា ប៉ុន្តែបើគិតតាមនិយាមអតិបរមាវិញនោះ គ្រូបង្រៀនជាក់ស្តែងមានចំនួនលើសទៅវិញ។ នេះមានន័យថា មានចំនួនគ្រូបងៀនគ្រប់គ្រាន់នៅបឋមសិក្សាក្នុងស្រុកនេះ បើអនុវត្តតាមនិយាមដែលកំណត់ដោយច្បាប់។ ប៉ុន្តែនៅតែខ្វះគ្រូបង្រៀនសម្រាប់តម្រូវការដែលកំពុងអនុវត្តជាក់ស្តែង ដោយសារតែចំនួនថ្នាក់ជាក់ស្តែងមានចំនួនច្រើនជាងថ្នាក់គិតតាមនិយាម។ ស្ថានភាពនេះបញ្ជាក់ឱ្យឃើញថាការប្រើប្រាស់និយាមសិស្ស-ថ្នាក់តិចជាងចំនួនកំណត់ ដែលកំពុងតែអនុវត្ត ហើយការប្រើប្រាស់គ្រូបង្រៀននៅក្នុងស្រុកពាមរក៍ពុំទាន់មានប្រសិទ្ធភាពនៅឡើយ ។

### ៤.២.១១.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកព្រះស្តេច

នៅក្នុងស្រុកព្រះស្តេចមានសាលាបឋមសិក្សាសរុបចំនួន៦០សាលា ដែលជាក់ស្តែងមានសិស្សសរុបចំនួន១៧៨៨៨នាក់ មានថ្នាក់ចំនួន៥១៣ថ្នាក់ និងប្រើប្រាស់គ្រូបង្រៀនចំនួន២៥៧នាក់ ។

*ក្រាបទី 11៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកព្រះស្តេច*




តាមនិយាមអប្បបរមាត្រូវមានថ្នាក់ចំនួន៤៨១ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ ដល់ទី៣ចំនួន៩៣៥១នាក់ចែក៣៥ស្មើនឹង២៦៧ថ្នាក់ បូក ២១៤ថ្នាក់ដែលបានពីចំនួនសិស្សថ្នាក់ទី៤ ដល់ទី៦ចំនួន៨៥៣៧ចែក៤០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន៤៨១នាក់ ( តាមច្បាប់កំណត់ក្នុង១ថ្នាក់ត្រូវការគ្រូ១នាក់) ។ តាមទិន្នន័យដែលទទួលបានចំនួនថ្នាក់ជាក់ស្តែងច្រើនជាងតម្រូវការថ្នាក់គិតតាមនិយាមចំនួន៣២ថ្នាក់ (៥១៣ថ្នាក់ ដក ៤៨១ថ្នាក់) ។ រីឯចំនួនគ្រូបង្រៀនជាក់ស្តែងក្នុងស្រុកនេះ តិចជាង តម្រូវការគ្រូតាមនិយាមចំនួន២២៤នាក់ (៤៨១នាក់ ដក ២៥៧នាក់)។

តាមនិយាមអតិបរមាត្រូវមានថ្នាក់ចំនួន៣៧៩ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ ដល់ទី៣ចំនួន៩៣៥១នាក់ចែក៤៥ស្មើនឹង២០៨ថ្នាក់ បូក ១៧១ថ្នាក់ដែលបានពីចំនួនសិស្សថ្នាក់ទី៤ ដល់ទី៦ចំនួន៨៥៣៧ចែក៥០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន៣៧៩នាក់ ។ តាមទិន្នន័យជាក់ស្តែងចំនួនថ្នាក់ច្រើនជាងតម្រូវការថ្នាក់គិតតាមនិយាមចំនួន១៣៤ថ្នាក់ (៥១៣ថ្នាក់ ដក ៣៧៩ថ្នាក់)។ រីឯចំនួនគ្រូជាក់ស្តែង តិចជាង តម្រូវការគ្រូតាមនិយាមចំនួន១២២នាក់ (៣៧៩នាក់ ដក ២៥៧នាក់)។

តាមទិន្នន័យជាក់ស្តែងមានថ្នាក់ចំនួន៥១៣ថ្នាក់ បើតាមច្បាប់កំណត់១ថ្នាក់ត្រូវការគ្រូបង្រៀន១នាក់ នោះត្រូវប្រើប្រាស់គ្រូបង្រៀនចំនួន៥១៣នាក់។ តាមទិន្នន័យដែលទទួលបាន គ្រូបង្រៀនជាក់ស្តែងតិចជាងតម្រូវការជាក់ស្តែងចំនួន២៥៦នាក់ (៥១៣នាក់ ដក ២៥៧នាក់)។

សរុបមកនៅបឋមសិក្សាក្នុងស្រុកព្រះស្តេចចំនួនគ្រូបង្រៀនជាក់ស្តែងតិចជាងតម្រូវការគ្រូបង្រៀនគិតតាមនិយាម បើទោះជាគិតតាមនិយាមអប្បបរមា ឬនិយាមអតិបរមាក៏ដោយ ។ នេះមានន័យថាខ្វះគ្រូបង្រៀននៅបឋមសិក្សាយ៉ាងច្រើន បើអនុវត្តតាមនិយាមដែលកំណត់ដោយច្បាប់ ហើយកាន់តែខ្វះគ្រូបង្រៀនសម្រាប់តម្រូវការដែលកំពុងអនុវត្តជាក់ស្តែង ដោយសារតែចំនួនថ្នាក់ជាក់ស្តែងមានចំនួនច្រើនលើសពីតម្រូវការថ្នាក់តាមនិយាម។ ស្ថានភាពនេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្ស-ថ្នាក់តិចជាងចំនួនកំណត់ ដែលកំពុងតែអនុវត្ត ហើយការប្រើប្រាស់គ្រូបង្រៀននៅក្នុងស្រុកកំពង់ត្របែកនៅពុំទាន់មានប្រសិទ្ធភាពនៅឡើយទេ។

### ៤.២.១២.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងក្រុងព្រៃវែង

នៅក្នុងក្រុងព្រៃវែងមានសាលាបឋមសិក្សាសរុបចំនួន១២សាលា ដែលជាក់ស្តែងមានសិស្សសរុបចំនួន ៣៥៦៨នាក់ មានថ្នាក់ចំនួន១២២ថ្នាក់ និងប្រើប្រាស់គ្រូបង្រៀនចំនួន១៣៧នាក់ ។

*ក្រាបទី 12៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងក្រុងព្រៃវែង*




តាមនិយាមអប្បបរមាត្រូវមានថ្នាក់ចំនួន៩៦ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ដល់ទី៣ចំនួន១៨៦២នាក់ចែក៣៥ស្មើនឹង៥៣ថ្នាក់ បូក ៤៣ថ្នាក់ដែលបានពីចំនួនសិស្សថ្នាក់ទី៤ដល់ទី៦ចំនួន១៧០៦ចែក៤០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន៩៦នាក់ (តាមច្បាប់កំណត់ក្នុង១ថ្នាក់ត្រូវការគ្រូ១នាក់) ។ តាមទិន្នន័យដែលទទួលបានចំនួនថ្នាក់ជាក់ស្តែងច្រើនជាងតម្រូវការថ្នាក់គិតតាម

និយាមចំនួន២៦ថ្នាក់ (១២២ថ្នាក់ ដក ៩៦ថ្នាក់) ។ រីឯចំនួនគ្រូបង្រៀនជាក់ស្តែងក្នុងស្រុកនេះវិញ ច្រើនជាង តម្រូវការគ្រូតាមនិយាមចំនួន៤១នាក់ (១៣៧នាក់ ដក ៩៦នាក់)។

តាមនិយាមអតិបរមាត្រូវមានថ្នាក់ចំនួន៧៥ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ដល់ទី៣ចំនួន១៨៦២នាក់ចែក៤៥ស្មើនឹង៤១ថ្នាក់ បូក ៣៤ថ្នាក់ដែលបានពីចំនួនសិស្សថ្នាក់ទី៤ដល់ទី៦ចំនួន១៧០៦ចែក៥០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន៧៥នាក់ ។ តាមទិន្នន័យជាក់ស្តែងចំនួនថ្នាក់ច្រើនជាងតម្រូវការថ្នាក់គិតតាមនិយាមចំនួន៤៧ថ្នាក់ (១២២ថ្នាក់ ដក ៧៥ថ្នាក់)។ រីឯចំនួនគ្រូជាក់ស្តែង ច្រើនជាង តម្រូវការគ្រូតាមនិយាមចំនួន៦២នាក់ (១៣៧នាក់ ដក ៧៥នាក់)។

តាមទិន្នន័យជាក់ស្តែងមានថ្នាក់ចំនួន១២២ថ្នាក់ បើតាមច្បាប់កំណត់១ថ្នាក់ត្រូវការគ្រូបង្រៀន១ម្នាក់ នោះត្រូវប្រើប្រាស់គ្រូបង្រៀនចំនួន១២២នាក់ ។ តាមទិន្នន័យដែលទទួលបាន គ្រូបង្រៀនជាក់ស្តែងច្រើនជាងតម្រូវការជាក់ស្តែងចំនួន១៥នាក់ (១៣៧នាក់ ដក ១២២នាក់)។

សរុបមកនៅបឋមសិក្សាក្នុងក្រុងព្រៃវែងចំនួនគ្រូបង្រៀនជាក់ស្តែងច្រើនជាងតម្រូវការគ្រូគិតតាមនិយាម ទោះបីជាគិតតាមនិយាមអប្បបរមា ឬគិតតាមនិយាមអតិបរមា ។ នេះមានន័យថាលើសគ្រូបង្រៀននៅបឋមសិក្សាយ៉ាងច្រើន បើអនុវត្តតាមនិយាមដែលកំណត់ដោយច្បាប់ ហើយក៏លើសគ្រូបង្រៀនសម្រាប់តម្រូវការដែលកំពុងអនុវត្តជាក់ស្តែងផងដែរ ។ រីឯចំនួនថ្នាក់ជាក់ស្តែងមានចំនួនច្រើនជាងថ្នាក់តាមនិយាម ។ នេះដោយសារតែសាលារៀនភាគច្រើននៅក្នុងថ្នាក់នីមួយៗមានចំនួនសិស្សតិច ។ ស្ថានភាពនេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្ស-ថ្នាក់តិចជាងចំនួនកំណត់ដែលកំពុងតែអនុវត្ត ហើយការប្រើប្រាស់គ្រូបង្រៀននៅក្នុងក្រុងព្រៃវែងពុំទាន់មានប្រសិទ្ធភាពនៅឡើយទេ ។

### ៤.២.១៣.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនបឋមសិក្សាក្នុងស្រុកស៊ីធរកណ្តាល

នៅក្នុងស្រុកស៊ីធរកណ្តាលមានសាលាបឋមសិក្សាសរុបចំនួន៤៧សាលា ដែលជាក់ស្តែងមានសិស្សសរុបចំនួន៨៧៥៨នាក់ មានថ្នាក់ចំនួន៣០៨ថ្នាក់ និងប្រើប្រាស់គ្រូបង្រៀនចំនួន១៩១នាក់ ។

*ក្រាបទី 13៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកស៊ីធរកណ្តាល*




តាមនិយាមអប្បបរមាត្រូវមានថ្នាក់ចំនួន២៣៥ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ ដល់ទី៣ចំនួន៤៥២០នាក់ចែក៣៥ស្មើនឹង១២៩ថ្នាក់ បូក ១០៦ថ្នាក់ដែលបានពីចំនួនសិស្សថ្នាក់ទី៤ ដល់ទី៦ចំនួន៤២៣៨ចែក៤០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន២៣៥នាក់ (តាមច្បាប់កំណត់ ក្នុង១ថ្នាក់ត្រូវការគ្រូ១នាក់) ។ តាមទិន្នន័យដែលទទួលបានចំនួនថ្នាក់ជាក់ស្តែងច្រើនជាងតម្រូវការថ្នាក់ គិតតាមនិយាមចំនួន៧៣ថ្នាក់ (៣០៨ថ្នាក់ ដក ២៣៥ថ្នាក់) ។ រីឯចំនួនគ្រូបង្រៀនជាក់ស្តែងក្នុងស្រុក នេះ តិចជាង តម្រូវការគ្រូតាមនិយាមចំនួន៤៤នាក់ (២៣៥នាក់ ដក ១៩១នាក់)។

តាមនិយាមអតិបរមាត្រូវមានថ្នាក់ចំនួន១៨៥ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ ដល់ទី៣ចំនួន៤៥២០នាក់ចែក៤៥ស្មើនឹង១០០ថ្នាក់ បូក ៨៥ថ្នាក់ដែលបានពីចំនួនសិស្សថ្នាក់ទី៤ដល់ ទី៦ចំនួន៤២៣៨ចែក៥០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន១៨៥នាក់ ។ តាមទិន្នន័យជាក់ស្តែង ចំនួនថ្នាក់ច្រើនជាងតម្រូវការថ្នាក់គិតតាមនិយាមចំនួន១២៣ថ្នាក់ (៣០៨ថ្នាក់ ដក ១៨៥ថ្នាក់) ។ រីឯ ចំនួនគ្រូជាក់ស្តែង ច្រើនជាង តម្រូវការគ្រូតាមនិយាមចំនួន៦នាក់ (១៩១នាក់ ដក ១៨៥នាក់)។

តាមទិន្នន័យជាក់ស្តែងមានថ្នាក់ចំនួន៣០៨ថ្នាក់ បើតាមច្បាប់កំណត់១ថ្នាក់ត្រូវការគ្រូបង្រៀន១ ម្នាក់ នោះត្រូវប្រើប្រាស់គ្រូបង្រៀនចំនួន៣០៨នាក់។ តាមទិន្នន័យដែលទទួលបាន គ្រូបង្រៀនជាក់ស្តែង តិចជាងតម្រូវការជាក់ស្តែងចំនួន១១៧នាក់ (៣០៨នាក់ ដក ១៩១នាក់)។

សរុបមកនៅបឋមសិក្សាក្នុងស្រុកស៊ីធរកណ្តាលចំនួនគ្រូបង្រៀនជាក់ស្តែងតិចជាងចំនួនគ្រូតាមនិយាមអប្បបរមា ប៉ុន្តែបើគិតតាមនិយាមអតិបរមាវិញនោះ គ្រូបង្រៀនជាក់ស្តែងមានចំនួនលើសទៅវិញ ។ នេះមានន័យថា មានចំនួនគ្រូបងៀនគ្រប់គ្រាន់នៅតាមបឋមសិក្សាក្នុងស្រុកនេះ បើអនុវត្តតាមនិយាមដែលកំណត់ដោយច្បាប់ ។ ប៉ុន្តែនៅតែខ្វះគ្រូបង្រៀនសម្រាប់តម្រូវការដែលកំពុងអនុវត្តជាក់ស្តែងដោយសារតែចំនួនថ្នាក់ជាក់ស្តែងមានចំនួនច្រើនជាងថ្នាក់គិតតាមនិយាម ។ ស្ថានភាពនេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្ស-ថ្នាក់តិចជាងចំនួនកំណត់ ដែលកំពុងតែអនុវត្ត ហើយការប្រើប្រាស់គ្រូបង្រៀននៅក្នុងស្រុកពាមរក៍ពុំទាន់មានប្រសិទ្ធភាពនៅឡើយ ។

### ៤.២.១៤.ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងស្រុកស្វាយអន្ទរ

នៅក្នុងស្រុកស្វាយអន្ទរមានសាលាបឋមសិក្សាសរុបចំនួន៥១សាលា ដែលជាក់ស្តែងមានសិស្សសរុបចំនួន១៤០១៧នាក់ មានថ្នាក់សរុបចំនួន៤២៥ថ្នាក់ និងប្រើប្រាស់គ្រូបង្រៀនចំនួន២៤៨នាក់ ។

*ក្រាបទី 14៖ តម្រូវការ ថ្នាក់ គ្រូបង្រៀន តាមនិយាម និងស្ថិតិជាក់ស្តែងក្នុងស្រុកស្វាយអន្ទរ*




តាមនិយាមអប្បបរមាត្រូវមានថ្នាក់ចំនួន៣៧៥ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ដល់ទី៣ចំនួន៦៩១៥នាក់ចែក៣៥ស្មើនឹង១៩៨ថ្នាក់ បូក ១៧៧ថ្នាក់ ដែលបានពីចំនួនសិស្សថ្នាក់ទី៤ដល់ទី៦ចំនួន៧១០២ចែក៤០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន៣៧៥នាក់ (តាមច្បាប់កំណត់ក្នុង១ថ្នាក់ត្រូវការគ្រូ១នាក់)។ តាមទិន្នន័យដែលទទួលបានចំនួនថ្នាក់ជាក់ស្តែងច្រើនជាងតម្រូវការថ្នាក់

គិតតាមនិយាមចំនួន៥០ថ្នាក់ (៤២៥ថ្នាក់ ដក ៣៧៥ថ្នាក់) ។ រីឯចំនួនគ្រូបង្រៀនជាក់ស្តែងក្នុងស្រុកនេះ តិចជាង តម្រូវការគ្រូតាមនិយាមចំនួន១២៧នាក់ (៣៧៥នាក់ ដក ២៤៨នាក់)។

តាមនិយាមអតិបរមាត្រូវមានថ្នាក់ចំនួន២៩៦ថ្នាក់ (បានមកពីការគណនាចំនួនសិស្សថ្នាក់ទី១ ដល់ទី៣ចំនួន៦៩១៥នាក់ចែក៤៥ស្មើនឹង១៥៤ថ្នាក់ បូក ១៤២ថ្នាក់ដែលបានពីចំនួនសិស្សថ្នាក់ទី៤ ដល់ទី៦ចំនួន៧១០២ចែក៥០) ដែលតម្រូវឱ្យប្រើប្រាស់គ្រូបង្រៀនចំនួន២៩៦នាក់ ។ តាមទិន្នន័យជាក់ស្តែងចំនួនថ្នាក់ច្រើនជាងតម្រូវការថ្នាក់គិតតាមនិយាមចំនួន១២៩ថ្នាក់ (៤២៥ថ្នាក់ ដក ២៩៦ថ្នាក់)។ រីឯចំនួនគ្រូជាក់ស្តែង តិចជាង តម្រូវការគ្រូតាមនិយាមចំនួន៤៨នាក់ (២៩៦នាក់ ដក ២៤៨នាក់)។

តាមទិន្នន័យជាក់ស្តែងមានថ្នាក់ចំនួន៤២៥ថ្នាក់ បើតាមច្បាប់កំណត់១ថ្នាក់ត្រូវការគ្រូបង្រៀន១ ម្នាក់ នោះត្រូវប្រើប្រាស់គ្រូបង្រៀនចំនួន៤២៥នាក់។ តាមទិន្នន័យដែលទទួលបាន គ្រូបង្រៀនជាក់ស្តែង តិចជាងតម្រូវការជាក់ស្តែងចំនួន១៧៧នាក់ (៤២៥នាក់ ដក ២៤៨នាក់)។

សរុបមកនៅបឋមសិក្សាក្នុងស្រុកស្វាយអន្ទរចំនួនគ្រូបង្រៀនជាក់ស្តែងតិចជាងតម្រូវការគ្រូបង្រៀនគិតតាមនិយាម បើទោះជាគិតតាមនិយាមអប្បបរមា ឬនិយាមអតិបរមាក៏ដោយ ។ នេះមានន័យថាខ្វះគ្រូបង្រៀននៅបឋមសិក្សាយ៉ាងច្រើន បើអនុវត្តតាមនិយាមដែលកំណត់ដោយច្បាប់ ហើយកាន់តែខ្វះគ្រូបង្រៀនសម្រាប់តម្រូវការដែលកំពុងអនុវត្តជាក់ស្តែង ដោយសារតែចំនួនថ្នាក់ជាក់ស្តែងមានចំនួនច្រើនលើសពីតម្រូវការថ្នាក់តាមនិយាម ។ ស្ថានភាពនេះបញ្ជាក់ឱ្យឃើញថា ការប្រើប្រាស់និយាមសិស្ស-ថ្នាក់តិចជាងចំនួនកំណត់ ដែលកំពុងតែអនុវត្ត ហើយការប្រើប្រាស់គ្រូបង្រៀននៅក្នុងស្រុកកំពង់ត្របែក នៅពុំទាន់មានប្រសិទ្ធភាពនោះទេ ។

## ៤.៣.បញ្ហាប្រឈម និងដំណោះស្រាយ

តាមទិន្នន័យដែលទទួលបានពីការឆ្លើយតបរបស់នាយកនៃសាលាបឋមសិក្សាចំនួន៤៧៦សាលា នៅក្នុងខេត្តព្រៃវែង ភាគច្រើននៃពួកគាត់បានឆ្លើយថាការកង្វះគ្រូបង្រៀនជាបញ្ហាប្រឈមដ៏សំខាន់ដែលកំពុងជួបប្រឈមប្រទះ ជាពិសេសសាលាបឋមសិក្សាដែលស្ថិតនៅតំបន់ជនបទជួបការលំបាក ហើយក៏ធ្វើឱ្យមានការពិបាកក្នុងការធ្វើបំណែងចែក និងស្វែងរកគ្រូមកបង្រៀន ការរៀបចំដំណើរការរៀន និងបង្រៀន

ជាដើម។ នេះក៏ស្របទៅនឹងការបញ្ជាក់របស់លោកប្រធានការិយាល័យបុគ្គលិកនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែងផងដែរថា "ខេត្តព្រៃវែងមានការខ្វះគ្រូបង្រៀនជាច្រើនទាំងនៅបឋមសិក្សា និងនៅមធ្យមសិក្សា"។ លោកក៏បានបន្ថែមផងដែរថា ដើម្បីដោះស្រាយនៅបញ្ហានៃការខ្វះគ្រូបង្រៀនយ៉ាងច្រើនបែបនេះ មន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង បានពិនិត្យមើលលទ្ធភាពដោយផ្អែកលើស្ថានភាពជាក់ស្តែង និងមូលដ្ឋាននៃច្បាប់ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ដែលមានចែងក្នុងសេចក្តីណែនាំលេខ ២០អយក.សណន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ ស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ មន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែងបានសម្រេចមិនទាន់អនុវត្តតាមនិយាមថ្មីនោះទេ គឺនៅបន្តការអនុវត្តតាមនិយាមចាស់ដែលកំណត់ដោយក្រសួងតាមរយៈសេចក្តីណែនាំលេខ២៥៦អយក.សណន ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០២ ស្តីពីការកំណត់និយាមប្រើប្រាស់មន្ត្រីរាជការ សម្រាប់សាលាមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងសាលាគរុកោសល្យ។

*ក្រាបទី 15៖ ស្ថានភាពជាក់ស្តែងនៃការដោះស្រាយបញ្ហាលើសខ្វះគ្រូនៅបឋមសិក្សាក្នុងខេត្តព្រៃវែង*




ជាដំណោះស្រាយចំពោះមុខ សាលាបឋមសិក្សានីមួយៗ បានរៀបចំឱ្យមានគ្រូបង្រៀនពីរថ្នាក់ពីរពេល គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនជាប់កិច្ចសន្យា និងគ្រូបង្រៀនដែលខ្ចីពីអង្គភាពដទៃ ដើម្បីជំរុញដល់ដំណើរការរៀន និងបង្រៀនទៅតាមស្ថានភាពជាក់ស្តែងរបស់សាលារៀនរៀងៗខ្លួន។ តាមរយៈក្រាបនេះ បានបង្ហាញឱ្យឃើញថា ចំនួនគ្រូបង្រៀនជាក់ស្តែងមានចំនួនតែ៦៦.៦%នៃចំនួនថ្នាក់សរុបជាក់ស្តែង ៤០១៧ថ្នាក់នៃសាលាចំនួន៤៧៦ដែលនាយកបានបំពេញកម្រងសំណួរប៉ុណ្ណោះ។ មានន័យថា បើថ្នាក់

មួយត្រូវការគ្រូបង្រៀនម្នាក់ នោះនៅសល់ថ្នាក់៣៣.៤%ទៀតស្មើនឹង១៣៤០ថ្នាក់ ដែលត្រូវការរកដំណោះស្រាយក្នុងការស្វែងរកគ្រូមកបង្រៀន។ យ៉ាងដូច្នេះហើយ នៅបឋមសិក្សានៅក្នុងខេត្តព្រៃវែងតម្រូវឱ្យមានការប្រើប្រាស់គ្រូបង្រៀនថ្នាក់ពីរពេលប្រមាណជា៣៨.៩%នៃថ្នាក់សរុបជាក់ស្តែង គ្រូបង្រៀនថ្នាក់គួបប្រមាណជា៣.១% គ្រូបង្រៀនជាប់កិច្ចសន្យា ប្រមាណជា៥.៤% និងគ្រូបង្រៀនក្របខណ្ឌដែលខ្ចីមកពីអង្គភាពផ្សេងប្រមាណជា២.៧%។ ដំណោះស្រាយទាំងនេះបានធ្វើឱ្យសាលារៀនអាចដំណើរការបង្រៀន និងរៀនបាន ប៉ុន្តែបែរធ្វើឱ្យលេចចេញនូវបញ្ហាប្រឈមមួយចំនួនដែលគួរឱ្យយកចិត្តទុកដាក់ផងដែរ បើយោងតាមឆ្លើយតបតាមរយៈការបំពេញកម្រងសំណួររបស់នាយកសាលា ពាក់ព័ន្ធនឹងគ្រូបង្រៀនខ្វះវិធីសាស្ត្រក្នុងការគ្រប់គ្រងការបង្រៀន និងរៀនចំពោះថ្នាក់គួបដោយសារតែមិនដែលឆ្លងការបណ្តុះបណ្តាលការបង្រៀនថ្នាក់គួប គ្រូបង្រៀនថ្នាក់ពីរពេលគ្មានពេលវេលាគ្រប់គ្រាន់ក្នុងការផលិតសម្ភារៈឧបទេស ការចូលបង្រៀនយឺតពេល ដែលធ្វើឱ្យសិស្សានុសិស្សរៀនមិនបានពេញម៉ោង និងរៀនមិនចប់កម្មវិធីសិក្សា។ បើទោះជាភាគច្រើននៃសាលាបឋមសិក្សាក្នុងខេត្តព្រៃវែងខ្វះគ្រូបង្រៀនយ៉ាងច្រើនក៏ដោយក៏មានសាលាបឋមសិក្សាមួយចំនួនលើសគ្រូបង្រៀនផងដែរ ជាពិសេសសាលារៀនដែលស្ថិតនៅតំបន់ទីប្រជុំជន។ ចំពោះដំណោះស្រាយ នាយកសាលាបានរាយការណ៍ទៅការិយាល័យអប់រំ យុវជន និងកីឡាស្រុក និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តជ្រាបជារបាយការណ៍ និងធ្វើការបែងចែកផ្តល់ភារកិច្ចឱ្យទទួលតាមផ្នែកនៅក្នុងសាលា ជាគ្រូជំនួយ និងជួយកិច្ចការសាលាដូចជា បង្រៀនជំនួស ជួយផលិតសម្ភារៈឧបទេស ជួយការងារបច្ចេកទេស និងការងាររដ្ឋបាលផ្សេងៗជាដើម។

សរុបសេចក្តីមកនៅបឋមសិក្សាក្នុងខេត្តព្រៃវែងមានការដោះស្រាយបញ្ហាលើសខ្វះគ្រូបង្រៀនមានលក្ខណៈល្អប្រសើរដោយបានអនុវត្តទៅតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការប្រើប្រាស់ ទាំងគ្រូបង្រៀនក្របខ័ណ្ឌ គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់ពីរពេល និងគ្រូបង្រៀនថ្នាក់គួប ដើម្បីជំរុញឱ្យមានប្រសិទ្ធភាព។

## ៤.៤.សំណូមពររបស់នាយកសាលាចំពោះបញ្ហាលើសខ្វះគ្រូបង្រៀន

ការស្នើសុំគ្រូបង្រៀន ដើម្បីដោះស្រាយបញ្ហាខ្វះគ្រូរបស់នាយកសាលាបឋមសិក្សាចំនួន៤៧៦ សាលាក្នុងខេត្តព្រៃវែង ដែលបានបំពេញកម្រងសំណួរត្រូវបានបង្ហាញនៅក្នុងតារាងខាងក្រោម ៖

*ក្រាបទី 16៖ ការឆ្លើយតបរបស់នាយកចំពោះការស្នើសុំគ្រូបង្រៀននៅរយៈពេល៥ឆ្នាំចុងក្រោយ*




ក្រាបទី១៦ខាងលើបង្ហាញឱ្យឃើញថាតាមការស្រង់មតិអំពីការស្នើសុំបន្ថែមគ្រូបង្រៀននៅរយៈពេល៥ឆ្នាំចុងក្រោយ របស់នាយកសាលាចំនួន៤៧៦នាក់ក្នុងចំណោម៥៤៧សាលាក្នុងខេត្តព្រៃវែង មាន ៩.៩ភាគរយ ឆ្លើយថាទទួលបានចំនួនគ្រប់គ្រាន់តាមការស្នើសុំ ៤៧.៣ភាគរយឆ្លើយថាទទួលបានខ្លះ ២៦.៩ភាគរយឆ្លើយថាមិនទទួលបាន ១៤.៧ភាគរយឆ្លើយថាមិនបានស្នើសុំ ០.៦ភាគរយមិនបានឆ្លើយតប និងមានប្រមាណជា០.៦ភាគរយទៀតបានឆ្លើយថាសាលារបស់ពួកគាត់ជាសាលាទើបបង្កើតថ្មី មានគ្រូផ្ទេរចូលពីសាលាស្រុកផ្សេងដែលមានបានស្នើសុំ និងបានទទួលខ្លះដែរប៉ុន្តែដល់គ្រប់ឆ្នាំបំពេញការងារក៏ផ្លាស់ប្តូរទៅវិញ ។ បើគិតទៅលើភាគរយដែលខ្ពស់ជាងគេនោះ សាលាបឋមសិក្សាភាគច្រើននៅក្នុងខេត្តព្រៃវែង មិនទាន់ទទួលបានគ្រូបង្រៀនគ្រប់តាមតម្រូវការនោះទេ ហើយការបែងចែកគ្រូក៏នៅមានចំនួនកំណត់នៅឡើយ។ នេះបញ្ជាក់ឱ្យឃើញថានៅបឋមសិក្សាក្នុងខេត្តព្រៃវែងពុំទាន់ទទួលបានគ្រូបង្រៀនតាមតម្រូវការ និងតាមការស្នើសុំនោះទេ។

*ក្រាបទី 17៖ សំណូមពររបស់នាយកសាលាចំពោះបញ្ហាលើសខ្វះគ្រូបង្រៀន*




តាមការបំពេញកម្រងសំណួររបស់នាយកសាលាបឋមសិក្សាចំនួន៤៧៦នាក់បានធ្វើការសំណូមពរដល់ក្រសួងអប់រំ យុវជន និងកីឡាចំពោះករណីខ្វះគ្រូបង្រៀន ក្នុងចំណោមនោះនាយកសាលាចំនួន៦៨.៩ភាគរយ សូមឱ្យក្រសួងផ្តល់គ្រូថ្មីបន្ថែម, ២៧.៧ភាគរយ ស្នើសុំផ្តល់ប្រាក់ឧបត្ថម្ភបន្ថែម, ២៩.៨ភាគរយ កែប្រែប្រព័ន្ធជ្រើសរើសគ្រូដោយយកចេញពីមូលដ្ឋាន ឬសហគមន៍, ១៥.៨ភាគរយ ការបញ្ចូលគ្រូបង្រៀនកិច្ចសន្យាទៅជាគ្រូក្របខណ្ឌពេញសិទ្ធិ និង១.៣ភាគរយមិនបញ្ចេញមតិយោបល់ និង១.៧ភាគរយមានមតិយោបល់ផ្សេងៗដែលពួកគាត់ចង់ឱ្យប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាល្អជាជាងការប្រើប្រាស់គ្រូបង្រៀនពីរថ្នាក់ពីរវេន និងគ្រូបង្រៀនថ្នាក់គួប ការពង្រឹងសមត្ថភាពគ្រូដែលមានស្រាប់បន្ថែម

ទៀត និងសូមក្រសួងផ្តល់គ្រូថ្មីបន្ថែមឱ្យបានគ្រប់គ្រាន់ ជាជាងការប្រើប្រាស់គ្រូបង្រៀនពីរថ្នាក់ពីរពេល គ្រូបង្រៀនថ្នាក់គួប ឬគ្រូបង្រៀនជាប់កិច្ចសន្យា ក្នុងគោលបំណងធានាគុណភាពអប់រំឱ្យមានលក្ខណៈល្អប្រសើរ។

ចំពោះករណីលើសគ្រូបង្រៀនវិញ តាមការឆ្លើយតបរបស់នាយកសាលាឃើញថា ២២.៥ភាគរយប្រើគោលការណ៍ប្តូរវេនសាលាក្នុងស្រុករយៈពេល៣ឆ្នាំម្តង ៣៧.៨ភាគរយត្រូវការផ្តល់លើកទឹកចិត្តបន្ថែមលើប្រាក់បៀវត្សន៍រៀងរាល់ខែចំពោះអ្នកស្ម័គ្រចិត្តពង្រាយទៅសាលាដែលកំពង់ខ្វះគ្រូ ២៣.៣ភាគរយផ្តល់ឱ្យនូវកាំប្រាក់១ឆ្នាំម្តង ឬប្រាក់បំណាច់មុខងារពិសេសដល់គ្រូស្ម័គ្រចិត្តពង្រាយ, ១៣ភាគរយលើកទឹកចិត្តដោយផ្តល់ឱកាសក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ ១៣.៩ភាគរយមិនមានមតិយោបល់ និង ១.៩ ភាគរយទៀត មានមតិយោបល់ផ្សេងៗតាមការយល់ឃើញរបស់ពួកគាត់ដូចជា ប្តូរវេនបង្រៀន១ឆ្នាំម្តងក្នុងសាលា, ស្នើសុំឱ្យមានអនុវត្តគោលការណ៍ពង្រាយគ្រូ ដើម្បីធានាមានគុណភាពនៃការអប់រំ និងសំណូមពរឱ្យក្រសួងអប់រំ យុវជន និងកីឡា ផ្តល់គ្រូបង្រៀនទៅតាមតម្រូវការជាក់ស្តែងរបស់សាលា។

សរុបមកតាមខ្លឹមសារនៃសំណូមពរដែលមានភាគរយខ្ពស់របស់លោកនាយក/នាយិកាសាលា និងអ្វីដែលជាបំណងចម្បងរបស់ពួកគាត់ គឺការផ្តល់គ្រូក្របខណ្ឌបឋមសិក្សាថ្មីបន្ថែមក្នុងករណីខ្វះគ្រូបង្រៀន និងផ្តល់ប្រាក់លើកទឹកចិត្តបន្ថែមលើប្រាក់បៀវត្សរាល់ខែចំពោះអ្នកស្ម័គ្រចិត្តពង្រាយទៅតំបន់ដែលកំពុងខ្វះគ្រូបង្រៀន។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១.សេចក្តីសន្និដ្ឋាន

ផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានធ្វើការសន្និដ្ឋានជារួមថា ការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងខេត្តព្រៃវែងពុំទាន់មានប្រសិទ្ធភាពនៅឡើយនោះទេ។ ខេត្តព្រៃវែងកំពុងតែប្រឈមនឹងបញ្ហាខ្វះគ្រូបង្រៀនកម្រិតបឋមយ៉ាងច្រើនដែលត្រូវទៅបង្រៀននៅសាលាបឋមសិក្សានានា ។ តាមលទ្ធផលសិក្សាទៅលើសាលាបឋមសិក្សាទាំង៥៤៧សាលាក្នុងខេត្តព្រៃវែង បានឱ្យឃើញថាបើតាមនិយាមអប្បបរមានៅខ្វះគ្រូបង្រៀនចំនួន១២៨៦នាក់ ហើយបើគិតតាមនិយាមអតិបរមាវិញ នៅខ្វះគ្រូបង្រៀនចំនួន៤៤២នាក់ ដែលភាគច្រើនខ្វះនៅសាលាក្នុងតំបន់ជនបទ ជាពិសេសនៅតំបន់ជួបការលំបាក។ ប៉ុន្តែសម្រាប់តម្រូវការជាក់ស្តែងដែលកំពុងអនុវត្តវិញនោះនៅខ្វះគ្រូបង្រៀនរហូតដល់ទៅចំនួន១៨៤២នាក់ឯណោះ ហើយមានតែនៅក្រុងព្រៃវែងមួយប៉ុណ្ណោះដែលលើសគ្រូបង្រៀនចំនួន១៥នាក់។ អ្នកស្រាវជ្រាវក៏បានរកឃើញផងដែរថា ការអនុវត្តន៍និយាមសិស្សថ្នាក់នៅបឋមសិក្សាក្នុងខេត្តព្រៃវែងមិនបានត្រឹមត្រូវតាមនិយាមសិស្សថ្នាក់ដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា នោះទេ។ ពោលគឺមានចំនួនថ្នាក់ជាក់ស្តែងច្រើនជាងចំនួនថ្នាក់គិតតាមនិយាម។ មូលហេតុចម្បងមួយដែលអ្នកស្រាវជ្រាវបានរកឃើញនោះគឺដោយសារតែសាលាបឋមសិក្សាភាគច្រើន នៅក្នុងថ្នាក់នីមួយៗមានចំនួនសិស្សតិច។ នៅក្នុងចំណោមថ្នាក់សរុបជាក់ស្តែងទាំងអស់មានតែប្រមាណជា៤៦.៥%ប៉ុណ្ណោះដែលអាចអនុវត្តបានត្រឹមត្រូវតាមនិយាម ហើយចំនួនថ្នាក់រហូតដល់ទៅប្រមាណជា៥១.១% ដែលមានចំនួនសិស្សតិចជាងនិយាម និងក៏មានថ្នាក់ដែលមានចំនួនសិស្សច្រើនប្រមាណជា២.៤%ផងដែរ។ ដើម្បីដោះស្រាយបញ្ហាកង្វះគ្រូបង្រៀនយ៉ាងច្រើននៅតាមសាលាបឋមសិក្សា មន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង បានពិនិត្យ និងសម្រេច រក្សាការអនុវត្តតាមសេចក្តីណែនាំលេខ២៥៦អយក.សណន ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០២ ស្តីពីការកំណត់និយាមប្រើប្រាស់មន្ត្រីរាជការ ពុំបានអនុវត្តតាមសេចក្តីណែនាំថ្មីលេខ២០អយក.សណន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ស្តីពីនិយាមប្រើបុគ្គលិកអប់រំនោះទេ និងព្យាយាមដោះស្រាយ

ដោយប្រើប្រាស់គ្រូបង្រៀនថ្នាក់ពីរពេល គ្រូបង្រៀនថ្នាក់គួប គ្រូបង្រៀនកិច្ចសន្យា និងគ្រូបង្រៀនក្របខណ្ឌដែលខ្ចីមកពីអង្គភាពផ្សេង។ បើទោះជាការដោះស្រាយបញ្ហាលើសខ្វះគ្រូបង្រៀនហាក់ដូចជាមានលក្ខណៈល្អប្រសើរ និងបត់បែនតាមស្ថានភាពជាក់ស្តែងក៏ដោយ ប៉ុន្តែក៏មានការលេចចេញនូវបញ្ហាប្រឈមមួយចំនួនផងដែរ ដែលធ្វើឱ្យមានការពិបាកដល់គណៈគ្រប់គ្រងសាលាក្នុងការរៀបចំដំណើរការបង្រៀននិងរៀន ក្នុងការធ្វើបំណែងចែក និងការស្វែងរកគ្រូមកបង្រៀន គ្រូបង្រៀនខ្វះវិធីសាស្ត្រក្នុងការគ្រប់គ្រងការបង្រៀននិងរៀនចំពោះថ្នាក់គួបដោយសារតែមិនដែលឆ្លងការបណ្តុះបណ្តាលការបង្រៀនថ្នាក់គួប គ្រូបង្រៀនថ្នាក់ពីរពេលគ្មានពេលវេលាគ្រប់គ្រាន់ក្នុងការផលិតសម្ភារៈឧបទេស គ្រូចូលបង្រៀនយឺតពេល ដែលធ្វើឱ្យសិស្សានុសិស្សរៀនមិនបានពេញម៉ោង និងរៀនមិនចប់កម្មវិធីសិក្សា។

## ៥.២.សំណូមពរ

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវបានរកឃើញបង្ហាញថា ការប្រើប្រាស់គ្រូបង្រៀននៅតាមសាលាបឋមសិក្សានានាក្នុងខេត្តព្រៃវែងពុំទាន់មានប្រសិទ្ធភាពនៅឡើយ អ្នកស្រាវជ្រាវ សូមលើកឡើងនូវសំណូមពរមួយចំនួន ដើម្បីជួយកែលម្អចំណុចខ្វះខាត ដែលភាគីពាក់ព័ន្ធនានាមានដូចជា ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាខេត្ត គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន ត្រូវរួមគ្នាដោះស្រាយជាប្រព័ន្ធក្នុងការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់គ្រូបង្រៀនឱ្យកាន់តែល្អប្រសើរឡើង។

- ក្រសួងអប់រំ យុវជន និងកីឡាគួរជ្រើសរើសគ្រូបង្រៀនកម្រិតបឋមសិក្សាបន្ថែមដោយមិនគ្រាន់តែធ្វើការសិក្សាទៅលើតម្រូវការតាមនិយាមដែលកំណត់ដោយច្បាប់ ហើយក៏ត្រូវសិក្សាលើស្ថានភាពតម្រូវការគ្រូជាក់ស្តែងផងដែរ ព្រមទាំងផ្តល់ទៅឱ្យសាលាដែលកំពុងជួបបញ្ហាខ្វះគ្រូបង្រៀន និងបើកវគ្គបណ្តុះបណ្តាល ឬវគ្គបំប៉ននានាស្តីអំពីការបង្រៀនថ្នាក់គួប ការបង្រៀនថ្នាក់ពីរពេល ដល់នាយកសាលាបឋមសិក្សា និងគ្រូបង្រៀនដែលត្រូវបង្រៀនថ្នាក់ទាំងនេះផងដែរ។
- មន្ទីរអប់រំ យុវជន និងកីឡាខេត្តគួរធ្វើការការបែងចែកគ្រូបង្រៀន ដោយសិក្សាឱ្យបានច្បាស់លាស់អំពីតម្រូវការគ្រូបង្រៀនជាក់ស្តែងនៅតាមសាលាបឋមសិក្សាដែលកំពុងខ្វះគ្រូបង្រៀន និងសូមចុះពិនិត្យ កែលម្អ និងផ្តល់អនុសាសន៍ ចំពោះចំណុចខ្វះខាតរបស់សាលារៀន។

- គណៈគ្រប់គ្រងសាលារៀនរៀបចំការប្រើប្រាស់គ្រូបង្រៀន និងធនធានដែលមានឱ្យអស់លទ្ធភាព ប្រកបដោយប្រសិទ្ធភាព ព្រមទាំងការសហការ និងគាំទ្រជានិច្ចចំពោះការខិតខំប្រឹងប្រែងជួយគ្រូបង្រៀនក្នុងដំណើរការរៀន និងបង្រៀន ។
- គ្រូបង្រៀនធ្វើការបង្ហាត់បង្រៀនសិស្សប្រកបដោយទឹកចិត្តអាណិត និងក្តីស្រឡាញ់ និងគោរពតាមការចាត់តាំងរបស់គណៈគ្រប់គ្រងសាលា និងប្រឹងប្រែងបំពេញការងារប្រកបដោយមនសិកាវិជ្ជាជីវៈខ្ពស់ ដើម្បីលទ្ធផលការងារប្រកបដោយប្រសិទ្ធភាព។

## ៥.៣.អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត

ការសិក្សាស្រាវជ្រាវនេះ ផ្តោតតែលើការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងខេត្តព្រៃវែង ហើយការប្រមូលទិន្នន័យចម្បង គឺយកចេញពីមតិយោបល់របស់នាយកសាលាតែប៉ុណ្ណោះ និងទិន្នន័យបន្ទាប់បន្សំយកពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ហើយសម្រាប់អ្នកស្រាវជ្រាវបន្តទៀត អាចពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម៖

- សិក្សាលើការប្រើប្រាស់គ្រូបង្រៀននៅខេត្តព្រៃវែងដដែល ឬនៅខេត្តដទៃទៀតដោយប្រើប្រាស់ពេលវេលាស្រាវជ្រាវឱ្យបានសមស្រប និងផ្តោតឱ្យបានស៊ីជម្រៅចំពោះការប្រើប្រាស់គ្រូបង្រៀននៅតំបន់ជនបទជួបការលំបាក។
- ស្រាវជ្រាវលើប្រធានបទដដែល ដោយជ្រើសរើសក្រុមគោលដៅ នៃការប្រមូលទិន្នន័យចេញពីនាយក នាយករង និងគ្រូបង្រៀន តាមរយៈការជួបផ្ទាល់ជាមួយអ្នកឆ្លើយសំណួរតែម្តង។

# ឯកសារយោង


1.Bokova, J. (២០១៥). *វិស័យអប់រំឆ្នាំ២០៣០* . InCheon.

2.CAMBRIDGE, U. P. (2020). *Dictionary*. Retrieved from Cambridge Dictonary: https://dictionary.cambridge.org/dictionary/english/utilization

3.Collins, C. (2020). *Dictionary*. Retrieved from Collions: https://www.collinsdictionary.com/dictionary/english/efficiency

4.IJSRESSD. (2019). *Utilization of the Primary School Teachers in Ogun Central Senatorial District, Nigeria.* Nigeria: University Of Benin.

5.Phumsas. (២០១៦, តុលា ១៣). *Prey Veng*. Retrieved from ភូមិសាស្ត្រស្រុកខ្មែរ: http://phumsas.blogspot.com/2016/10/prey-veng.html

6.Wikipedia. (2020, 12 03). *ព្រៃវែង*. Retrieved from វិគីភីឌា: https://km.wikipedia.org/wiki/

7.ក្រសួងអប់រំ យុវជន និងកីឡា. (២០១៦). *ផែនការសកម្មភាព ស្ដីពីធនធានមនុស្សក្នុងវិស័យអប់រំ.*

8.ក្រសួងអប់រំ យុវជន និងកីឡា. (២០១៨). *ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន.* ភ្នំពេញ.

9.ក្រសួងអប់រំ យុវជន និងកីឡា. (២០១៨). *យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨-២០២៣.* ភ្នំពេញ.

10.ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩). *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ.* ភ្នំពេញ.

11.ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩). *ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០.* ភ្នំពេញ.

12.ក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានជាសកលលើការអប់រំសម្រាប់ទាំងអស់គ្នា. (២០១៥).*ការអប់រំសម្រាប់ទាំងអស់គ្នា២០០០-២០១៥៖សមិទ្ធផល និងបញ្ហាប្រឈម.* ភ្នំពេញ: UNESCO.

13.គណៈកម្មការ"PAP". (២០០០). *ឯកសារការគ្រប់គ្រងសម្រាប់នាយកសាលាបឋមសិក្សា.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា.

14.ណាត, ជ. (២០០៨). *វចនានុក្រម.* រក្សាសិទ្ធដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត.

15.នាយកដ្ឋានបឋមសិក្សា. (២០១៧). *ស្តង់ដាសាលាបឋមសិក្សា.* ក្រសួងអប់រំ យុវជន និងកីឡា.

16.នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ. (២០២០). *ស្ថិតិ និងសូចនាករអប់រំសាធារណៈ.* ភ្នំពេញ.

17.នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា. (២០១៥). *ក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស.* ភ្នំពេញៈ ក្រសួងអប់រំ យុវជន និងកីឡា.

18.បណ្ឌិតធម្មណាត. (២០១៨, March ២២). *Home*. Retrieved from WatKhmer: https://watkhmers.org/គរុ-គ្រូ/

19.ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២. (២០០៧). *ច្បាប់ស្តីពីការអប់រំ.* ភ្នំពេញ.

20.វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ. (២០១៩). *ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៩.* ភ្នំពេញ.

21.សន្និបាតបូកសរុបលទ្ធផលការងារ, ក. យ. (២០១៩). *សន្និបាតបូកសរុបលទ្ធផលការងារ អប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៧-២០១៨.* ភ្នំពេញ.

22.សុធីរ, ប. (២០២០). *សន្ទរកថាស្វាគមន៍បើកសន្និបាតបូកសរុប វាយតម្លៃការងារអប់រំ យុវជន និង កីឡាឆ្នាំសិក្សា២០១៨-២០១៩ និងលើកទិសដៅសកម្មភាពឆ្នាំសិក្សា២០១៩-២០២០.* ព្រៃវែង.

23.សុផន, ន. (២០២០). *ឯកសារបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈស្តីពីការគ្រប់គ្រងបុគ្គលិកអប់រំ.* ភ្នំពេញៈ វិទ្យាស្ថានជាតិអប់រំ.

24.សេចក្តីណែនាំលេខ៥៣អយក.សណន. (២០១៩). *ស្តីពីការគ្រប់គ្រងគ្រូបង្រៀន.* ភ្នំពេញៈ ក្រសួងអប់រំ យុវជន និងកីឡា.

25.អនុក្រឹត្យលេខ១២៦អនក្រ.បក. (២០០៨). *ស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន.* ភ្នំពេញៈ រាជរដ្ឋាភិបាលកម្ពុជា.

26.អនុក្រឹត្យលេខ៣០៩អនក្រ.បក. (២០១៤). *ស្តីពីការគ្រប់គ្រង និងការចាត់ចែងសេវាបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ.* ភ្នំពេញៈ រាជរដ្ឋាភិបាល.

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ កម្រងសំណួរសម្រាប់ការចុះប្រមូលទិន្នន័យពីនាយកសាលាបឋមសិក្សា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំយុវជន និងកីឡា**
**វិទ្យាស្ថានជាតិអប់រំ**

**ប្រធានបទស្រាវជ្រាវ ៖**

**ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា ក្នុងខេត្តព្រៃវែង**

**គោលបំណងនៃការស្រាវជ្រាវ៖**

១. សិក្សាពីស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងខេត្តព្រៃវែង។

២. ស្វែងយល់ពីបញ្ហាប្រឈម និងដំណោះស្រាយរបស់នាយក/នាយិកា នៅក្នុងការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សាក្នុងខេត្តព្រៃវែង។

*ខ្ញុំបាទ ឈ្មោះ **ប៊ិន សុផាន់ណាក់** ជានិស្សិត **ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ** ជំនាន់ទី៣ ដែលកំពុងសិក្សានៅ **វិទ្យាស្ថានជាតិអប់រំ** ត្រូវបានចាត់តាំងឱ្យ ចុះប្រមូលទិន្នន័យ ស្តីពីការប្រើប្រាស់គ្រូបង្រៀននៅសាលាបឋមសិក្សានានាក្នុងខេត្តព្រៃវែង។ ការប្រមូលទិន្នន័យនេះ ក្នុងគោលបំណងដើម្បីសរសេរនិក្ខេបបទបញ្ចប់វគ្គសិក្សា។*

***ការរក្សាការសម្ងាត់***

*ព័ត៌មានដែលទទួលបានពី លោក លោកស្រី នឹងត្រូវរក្សាការសម្ងាត់ ។ អត្តសញ្ញាណរបស់លោក លោកស្រី មិនត្រូវបានបង្ហាញក្នុងការស្រាវជ្រាវនេះទេ។*

**<u>កម្រងសំណួរសម្រាប់សម្ភាសន៍នាយក/នាយិកាសាលា</u>**

**ផ្នែកទី១៖ ស្ថានភាពទូទៅនៃទីតាំងសាលារៀន**

១.តើសាលាបឋមសិក្សារបស់លោក~លោកស្រី មានឈ្មោះអ្វី?

- សាលាបឋមសិក្សា...................................

២.តើសាលា របស់លោក~លោកស្រី មានទីតាំងស្ថិតក្នុងស្រុកណា?

- ក្នុងស្រុក...............................................

៣.ទីតាំងសាលារៀន ៖ ☐តំបន់ទីប្រជុំជន ☐តំបន់ជនបទ ☐តំបន់ជួបការលំបាក

**ផ្នែកទី២៖ ការកំណត់ពីតម្រូវការ បញ្ហាប្រឈម និងដំណោះស្រាយ**

៤.តើសាលា របស់លោក~លោកស្រី មានចំនួនសិស្សប៉ុន្មាននាក់ និងចំនួនថ្នាក់ប៉ុន្មាន?

- ថ្នាក់ទី១៖ ចំនួនសិស្ស.......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់
- ថ្នាក់ទី២៖ ចំនួនសិស្ស.....................នាក់ ចំនួនថ្នាក់៖.................ថ្នាក់

1

- ថ្នាក់ទី៣៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់
- ថ្នាក់ទី៤៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់
- ថ្នាក់ទី៥៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់
- ថ្នាក់ទី៦៖ ចំនួនសិស្ស......................នាក់ ចំនួនថ្នាក់៖.................ថ្នាក់

**ចំនួនសិស្សសរុប៖ .................. នាក់ ចំនួនថ្នាក់សរុប៖............. ថ្នាក់**

៥.តើសាលារបស់លោកលោកស្រី មានបុគ្គលិកអប់រំសរុបចំនួនប៉ុន្មាននាក់ ? (មិនរាប់គ្រូមត្តេយ្យសិក្សា)

- ចំនួនបុគ្គលិកសរុប..................នាក់ ស្រី................នាក់
- បុគ្គលិកមិនបង្រៀន ................នាក់ ស្រី................នាក់ (រាប់ លេខា បណ្ណារក្ស...)
- បុគ្គលិកបង្រៀន ................នាក់ ស្រី......................នាក់

៦.តើគ្រូក្របខណ្ឌដែលកំពុង**បង្រៀនពីរវេន** មានចំនួនប៉ុន្មាននាក់?

- ចំនួនសរុប.......................នាក់ ស្រី......................នាក់

៧.តើគ្រូក្របខណ្ឌដែលកំពុង**បង្រៀនថ្នាក់គួប** មានចំនួនប៉ុន្មាននាក់?

- ចំនួនសរុប.......................នាក់ ស្រី......................នាក់

៨.តើគ្រូក្របខណ្ឌដែលមកពីកន្លែងផ្សេងកំពុងជួយបង្រៀន មានចំនួនប៉ុន្មាននាក់?

- ចំនួនសរុប.......................នាក់ ស្រី......................នាក់

៩.តើ**គ្រូជាប់កិច្ចសន្យា**កំពុងជួយបង្រៀន មានចំនួនប៉ុន្មាននាក់?

- ចំនួនសរុប.......................នាក់ ស្រី......................នាក់

១០.តើលោក~លោកស្រី ជួបបញ្ហាប្រឈមអ្វីខ្លះ ក្នុងស្ថានភាពលើសឬខ្វះគ្រូនៅក្នុងសាលារបស់អ្នក?

.....................................................................................................................

.....................................................................................................................

.....................................................................................................................

១១.តើលោក~លោកស្រី ដោះស្រាយបញ្ហាខ្វះ ឬលើសគ្រូយ៉ាងដូចម្តេច?

- ករណីខ្វះ ........................................................................................................

.....................................................................................................................

.....................................................................................................................

- ករណីលើស........................................................................................................

.....................................................................................................................

.....................................................................................................................

2

**ផ្នែកទី៣៖ សំណូមពររបស់នាយកសាលារៀនចំពោះបញ្ហាលើសខ្វះគ្រូបង្រៀន**

១២.តើសាលាលោកលោកស្រីបានទទួលចំនួនគ្រូតាមការស្នើសុំដែរទេ រយៈពេល៥ឆ្នាំចុងក្រោយនេះ?

ចំនួនគ្រូទទួលបានតាមការស្នើសុំគឺ៖

☐ គ្រប់ចំនួន ☐ ទទួលបានខ្លះ ☐ មិនទទួលបាន ☐ មិនបានស្នើសុំ ☐ ផ្សេងៗ.........

១៣.តើលោក លោកស្រីផ្តល់សំណូមពរ ដូចម្តេចចំពោះក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីលើស និងខ្វះគ្រូ ?(ចម្លើយអាចជ្រើសរើសបានច្រើនជាង១)

**ករណីខ្វះ**

☐ ផ្តល់គ្រូថ្មីបន្ថែម

☐ ផ្តល់ប្រាក់ម៉ោងបន្ថែម

☐ កែប្រែប្រព័ន្ធជ្រើសរើសគ្រូដោយយកចេញពីមូលដ្ឋាន ឬសហគមន៍

☐ បង្កើនគ្រូបង្រៀនជាប់កិច្ចសន្យាទៅជាគ្រូកម្រិតបឋមសិក្សា ពេញសិទ្ធ

☐ ផ្សេងៗ......................................................................................................

**ករណីលើស**

☐ ប្រើគោលការណ៍ប្តូរវេនសាលា ក្នុងស្រុក រយៈពេល ៣ឆ្នាំម្តង

☐ ផ្តល់លើកទឹកចិត្តបន្ថែម លើប្រាក់បៀវត្សន៍រៀងរាល់ខែ ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ

☐ លើកទឹកចិត្តបង្កើនកាំប្រាក់ មួយឆ្នាំម្តង ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ

☐ លើកទឹកចិត្តដោយផ្តល់ឱកាសក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ

☐ ផ្សេងៗ......................................................................................................

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក លោកស្រី ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចូលរួមឆ្លើយសំណួរទាំងនេះ។**

**សូមអរគុណ!**

3

ឧបសម្ព័ន្ធទី២ ៖ លិខិតឧទ្ទេសនាមចុះប្រមូលទិន្នន័យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ: ១៣៦ វជអ.វក

ថ្ងៃ ពុធ ៩កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ២០២០

**ជម្រាបជូន**
**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ដើម្បីសរសេរនិក្ខេបបទបំពេញលក្ខខណ្ឌសិក្សាតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅវិទ្យាស្ថានជាតិអប់រំ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក លោកស្រី ប្រធាន ជ្រាបថា៖ និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ សរុបចំនួន២៩នាក់ ស្រី០៧នាក់ ដែលកំពុងសិក្សានៅវិទ្យាស្ថានជាតិអប់រំត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពី ការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០តទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ប្រធាន ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើតាមការគួរ។

សូម លោក លោកស្រី ប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.វេស្សែ សុខណ្ណារ៉ា

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក "ដើម្បីជាព័ត៌មាន"
- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ [illegible] គេហទំព័រ www.nie.edu.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ:១៣៤.....វជអ. ៥៨

# លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០។

និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពីការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ នៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនាឆ្នាំ ២០២០តទៅ៖

| ល.រ | គោត្តនាម-នាម | ភេទ | រាជធានី ខេត្ត |
|---|---|---|---|
| 1 | សុខ ផល្លី | ស | កណ្តាល |
| 2 | ទុន វណ្ណៈ | ប | កណ្តាល |
| 3 | វ៉ង់ ប៊ុនថាន | ប | កែប |
| 4 | គុយ សេងលី | ប | កំពង់ចាម |
| 5 | សំរ៉េត ពេជ្រតា | ស | កំពង់ចាម |
| 6 | ឈាង សោភា | ប | កំពង់ធំ |
| 7 | ពេជ្រ ចំរុង | ប | កំពង់ធំ |
| 8 | ប៊ុត សមពីសិទ្ធ | ប | កំពង់ស្ពឺ |
| 9 | លាង លីលី | ប | កំពង់ស្ពឺ |
| 10 | ជិន សុជី | ប | តាកែវ |
| 11 | មាន់ ម៉ៅ | ប | តាកែវ |
| 12 | មៀង ង៉ុន | ប | ត្បូងឃ្មុំ |
| 13 | យាន ពិសិដ្ឋ | ប | ត្បូងឃ្មុំ |
| 14 | ឆាន ឆាត | ប | បន្ទាយមានជ័យ |

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តមភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ (៨៥៥-២៣) ២១៥/៥៨៤ គេហទំព័រ៖ www.nie.edu.kh

| | | | |
|---|---|---|---|
| 15 | ឌី សុផល | ប | បន្ទាយមានជ័យ |
| 16 | ថាច់ សន | ប | ប៉ៃលិន |
| 17 | សុត សំអូន | ប | ពោធិ៍សាត់ |
| 18 | ហួន ស៊ីថា | ប | ពោធិ៍សាត់ |
| 19 | ប៊ិន សុផាន់ណាក់ | ប | ព្រៃវែង |
| 20 | សេ៎ សាយ៉ាន | ស | ព្រៃវែង |
| 21 | សូ ស៊ីណា | ប | ព្រះសីហនុ |
| 22 | កើត មាយលក្ខិណា | ស | ភ្នំពេញ |
| 23 | សុន ឌីណា | ស | ភ្នំពេញ |
| 24 | ម៉ោញ វង្ឋា | ស | មណ្ឌលគីរី |
| 25 | កែវ សុខជា | ប | ស្ទឹងត្រែង |
| 26 | វួច វី | ប | សៀមរាប |
| 27 | ខូ សុខា | ប | ស្វាយរៀង |
| 28 | អ៊ុក សម្ផស្ស | ស | ស្វាយរៀង |
| 29 | រីន សុធី | ប | ឧត្តរមានជ័យ |

ថ្ងៃពុធ ៩កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណារា

**កន្លែងទទួល៖**

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"

-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក "ដើម្បីជាព័ត៌មាន"

- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"

- សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

ឧបសម្ព័ន្ធទី៣ ៖ លិខិតឧទ្ទេសនាមសាស្ត្រាចារ្យដឹកនាំការសរសេរនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ : ២៧៧ វជអ.សក

## លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០។

គណៈគ្រប់គ្រង និងគ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យដឹកនាំការសរសេរនិក្ខេបបទរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ស្តីពីការ **"ប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ"** នៅតាមរាជធានី ខេត្ត៖

| ល.រ | គ្រូដឹកនាំ | និស្សិត | ភេទ | ករណីសិក្សា |
|---|---|---|---|---|
| 1 | លោក លឹម វ៉ាន់ | សុខ ផល្លី | ស | កណ្តាល |
| 2 | លោក លឹម វ៉ាន់ | ទុន វណ្ណៈ | ប | កណ្តាល |
| 3 | លោក ឡុច ចាន់ថន | វង់ ប៊ុនថាន | ប | កែប |
| 4 | លោក ប៉ូ ប៊ុន្ណន | គុយ សេងលី | ប | កំពង់ចាម |
| 5 | លោក ប៉ូ ប៊ុន្ណន | សំរ៉េត ពេជ្រតា | ស | កំពង់ចាម |
| 6 | លោកបណ្ឌិត អាន វ៉ូប្រាវ | ឈាង សោភា | ប | កំពង់ធំ |
| 7 | លោកបណ្ឌិត អាន វ៉ូប្រាវ | ពេជ្រ ចំរុង | ប | កំពង់ធំ |
| 8 | លោកបណ្ឌិត គួយ សុគាន | ប៊ុត សមពីសិទ្ធ | ប | កំពង់ស្ពឺ |
| 9 | លោកបណ្ឌិត គួយ សុគាន | លាង លីលី | ប | កំពង់ស្ពឺ |
| 10 | លោក ម៉ន មុនិន្ទ | ជិន សុជី | ប | តាកែវ |

| | | | | |
|---|---|---|---|---|
| 11 | លោក ម៉ន មុនិន្ទ | មាន់ ម៉ៅ | ប | តាកែវ |
| 12 | លោកស្រី នូ ចន្ទី | មៀង ង៉ុន | ប | ត្បូងឃ្មុំ |
| 13 | លោកស្រី នូ ចន្ទី | យាន ពិសិដ្ឋ | ប | ត្បូងឃ្មុំ |
| 14 | លោកបណ្ឌិត នី រដ្ឋា | ឆាន ឆាត | ប | បន្ទាយមានជ័យ |
| 15 | លោកបណ្ឌិត នី រដ្ឋា | ឌី សុផល | ប | បន្ទាយមានជ័យ |
| 16 | លោកបណ្ឌិត នួវ រីរ៉ា | ថាច់ សន | ប | ប៉ៃលិន |
| 17 | លោកស្រី ខែក សំណាង | សុត សំអូន | ប | ពោធិ៍សាត់ |
| 18 | លោក លន លីណា | ហួន ស៊ីថា | ប | ពោធិ៍សាត់ |
| 19 | លោក ចាប រតនា | ប៊ិន សុផាន់ណាក់ | ប | ព្រៃវែង |
| 20 | លោក ចាប រតនា | រស់ សាយ៉ាន | ស | ព្រៃវែង |
| 21 | លោក សៀង វាសនា | សូ ស៊ីណា | ប | ព្រះសីហនុ |
| 22 | លោក ម៉ៅ សារឿន | កើត មាយលក្ខិណា | ស | ភ្នំពេញ |
| 23 | លោក ម៉ៅ សារឿន | សុន ឌីណា | ស | ភ្នំពេញ |
| 24 | លោក សៀង វាសនា | ម៉ោញ រដ្ឋា | ស | មណ្ឌលគីរី |
| 25 | លោកបណ្ឌិត នួវ រីរ៉ា | កែវ សុខជា | ប | ស្ទឹងត្រែង |
| 26 | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | វួច រី | ប | សៀមរាប |
| 27 | លោកបណ្ឌិត ឈាង សង្វាត | ខូ សុខា | ប | ស្វាយរៀង |
| 28 | លោកបណ្ឌិត ឈាង សង្វាត | អ៊ុក សម្ផស្ស | ស | ស្វាយរៀង |
| 29 | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | វីន សុធី | ប | ឧត្តរមានជ័យ |

ថ្ងៃ អង្គារ ១៣រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**កន្លែងទទួល៖**

-នាយក នាយករង នាយិការងវេជអ "ដើម្បីជ្រាបជាព័ត៌មាន"

-ប្រធានដេប៉ាតឺម៉ង់-ការិយាល័យក្រោមឱវាទវេជអ "ដើម្បីសហការ"

-សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារៈ ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការវេជអ